៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ


ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤០ ខែ មេសា

ព.ស. ២៥១២ គ.ស. ១៩៦៨

-ភ្នំពេញ-

ÉCOLE FRANÇAISE D'EXTRÊME ORIENT
BIBLIOTHÈQUE
P.P.
F.745

៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

| អត្ថបទ | | ទំព័រ |
|---|---|---|
| | **ផ្នែកសាសនា** | |
| ១– | កបិលកថាសង្ខេប (ត) សម្ដេចព្រះពោធិវង្ស រៀបរៀង . . . . . | ៣៦០ |
| ២– | រឿងមហោកាលទសក (សហ. ប៊ុ-ប៊ូ ប្រែរៀបរៀង) . . . . . . | ៣៧១ |
| ៣– | រឿងព្រះទេវទត្ត (សហ. ប៊ូ-ប៊ូ ប្រែ-រៀបរៀង) . . . . . | ៣៧៩ |
| | **ផ្នែកអក្សរសាស្ត្រ** | |
| ៤– | វចនានុក្រមសំស្ក្រឹត ខ្មែរ (ព្រះមហា ជាំង.ទាត់) . . . . . | ៣៧៧ |
| ៥– | ល្បងសិក្សា ប្រវត្តិអក្សរសាស្ត្រខ្មែរ (សហ. លាង.ហ៊ាបអាន) . . | ៣៨១ |
| ៦– | រឿងចៅកែលលក (ត ចប់) (សហ. ព្រួច-កុម រៀបរៀង) . . . | ៣៩១ |
| ៧– | រឿងសាមកុក (ត) (ឧកញ៉ា ត្នូ-កន) . . . . . . . . | ៤០៣ |
| ៨– | ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត (លោក ញុំត.ថែម) . . . . | ៤២៣ |
| ៩– | ជីវប្រវត្តិសង្ខេប (សហ. ហែល-ស៊ុំផា) . . . . . . . . | ៤៣៣ |
| ១០– | រឿងពិសពស និង ពិសត្រី (សហ. លី-ធាមតេង រៀបរៀង តាមឯកសារ) | ៤៤១ |
| | **ផ្នែកកំណត់-ប្រវត្តិការណ៍** | |
| ១១– | ពិធីបុណ្យឆ្លងព្រះវិហារ-បញ្ចុះខណ្ឌសីមាវត្តនិគ្រោធវង្ស . . . . | ៤៤៦ |
| ១២– | សុន្ទរកថានៃព្រះធុតីកោសល ស៊ូរ ហាយ . . . . . . . | ៤៥៤ |
| ១៣– | ឯកសារព្រះរាជក្រមស្ដីពីពុទ្ធសាសនបណ្ឌិត្យ . . . . . . | ៤៦៦ |

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការល្អមក, ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប. ព.

# កឋិនកថាសង្ខេប

*សម្តេចព្រះពោធិវង្ស ហួត តាត រៀបរៀង*

(ក)

*រួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ គិតថា «អញនឹងត្រឡប់មកវិញ» ; លុះទៅដល់ខាងក្រៅឧបចារសីមា ក៏ឲ្យគេជួយធ្វើចីវរនោះ ៗ កាលដែលធ្វើចីវររួចហើយ ក៏នៅតែគិតថា «អញនឹងត្រឡប់វិញ ៗ» ប៉ុន្តែមិនទាន់ត្រឡប់ ក៏ចេះតែនៅខាងក្រៅឧបចារសីមា. នោះ គ្រាតែដល់កំណត់កាលដែលកឋិនដោះ គឺកន្លងហួសថ្ងៃ១៥កើតខែផល្គុណទៅ ៗ កឋិនរបស់ភិក្ខុនោះ ក៏ដោះក្នុងគ្រាដែលកន្លងហួសសីមា គឺកន្លងហួសខេត្រនៃកឋិន ។*

*(ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ក្រោយ)*

៨– សហុព្ភារក មាតិកា មានការដោះកឋិនរួមជាមួយនឹងភិក្ខុទាំងឡាយ ។ សេចក្ដីថា ភិក្ខុបានក្រាល - បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើ ចេញពីអាវាសទៅ គិតថា "អញនឹងត្រឡប់វិញ"; កាលទៅដល់ខាងក្រៅឧបចារសីមា ក៏បានឲ្យគេជួយធ្វើចីវរនោះ លុះធ្វើចីវររួចហើយ គិតថា "អញនឹងត្រឡប់វិញ ។" ហើយបានត្រឡប់មកទាន់ពេលដោះកឋិន ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះជាមួយនឹងភិក្ខុទាំងឡាយ ។

(ក្នុងមាតិកានេះ បលិពោធទាំងពីរដាច់ស្មើគ្នា មិនមុនមិនក្រោយ គឺដាច់ក្នុងពេលដែលចប់កម្មវាចា) ។

មាតិកា ៨ ចប់ដោយសង្ខេប

---

កឋិនុព្ភារៈ "ការដោះកឋិន ឬ កឋិនដោះ"

ស. ការដោះកឋិន មានប៉ុន្មានយ៉ាង ?

ឆ. ក្នុងគម្ពីរវិនយាលង្ការដីកាថា(១) ការដោះកឋិនមានពីរយ៉ាងគឺ អដ្ឋមាតិកាឧព្ភារៈ ១ អន្តរុព្ភារៈ ១ ។

ស. ការដោះកឋិនទាំងពីរខាងលើនេះ មានសេចក្ដីដូចម្ដេច ហើយផ្សេងគ្នាយ៉ាងណាខ្លះ ?

ឆ. អដ្ឋមាតិកាឧព្ភារៈ ប្រែថា "ការដោះកឋិន ឬកឋិនដោះ តាម

---

១ ខន្ធកេ ទុវិធោ អដ្ឋមាតិកាឧព្ភារអន្តរុព្ភារវសេន ។

មាតិកា ៨ " ។ សេចក្តីអធិប្បាយថា ការដោះកឋិនតាមមាតិកា ៧ គឺតាំងពី បក្កមនន្តិកា ដល់ សីមាតិក្កន្តិកា នោះ លោកពោលសំដៅ យកតែភិក្ខុដែលចេញទៅខាងក្រៅឧបចារសីមា ហើយធ្វើឲ្យកឋិនដោះ ក្នុងទីនោះតែម្តង ។ ឯការដោះកឋិនតាមមាតិកា១ គឺ សហុព្ភារៈ នោះគឺ ចំពោះតែភិក្ខុដែលចេញទៅខាងក្រៅឧបចារសីមាដែរ ប៉ុន្តែត្រឡប់មកវិញ ទាន់ការដោះកឋិនក្នុងចន្លោះកាលកំណត់ ដែលហៅថា អន្តរុព្ភារៈ ក្នុង វត្តដែលខ្លួនបានក្រាល - បានអនុមោទនាកឋិន ហើយបានធ្វើនូវការដោះ កឋិននោះ រួមជាមួយនឹងភិក្ខុទាំងឡាយ, រួមជាមាតិកា ៨ ។ ការដោះ កឋិនតាមមាតិកាទាំង ៨ នេះ ហៅថា អដ្ឋមាតិកាឧព្ភារៈ ។

រីឯ អន្តរុព្ភារៈ ប្រែថា "ការដោះកឋិនក្នុងចន្លោះកាលកំណត់" ។ សេចក្តីអធិប្បាយថា ការដោះកឋិន ដោយញត្តិទុតិយកម្មវាចា ដែល សម្រាប់សូត្រដោះកឋិន មិនចូលទៅក្នុងមាតិកា៨ទេ ហៅថា អន្តរុព្ភារៈ ព្រោះការដោះកឋិននោះ សម្រាប់តែភិក្ខុដែលមិនបានចេញទៅខាងក្រៅ ឧបចារសីមា គឺនៅតែក្នុងវត្តនោះ មិនទាន់ដល់កាលបរិច្ឆេទទេ តែ ប្រជុំគ្នាធ្វើការដកកឋិនក្នុងចន្លោះកាលកំណត់ ។

ការដោះកឋិនទាំង២យ៉ាង គឺអដ្ឋមាតិកាឧព្ភារៈ និងអន្តរុព្ភារៈ មាន សេចក្តីផ្សេងគ្នាដូចអធិប្បាយខាងលើនេះ ។

ក្នុងគម្ពីរដែល មានសេចក្ដីបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតថា[១] អន្តរុព្ភារៈ និងសហុព្ភារៈទាំងពីរនេះ សង្ឃធ្វើដោយញត្តិទុតិយកម្មវាចា ។ ឯកឋិនុព្ភារៈ ៧ មានបក្កមនន្តិកាជាដើម ភិក្ខុមិនបានធ្វើដោយកម្មវាចាទេ ។

សរ. ការដោះកឋិន ២ យ៉ាងគឺ អន្តរុព្ភារៈ និងសហុព្ភារៈ មានសេចក្ដីប្លែកគ្នាដូចម្ដេច ?

ឆ. អន្តរុព្ភារៈ គឺភិក្ខុច្រើនរូប មិនបានចេញទៅខាងក្រៅឧបចារ-សីមាទេ ឋិតនៅតែខាងក្នុងឧបចារសីមាប្រជុំគ្នាធ្វើ ។ ឯសហុព្ភារ គឺភិ មួយរូប ៗ ចេញទៅខាងក្រៅឧបចារសីមា ហើយត្រឡប់មកវិញទាន់ អន្តរុព្ភារៈនោះ ហើយបានធ្វើជាមួយនឹងភិក្ខុទាំងឡាយ ដែលឋិតនៅក្នុង ឧបចារសីមានោះ ។ នេះ ជាសេចក្ដីប្លែកគ្នា នៃអន្តរុព្ភារៈ និង សហុព្ភារៈ នោះ ។

សរ. ភិក្ខុសង្ឃ ប្រជុំគ្នាសូត្រកម្មវាចាដោះកឋិន ក្នុងចន្លោះកាល គឺមិនទាន់ដល់កំណត់កាលនៃកឋិន តើដោយហេតុអ្វី ?

ឆ. ភិក្ខុសង្ឃ បានជាប្រជុំគ្នាសូត្រកម្មវាចាដោះកឋិនដូច្នេះ ដោយហេតុថាមានឧបាសកទាំងឡាយ មានបំណងនឹងធ្វើទានធំ ៗ ចង់ប្រគេន អកាលចីវរដល់ភិក្ខុទាំងឡាយ ដែលមិនបានក្រាល - អនុមោទនាកឋិន

---

១ អន្តរុព្ភារសហុព្ភារា ញត្តិទុតិយកម្មវាចាយេវ កតា បក្កមនន្តិកាទយោ សត្ត កឋិនុព្ភារា ន កម្មវាចាយ កតា ។

បាននិមន្តមកដល់ ដាល់ដាប់ល់ដោយហូរហែ គេសុំឲ្យព្រះភិក្ខុសង្ឃក្នុងកឋិនាវាសដកកឋិនចេញ ។ (រឿងនេះព្រះពុទ្ធជាម្ចាស់ទ្រង់បានអនុញ្ញាតក្នុងភិក្ខុនីវិភង្គ ត្រង់សិក្ខាបទទី ១០ នៃនគ្គវគ្គ ដោយហេតុមានឧបាសកម្នាក់ ចង់ប្រគេននូវអកាលចីវរ ដល់ឧភតោសង្ឃ ហើយបានសូមព្រះភិក្ខុសង្ឃឲ្យដកកឋិនចេញ ) ។

ដូច្នេះក្នុងវត្តមួយ ៗ កាលបើសង្ឃបានក្រាល-អនុមោទនាកឋិនហើយ សង្ឃលាភទាំងប៉ុន្មានដែលកើតឡើងក្នុងវត្ត ត្រូវតែចែកដល់សង្ឃដែលបានក្រាល-អនុមោទនាកឋិនទាំងនោះ មិនត្រូវចែកដល់សង្ឃដទៃឡើយ បើលុះតែផុតកាលនៃកឋិន គឺផុតពីថ្ងៃ ១៥ កើត ខែផល្គុណទៅ ឬបើមិនទាន់ផុតកាលនៃកឋិននៅឡើយទេ ប៉ុន្តែសង្ឃបានប្រជុំគ្នាសូត្រកម្មវាចាដកកឋិន ក្នុងចន្លោះកាលកឋិននោះ ទើបសង្ឃលាភដែលកើតឡើងក្នុងវត្តនោះ អាចនឹងចែករំលែកដល់ភិក្ខុសង្ឃឯទៀត ៗ បាន ។

រីឯវិធីសូត្រកម្មវាចាដកកឋិន ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យភិក្ខុ ១ រូបដែលឈ្លាសប្រតិពល សូត្រប្រកាសសង្ឃ ដោយញត្តិទុតិយកម្មវាចា ថា ៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ
សង្ឃោ កឋិនំ ឧទ្ធរេយ្យ ។ ឯសា ញត្តិ ។ សុណាតុ

មេ ភន្តេ សង្ឃោ សង្ឃោ កឋិនំ ឧទ្ធរតិ ។ យស្សាយស្មតោ ខមតិ កឋិនស្ស ឧទ្ធារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧទ្ធតំ សង្ឃេន កឋិនំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

បពិត្រព្រះសង្ឃដ៏ចម្រើន ! សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ (ការណ៍នេះ) បើជាការគួរដល់សង្ឃហើយ សង្ឃគួរដោះកឋិនចេញ ។ នេះជាពាក្យប្រកាសឲ្យសង្ឃបានជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន ! សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃដោះកឋិន ។ ការដោះកឋិន គួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។ កឋិនសង្ឃដោះហើយ ។ គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំចាំទុកនូវការព្រមព្រៀងរបស់សង្ឃ ដោយអាការស្ងៀមយ៉ាងនេះ ។

កឋិនុព្ភារៈចប់

## កឋិន កថា « ប្រភេទនៃកឋិន »

ក្នុងគម្ពីរបរិវារៈ មានសេចក្ដីថ្លែងអំពីប្រភេទនៃកឋិន ពិស្ដារក្រៃពេកណាស់ ។ ខ្ញុំស្រង់យកនូវសេចក្ដីខ្លីៗ បន្តិចបន្តួច ពីក្នុងគម្ពីរបរិវារៈនោះ

ចំពោះតែត្រង់សេចក្ដីណាដែលមានប្រយោជន៍ ហើយជាសេចក្ដីងាយយល់ មកតម្កល់ទុកក្នុងទីនេះ ដើម្បីឲ្យយុវភិក្ខុ ងាយស្រួលក្នុងការសិក្សា ដូចមានតទៅនេះ ៖

ស. ធម៌ដែលកើតដំណាលគ្នានឹងការក្រាលកឋិន មានប៉ុន្មានយ៉ាង?

ឆ. ធម៌ដែលកើតដំណាលគ្នានឹងការក្រាលកឋិន មាន ១៩ យ៉ាងគឺ មាតិកា ៨ បលិពោធ ២ និងអានិសង្ស ៩ ។ តាំង ១៩ នេះ ហៅថា សហជាតធម៌ ប្រែថា ធម៌កើតដំណាលគ្នា ឬកើតជាមួយគ្នា ។

ស. បុព្វករណៈ លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង ?

ឆ. បុព្វករណៈ លោកសង្គ្រោះដោយធម៌ ៧ យ៉ាង គឺ ធោវន ការបោកគក់ ១ វិចារណៈ ការចាត់ចែងវាស់វែង ១ ឆេទនៈ ការកាត់ ១ ពន្ធនៈ ការដានផ្គុំ ១ សិព្វនៈ ការដេរ ១ រជនៈ ការជ្រលក់ ១ កប្បករណៈ ការធ្វើពិន្ទុកប្បៈ ១ ។

ស. បច្ចុទ្ធារៈ លោកសង្គ្រោះដោយរូបធម៌ប៉ុន្មានយ៉ាង ?

ឆ. បច្ចុទ្ធារ លោកសង្គ្រោះដោយរូបធម៌៣ យ៉ាង គឺសង្ឃាដី ១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១ ។

ស. អធិដ្ឋាន លោកសង្គ្រោះដោយរូបធម៌ប៉ុន្មានយ៉ាង ?

ឆ. អធិដ្ឋាន លោកសង្គ្រោះដោយរូបធម៌ ៣ យ៉ាងគឺ សង្ឃាដី ១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១ ។

ស. អត្ថារៈ ការក្រាលកឋិន លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង?

ឆ. អត្ថារៈ ការក្រាលកឋិន លោកសង្គ្រោះដោយធម៌តែ ១ យ៉ាង គឺវចីភេទ ការបញ្ចេញវាចា (ឲ្យសង្ឃបានឮគ្រប់រូប) ។

ស. កឋិន មានមូលប៉ុន្មាន? មានវត្ថុប៉ុន្មាន? មានភូមិប៉ុន្មាន?

ឆ. កឋិន មានមូល ១ គឺជំនុំសង្ឃ; មានវត្ថុ ៣ គឺ សង្ឃាដី១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១; មានភូមិ ៦ គឺ ខោមៈ សំពត់ធ្វើដោយសរសៃសម្បកឈើ ១ កប្បាសិកៈ សំពត់ធ្វើដោយកប្បាស១ កោសេយ្យៈ សំពត់ធ្វើដោយសូត្រ១ កម្ពលៈ សំពត់ធ្វើដោយរោមសត្វ១ សាណៈ សំពត់ធ្វើដោយសម្បកធ្មៃ១ ភង្គៈ សំពត់ធ្វើដោយវត្ថុទាំង ៥ ខាងដើមលាយចម្រុះគ្នា ១ ។

ស. កឋិន មានអ្វីជាខាងដើម? មានអ្វីជាកណ្តាល? មានអ្វីជាខាងចុង?

ឆ. កឋិន មានបុព្វករណៈជាខាងដើម; មានកិរិយា គឺបច្ចុទ្ធារ និងអធិដ្ឋាន ជាកណ្តាល; មានអត្ថារៈ ជាខាងចុង ។

ស. បុគ្គលប្រកបដោយអង្គប៉ុន្មាន មិនគួរក្រាលកឋិន?

ឆ. បុគ្គលប្រកបដោយអង្គ ៨ មិនគួរក្រាលកឋិន ។ អង្គ ៨ នោះគឺ មិនចេះបុព្វករណៈ ១ មិនចេះបច្ចុទ្ធារៈ ១ មិនចេះអធិដ្ឋាន ១ មិនចេះក្រាល

១ មិនចេះមាតិកា ១ មិនចេះបលិពោធ ១ មិនចេះការដោះកឋិន ១ មិន ចេះអានិសង្ស ១ រួមជា ៨ ។

ស. ចុះបុគ្គលប្រកបដោយអង្គប៉ុន្មាន ទើបគួរក្រាលកឋិន ?

ឆ. បុគ្គលប្រកបដោយអង្គ ៨ ដែរ ទើបគួរក្រាលកឋិន ។ អង្គ ៨ នោះគឺ ចេះបុព្វករណៈ ១ ចេះបច្ចុទ្ធរៈ ១ ចេះអធិដ្ឋាន ១ ចេះក្រាល ១ ចេះមាតិកា ១ ចេះបលិពោធ ១ ចេះការដោះកឋិន ១ ចេះអានិសង្ស ១ រួមជា ៨ ។

ស. ការក្រាលកឋិន របស់បុគ្គលប៉ុន្មានពួក មិនបានឡើងជាកឋិន? ប៉ុន្មានពួក ទើបឡើងជាកឋិន ?

ឆ. ការក្រាលកឋិន របស់បុគ្គល ៣ ពួក មិនបានឡើងជាកឋិន ឡើយ គឺ បុគ្គលឋិតនៅក្រៅឧបចារសីមាក្រាល - អនុមោទនាកឋិន ១ បុគ្គលក្រាល - អនុមោទនាកឋិន មិនបានបញ្ចេញវាចា ១ បុគ្គលកាល ដែលបញ្ចេញវាចា មិនបានឲ្យអ្នកដទៃដឹងសេចក្តីច្បាស់ ១ ។

ការក្រាលកឋិន របស់បុគ្គល ៣ ពួក ក្រៅពីនេះទើបបានឡើងជា កឋិនគឺ បុគ្គលឋិតនៅក្នុងឧបចារសីមាក្រាល - អនុមោទនាកឋិន ១ បុគ្គល កាលក្រាល - អនុមោទនាកឋិន បានបញ្ចេញវាចា ១ បុគ្គលកាលដែល បញ្ចេញវាចា បានឲ្យអ្នកដទៃដឹងសេចក្តីច្បាស់ ១ ។

ស. ការក្រាលកឋិនប៉ុន្មានយ៉ាង មិនឡើងជាកឋិន? ប៉ុន្មានយ៉ាង ទើបឡើងជាកឋិន ? ។

ឆ. ការក្រាលកឋិន ៣ យ៉ាង មិនឡើងជាកឋិនឡើយ គឺ

១– វត្ថុវិបន្ន វត្ថុខុស បានដល់សំពត់កឋិនជាអកប្បិយៈ គឺចីវរមិនត្រឹមត្រូវ ។

២- កាលវិបន្ន កាលខុស បានដល់កាលដែលទាយកប្រគេនសំពត់ក្នុងថ្ងៃនេះ សង្ឃប្រគល់ឲ្យដល់ភិក្ខុអ្នកក្រាល ក្នុងថ្ងៃស្អែក ។

៣– ករណវិបន្ន ធ្វើខុស បានដល់ការមិនបានធ្វើសំពត់ដែលនៅថ្មីសុទ្ធ ឲ្យទៅជាចីវរត្រឹមត្រូវ ឲ្យទាន់ក្នុងថ្ងៃនោះ ។

ការក្រាលកឋិន ៣ យ៉ាងក្រៅពីនេះ ទើបបានឡើងជាកឋិន គឺ

១– វត្ថុសម្បន្ន វត្ថុត្រូវ បានដល់សំពត់កឋិនជាកប្បិយៈ គឺចីវរត្រឹមត្រូវ ។

២– កាលសម្បន្ន កាលត្រូវ បានដល់កាលដែលទាយកប្រគេនសំពត់កឋិនក្នុងថ្ងៃណា សង្ឃបានប្រគល់ឲ្យភិក្ខុអ្នកក្រាលក្នុងថ្ងៃនោះ។

៣- ករណសម្បន្ន ធ្វើត្រូវ បានដល់ការធ្វើចីវរឲ្យបានត្រឹមត្រូវ ហើយទាន់ក្នុងថ្ងៃនោះ ប្រសិនបើសំពត់នោះជាសំពត់នៅថ្មីសុទ្ធនៅឡើយ ។ បើសំពត់ដែលទាយកប្រគេនមកនោះ គេបានធ្វើចីវរត្រឹមត្រូវរួចស្រេចមកហើយ នោះមិនចាំបាច់ធ្វើអ្វីទៀតទេ ត្រូវតែបច្ចុទ្ធ័

អធិដ្ឋានក្រាល ឲ្យហើយស្រេចក្នុងថ្ងៃនោះ ក៏អាចចាត់ទុកជា ករណ-សម្បន្នពេញទី ។

ស. ខែណា ជាខែដែលត្រូវក្រាលកឋិន ?

ឆ. ខែ ១ ជាខាងចុងនៃវស្សានរដូវ គឺតាំងពីថ្ងៃ ១ កើតខែអស្សុជ ទៅទាល់ទីងថ្ងៃ ១៥ កើតខែកត្តិក ជាខែដែលត្រូវក្រាលកឋិន ។

ស. ការក្រាលកឋិន ដែលជា អត្ថារវិបត្តិ "ក្រាលខុស" ឬជា អត្ថារសម្បត្តិ "ក្រាលត្រូវ" ត្រូវដឹងដោយអ្វី ?

ឆ. ការក្រាលកឋិន ជាអត្ថារវិបត្តិ ត្រូវដឹងដោយអត្ថាការ ២៤; ដែលជាអត្ថារសម្បត្តិ ត្រូវដឹងដោយអត្ថាការ ១៧ ដែលបានពោលរួចមកហើយក្នុងខាងដើម ។

កឋិនកថាសង្ខេប

ចប់ ។

---

អង្គិលបត្តិ ដែលប្រទូស្លាក់
ត្រូវហាក់ទឹកច្រើន ទើបលាងជ្រះ
រីឯទោសខុស គិបត្តបទ្ទះ
ត្រូវលាងឲ្យជ្រះ ដោយគុណាច្រើន

ជ-ន

# រឿងមហាកាលឧបាសក

## អដ្ឋកថាធម្មបទ ភាគទី ៦ អត្តវគ្គទី ១២

លោក ប៊ូ.ប៊ុំ ប្រែ - រៀបរៀង

កាលព្រះបរមសាស្ដាគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវឧបាសកជាសោតាបន្នម្នាក់ ឈ្មោះមហាកាល សំដែងធម៌ដោយបទគាថា ថា អត្តនា ហិ កតំ បាបំ ដូច្នេះជាដើម ។

បានឮមកថា ឧបាសកនោះ រក្សាឧបោសថសីលក្នុងមួយខែ៨ថ្ងៃ ស្ដាប់ធម្មកថាក្នុងវិហារតាំងពីព្រលប់ដល់ភ្លឺ ។ គ្រានោះ ពួកចោរគាស់កាត់ជញ្ជាំងផ្ទះមួយ ក្នុងវេលាយប់លួចយកទ្រព្យរបស់, អ្នកម្ចាស់ផ្ទះឮសំឡេងភាជនលោហៈទង្គិចគ្នា ភ្ញាក់ដឹងខ្លួនឡើង ក៏ស្ទុះទៅដេញតាមចាប់ចោរ ។ ភ័យខ្លាំងបោះបង្វិចទ្រព្យចោលហើយខំរត់ឲ្យរួចតែខ្លួនទៅបាត់ ។ ចំណែកម្ចាស់ទ្រព្យ ចេះតែដេញតាមចោរប្រកិតៗឥតឈប់ ។ ចោរទាំងនោះ ខំរត់គេចខ្លួនបែកខ្ញែកគ្នាអស់ ។ មានចោរម្នាក់ រត់ត្រង់ទៅចំវិហារ បោះបង្វិចទ្រព្យចោលនៅមុខមហាកាលឧបាសក ដែលស្ដាប់ធម្មកថាក្នុងវិហារពេញមួយយប់ដល់ភ្លឺហើយ ទៅលុបលាងមុខមាត់នៅឆ្នេរស្រះខាងមុខវិហារហើយចោរនោះរត់បាត់ទៅ ។ ពួកមនុស្ស ដេញតាមចោរមកដល់ទីនោះឃើញបង្វិចទ្រព្យ ក៏និយាយថា អាឯងគាស់ជញ្ជាំងផ្ទះរបស់ពួកអញលួចបង្វិចទ្រព្យអញមកហើយក្លែងខ្លួនធ្វើដូចជាអ្នកស្ដាប់ធម៌, ថារួចចាប់ឧបាសកនោះវាយសម្លាប់ចោលទៅ ។ លំដាប់នោះ ភិក្ខុកម្លោះនិងសាម-

ណោរកាន់ក្អមទៅដងទឹកពីព្រលឹម បានឃើញខ្មោចឧបាសកនោះ ហើយក៏ក្រាបទូលព្រះសាស្តាថា ឧបាសក ដែលស្តាប់ធម្មកថាក្នុងវិហារ ស្លាប់ដោយការមិនសមគួរសោះ ។ ព្រះបរមសាស្តាទ្រង់ត្រាស់ៈ មែនហើយ ភិក្ខុទាំងឡាយ! កាលឧបាសក ស្លាប់ក្នុងអត្តភាពនេះមិនសមគួរទេ ប៉ុន្តែសមគួរតាមកម្មដែលខ្លួនធ្វើទុកពីកាលមុន ។ ភិក្ខុទាំងនោះ ក្រាបទូលអារាធនាទើបព្រះពុទ្ធអង្គទ្រង់សំដែងបុព្វកម្មរបស់ឧបាសកនោះ ដូចតទៅនេះ ៖

បានឮថា ក្នុងកាលកន្លងទៅយូរហើយ មានពួកចោរលាក់ខ្លួនពួននៅក្នុងដងព្រៃជិតដំបន់បច្ចន្តគ្រាមមួយ ក្នុងដែនរបស់ព្រះបាទពា-រាណសី ។ ព្រះរាជាទ្រង់តាំងរាជបម្រើម្នាក់ឲ្យនៅក្នុងដងព្រៃមួយ ។ រាជបម្រើនោះស៊ីឈ្នួលនាំផ្លូវពួកមនុស្ស ពីនេះទៅខាងនោះ នាំផ្លូវពួកមនុស្សពីខាងនោះមកខាងនេះឆ្លងកាត់ព្រៃ ដែលមានពួកចោរចាំប្លន់នោះ ឲ្យពួកឈ្មួញបានរួចពីអន្តរាយ ។ គ្រានោះ មានមនុស្សម្នាក់ ឲ្យភរិយារបស់ខ្លួន ដែលមានរូបល្អស្អាតឡើងជិះរទេះតូចបរទៅដល់ទីនោះ ។ រាជបម្រើក្រឡេកឃើញស្រីនោះ កើតចិត្តស្រឡាញ់ កាលប្តីនាងនោះនិយាយថា បពិត្រនាយ! សូមលោកនាយមេត្តាចម្លងខ្ញុំឲ្យផុតពីព្រៃដែលមានគ្រោះថ្នាក់នេះផង ។ រាជបម្រើឆ្លើយថា ពេលនេះយប់ងងឹតហើយ ចាំព្រឹកឡើងយើងនឹងចម្លងអ្នកទៅពីព្រលឹម ។ នៅថ្ងៃក៏ទេលោកនាយ សូមមេត្តានាំផ្លូវខ្ញុំទៅពេលនេះចុះ ។ ចូរអ្នកត្រឡប់ទៅ

វិញ  អាហារនិងទីលំនៅ មានក្នុងផ្ទះយើងសព្វគ្រប់ស្រាប់ហើយ ។ បុរសប្តី មិនព្រមត្រឡប់វិញ  រាជបម្រើញាក់មុខធ្វើសញ្ញាឲ្យពួកបុរសជាបរិវាររបស់ខ្លួនចាប់ទាញរទេះត្រឡប់មុខមកផ្ទះខ្លួនវិញ ប៉ុន្តែឲ្យឈប់រទេះដេកនៅត្រង់ខ្លោងទ្វាររបង  ឲ្យបុគ្គលចាត់ចែងអាហារយកមកឲ្យបុរសប្តីប្រពន្ធដែលឥតចង់នៅបរិភោគសោះ ។ ឯក្នុងផ្ទះរាជបម្រើនោះមានកែវមណីមួយដុំ ។ រាជបម្រើប្រើមនុស្សឲ្យលបយកកែវមណីនោះទៅដាក់លាក់ក្រោមបាតរទេះរបស់បុរសនោះ  ហើយឲ្យស្រែកដូចជាចោរចូលទៅនៅពេលជិតភ្លឺ ។ គ្រានេះ ពួកបុរសរបស់រាជបម្រើប្រាប់ថា បពិត្រលោកនាយ ! ចោរលួចយកកែវមណីទៅបាត់ហើយ ។ រាជបម្រើបង្គាប់ថា  អ្នកពល់គ្នាចូរដាក់បុរសឲ្យចាំយាមឃ្លាំមើលក្បែរខ្លោងទ្វាររបងហើយត្រួតត្រាមើលអ្នកដំណើរដែលចេញមកអំពីក្នុងស្រុក ។ បុរសប្តីប្រពន្ធ ទឹមរទេះបរចេញទៅពីព្រលឹម ។ ពេលនោះពួកអ្នកយាមល្បាតឃាត់រទេះ ហើយរើមើលឃើញកែវមណីដែលខ្លួនលាក់ទុកនោះ ហើយស្រែកគំហកថា  អាឯងលបលួចយកកែវមណីតែទៅ ។ វាយហើយនាំយកទៅប្រគល់ជូនរាជបម្រើជំរាបថា  បពិត្រលោកនាយ ! ពួកខ្ញុំចាប់ចោរបានហើយ ។ រាជបម្រើនិយាយថា  អញជាអាមាត្យ  ឲ្យវានៅក្នុងផ្ទះឲ្យបាយស៊ីទៀត  វាហ៊ានលួចយកកែវមណីអញទៅ  អ្នកពល់គ្នាចូលចាប់អាចោរកំណាចនោះឲ្យជាប់  វាយឲ្យស្លាប់  ហើយយកខ្មោចវាទៅបោះ

បោលឲ្យឆ្ងាយទៅ នេះជាបុព្វកម្មរបស់ឧបាសកនោះ ។ ភជបម្រើបត្រពីអត្តភាពនោះហើយទៅកើតក្នុងអវិចនរក នៃះក្នុងនរកអស់កាលជាយូរ ដល់បានមកកើតជាមនុស្ស ត្រូវគេវាយសម្លាប់បែបនេះ ជាច្រើនរយជាតិ ដោយផលកម្មដ៏សេសសល់ ។

ព្រះបរមសាស្តាកាលទ្រង់សម្ដែងបុព្វកម្ម របស់មហាកាលឧបាសកយ៉ាងនេះចប់ហើយ ត្រាស់ថាៈ ម្នាលភិក្ខុទាំងឡាយ ! កម្មដែលខ្លួនធ្វើខ្លួនឯង រមែងញាំញីសត្វទាំងនេះ ក្នុងអបាយបួនយ៉ាងនេះហើយ ត្រាស់គាថាថា ៖

អត្តនា វ កតំ បាបំ អត្រជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ វជិរំវម្ហយំ មណឹ ។

បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សអ្នកឥតបញ្ញា ដូចពេជ្រ សម្រាប់កាត់កែវមណីដែលកើតអំពីថ្មនោះ ។

កាលចប់ធម្មទេសនា ពួកភិក្ខុអ្នកប្រជុំគ្នានោះ បានសម្រេចមគ្គផល មានសោតាបត្តិផលជាដើម ។

រឿងមហាកាលឧបាសក ចប់ ។

ដង្វាលេចពីសាច់
ឬថាច្រេះចេញពីដែក

# រឿងព្រះទេវទត្ត

## អដ្ឋកថាធម្មបទ ភាគទី៦ អត្ថវគ្គទី ១២

លោកប៊ូ - ប៉ូ ប្រែ - រៀបរៀង

កាលព្រះបរមសាស្តាគង់គង់វត្តវេឡុវន ទ្រង់ប្រារព្ធនឹងព្រះទេវទត្ត សំដែងធម៌ដោយបទគាថាថា យស្ស អច្ចន្តទុស្សីល្យំ ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ពួកភិក្ខុនិយាយគ្នាក្នុងរោងធម៌ថា អាវុសោទាំងឡាយ ! ព្រះទេវទត្ត ជាមនុស្សទ្រុស្តសីល កាន់ធម៌ដ៏អាក្រក់ លាមក កាលតណ្ហាចម្រើនច្រើនឡើង ព្រោះហេតុជាមនុស្សទ្រុស្តសីល ក៏ទៅបញ្ចុះបញ្ចូលព្រះបាទអជាតសត្រូវ ញុំាងលាភនិងសក្ការៈជាច្រើនឲ្យកើតឡើង ដឹកនាំព្រះបាទអជាតសត្រូវឲ្យធ្វើឃាតព្រះបិតា រួមចិត្តគ្នានឹងព្រះបាទអជាតសត្រូវនោះ ខ្វល់ខ្វាយរកឧបាយ ដើម្បីនឹងសម្លាប់ព្រះតថាគត ដោយប្រការផ្សេង ៗ ។ ព្រះសាស្តាស្តេចមកដល់ ត្រាស់សួរថា នែភិក្ខុទាំងឡាយ ! ពេលនេះ ពួកអ្នកអង្គុយសន្ទនាគ្នាពីរឿងអ្វី? ។ កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាប ហើយត្រាស់ថា ភិក្ខុទាំងឡាយ ! មិនមែនតែក្នុងគ្រានេះទេ សូម្បីពីកាលមុន ទេវទត្តក៏ព្យាយាមរកឧបាយនឹងសម្លាប់តថាគត ដោយប្រការផ្សេង ៗ ដូច្នេះដែរ ទ្រង់សម្តែងក្បាលជាតកជាដើមចប់ហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ! តណ្ហា

រមែងកើតឡើងព្រោះហេតុជាមនុស្សទ្រុស្តសីល រមែងប្រានទម្លាក់នូវបុគ្គលទ្រុស្តសីលហួសប្រមាណ ទៅក្នុងនរកជាដើម ដូចព្រៃជ្រៃរួបរឹតដើមពាំងឲ្យបាក់រលំបាត់ទៅ ទ្រង់សម្តែងគាថាថា ៖

យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។

អំពើទ្រុស្តសីលហួសហេតុ(១) គ្របសង្កត់ (នូវអត្តភាព) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះឈ្មោះថា ធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរ ប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាសដូច្នោះ ។

កាលចប់ធម្មទេសនា ជនជាច្រើននាក់ បានសម្រេចមគ្គផល មានសោតាបត្តិផលជាដើម ។

រឿងព្រះទេវទត្ត ចប់ ។

| |
|---|
| បើដៃខ្វី កុំស្រវាឱបភ្នំ<br>ក្រែងឱបមិនជុំ ព្រះធរណីស្រូប |

---

១- បើគ្រហស្ថ ចាប់តាំងពីកើតមក ធ្វើតែអកុសលកម្មបថទាំង១០, បើបព្វជិត តាំងពីថ្ងៃឧបសម្បទមក ត្រូវគរុកាបត្តិគឺអាបត្តិមានទោសធ្ងន់ យ៉ាងនេះឈ្មោះថាអំពើទ្រុស្តសីលហួសហេតុ ។ ធម្មបទដ្ឋកថា ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ក)

*ព្រះមហា ចាន់-ទាត់ រៀបរៀង*

---

អបិសាច គុ. ដែលមិនជាបិសាច ដែលរួចពីបិសាច ។

អបិហិត គុ. ដែលលាក់ ដែលគ្រប ដែលបាត់ ។

អបី: ធី: ធាតុ ចូលរួម ក្រ ជ្រះប រលាយ ។ អបីត
គុ. ដែលស្រូបចូល ។

អបីឌា ស្ត្រី. អបីឌា កិរិយាមិនធ្វើឱ្យខុស ។ អបីឌិត
គុ. ដែលគេមិនយាយី ។

អបីត គុ. ដែលមិនផឹក ។

អបីតិ ស្ត្រី. អបីតិ កិរិយារលាយ ។

អបុំគ្គលីយ គុ. ដែលមិនមែនជាកូននៃស្ត្រីពេស្យា ។

អបុំស បុំ. កិរិយាក្រៀវ ។ —ក្លី នបុំ. ការនៃកិរិយា
ក្រៀវ ។

អបុណ្យ គុ. អបុណ្យ ដែលឥតបុណ្យ ដែលមិនបរិសុទ្ធ។

។ – វិឌ្ឍ គុ. ដែលមិនមានបុណ្យ ។

– ប្បតិ គុ. ដែលមិនធ្វើបុណ្យ ដែលមិន

ធ្វើល្អ ។ –ភាជិ ឬ –ភិល គុ. ដែល

រងទុក្ខ ។

អបុត្រ | បុំ. | កិរិយាមិនមានកូន ។ គុ. ដែលឥតកូន ។

ក– គុ. ដែលឥតកូន ។

អបុនវុត្ត | គុ. | ដែលមិនពោលទៀត

អបុនវុត្មីលន | គុ. | ដែលមិនបើកភ្នែកទៀត ។

អបុនរាវតិន | គុ. | ដែលមិនត្រឡប់មកទៀត។ – ភាវិន គុ.

ដែលមិនមានភពទៀត ។

អបុនរាវ្ឫតិ | ស្ត្រី | កិរិយាមិនត្រឡប់មកទៀត ។ –ភាវិ ប៉ុ.

អបុនភព កិរិយាមិនកើត កិរិយារួច

ស្រឡះ ។

អបុនម៌្ឫត | ឥប៉ុ. | កិរិយាមិនស្លាប់ទៀត ។

អបុប្កល | គុ. | ដែលមិនច្រើន ដែលទទេ ដែលមិនសម្រេច

អ្វីសោះ ។

អបុប្ផ — គុ. ដែលឥតផ្កា ។ អបុប្ផិត គុ. ដែលមិនបុិចផ្កា ។

អបូជិត — គុ. ដែលមិនបូជា ។

អបូត — គុ. ដែលមិនស្អាត ដែលមិនបរិសុទ្ធ ។

អបូប — បុំ. នំ ។ ប្រហោះសម្បកឃ្មុំ ។ អបូក បុំ. អបូបិកា ស្រ្តី នំ – គាលា ស្រ្តី. សាលលក់នំ អបូបសាលា ។

អបូរ — គុ. សម្រេក ដែលទប់មិនបាន ។ – ស៍ គុ. ធ្លូបគ្លា ។

អបូរណ — គុ. ដែលមិនចេះឆ្អែត ។ ដែលខ្វះខាត ។

អបូរណ៍ — គុ. ដែលមិនពេញ ។

អបូតិ — ស្រ្តី. កិរិយាមិនពេញបំណង ។

អបវ៌ — គុ. ដែលមិនមានពីដើម ថ្មី ដែលប្រៀបមិនបាន។ បុំ. អ្នកថ្មី ។ –តា ស្រ្តី. -ត្វា នបុំ. ដែលប្លែក អបូវ្វិកាព ភាពជារបស់ថ្មី ។ - ទស្សិន ដែលនាប្ចូវទស្សន៍ ។

អប្បវិត្ត គុ. អប្បវិទ្ធ ដែលមិនទាន់ធ្វើ ។ ដែលមិនទាន់រៀបការ ។

អប្បដិក្កិត្ត គុ. ដែលមិនព្រមព្រាសចាក ។

អប្បដិគាគ្រយ គុ. ដែលមិនមានទីអាស្រ័យដទៃជាង ដែលមិនមានទីពឹងដទៃជាង ។

អប្បដិគ្គគន គុ. ដែលមិនឃើញផ្សេង ។

អប្បដិគ្គត គុ. ដែលមិនកើតផ្សេង ។

អប្បដិឃាត្តជ គុ. ដែលមិនមានអង្គុំ ។

អប្បុច្ឆ គុ. ដែលគេមិនបានសួរ ។

អបេៈ តិៈ ធាគុ. ចេញចាត់ ។ អបេត គុ. ដែលទៅ ដែលទៅបាត់ ។ អបេតប្រាណ គុ. អបេតប្រាណ ដែលមានប្រាណចេញទៅហើយ ដែលស្លាប់ ។ អបេតភី គុ. ដែលមានភ័យកន្លងទៅហើយ ដែលឥតភ័យ ។ អបេតាគ គុ. ដែលមានបំណងទៅប្រាសហើយ ដែលមិនមានក្តីសង្ស័យ ។

# ល្បងសិក្សា

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

ដោយ លាង ហាប់អាន

សាស្ត្រាចារ្យ ទាយកក្នុងសាសនបណ្ឌិត្យ

(ស្រង់ពីមេរៀនវិទ្យាស្ថានអប់រំខាងអក្សរសាស្ត្រ)

## អក្សរសាស្ត្រខ្មែរ
## ពីសម័យបុរាណ មកសម័យបច្ចុប្បន្ន

[ក]

– ផ្នែកខាងត្បូងហៅ Groupe sud (S) សរសេរជាភាសាសំស្ក្រឹត ក្នុងសម័យសតវត្សទី ៧ នៃគ.ស. ដែលគេរកឃើញនៅនឹងមេបញ្ជរនៃបន្ទប់ ៦ កន្លែង នៅនាទ្វារទិសខាងកើតនៃកំពែងខាងក្រៅ (គឺសិលាចារឹករបស់ព្រះបាទឥសានវរ្ម័នទី ១) ហើយនិងនៅមេបញ្ជរទិសខាងត្បូងនៃទ្វារកំពែងក្រៅផ្នែកខាងលិច ។

– ផ្នែកខាងជើងហៅ Groupe Nord (N.) ដែលសរសេរជាសំស្ក្រឹតផង ខ្មែរផង (ដូចជាសិលាចារឹករបស់ព្រះបាទឥសានវរ្ម័នទី ១ នៅលើមេបញ្ជរនៃទ្វារប្រាសាទខាងជើង) ។

ផ្នែកផ្សេង ៗ នៃសិលាចារឹកសម្បូណ៌ព្រៃគុក បញ្ជាក់ជាដំបូង

កាលក្នុង គ.ស. ១៨៨៤ ដោយលោក Adhémar Leclère ។ នៅ គ.ស. ១៩០០ លោក L. de Lajonquière, បានរកឃើញខ្លះ ហើយលោក G. Morand រកឃើញគ្រប់ពេញលេញនៅ គ.ស ១៩៤០ ។ លោក H. Parmantier បានយកសិលាចារឹកទាំងនេះមកសិក្សាតាមផ្នែកម៉ត់ចត់ នៅឆ្នាំ ១៩១១ ទំរាំ ១៩២៩ ។ ជាបញ្ចប់គឺ លោក V. Goloubew ដែលស្រាវជ្រាវបន្ថែមដល់ ១៧ សិលាចារឹកនៅឆ្នាំ ១៩២៧ ។

## ទី២– សិលាចារឹកនៅភូមិខាវរាំង(១)

### ក) សេចក្តីសង្ខេប. –

សិលាចារឹកនេះនៅក្នុងក្រុមសិលាចារឹកនៅលើភ្នំនៃដំបន់អរញ្ញ ។ ភ្នំនេះមានបីគឺឈ្មោះខាវរាំង Khâu Rang, ខាវណូយ Khâu Nôi, និងខាវចម្ពូ Khâu C'-omp'u ឋិតនៅដែនសៀម ត្រង់តម្បន់ព្រំប្រទល់អរញ្ញ ។ គេដឹងអំពីសិលាចារឹកនេះ ដោយសារឃើញសំណាកដែលផ្តិតទុកនៅនាបណ្ណាល័យជាតិនៅក្រុងបាងកក ។

#### ១) លក្ខណៈ. –

សិលាចារឹកនៅខាវជម្ពូ ប្រើការពុំបានទេ ។ គេគ្រាន់តែដឹងថា

(១) ស្រង់ពី Inscription du Cambodge, G. Cœdès. vol, V ពីទំព័រ ២៣ ដល់ ២៤ ។

អត្ថបទសិលាចារឹកនេះសរសេរជាសំស្ក្រឹត មានចំនួន ២៨ បន្ទាត់ ។

សិលាចារឹកនៅខាងត្បូងមាន ៩ បន្ទាត់ សរសេរជាសំស្ក្រឹត ហើយ ២៦ បន្ទាត់សរសេរជាខ្មែរ ។ អ្នកនិពន្ធសិលាចារឹកនោះនាម ម្រតាញខ្ញាញជេស្ឋបុរៈ ដែលបានធ្វើពិធីបូជាចំពោះសមរេស្វរៈ ក្នុង គ.ស.· ៦៣៧ ។

ឯសិលាចារឹកនៅខាងកំពង់វិញ គឺសរសេរលើថ្មតូច មានទទឹងប្រមាណជាបីតឹក ។ សិលាចារឹកនេះសរសេរជាសំស្ក្រឹត ចំនួន១ស្លោក មាន២បន្ទាត់ បញ្ជាក់អំពីឆ្នាំកត់ត្រា គឺមហាសករាជ៥៦១ឬគ.ស៦៣៩ ។ ឯ ២៩ បន្ទាត់សរសេរជាខ្មែរ គឺគេរៀបរាប់អំពីអំណោយផ្សេងៗ របស់ឈ្មោះសិនាហ្វេរ ទៅឲ្យព្រះវិហារ ។ គឺជាសិលាចារឹកនិយាយពីកំណើតពុទ្ធសាសនា ។

គ- អត្ថបទ.–

១- ឥសត្រយោគសមនេ ក្រិស្ណចន្ទ្ររសេន្ទ្រិយេស៊ែ,

២- ភ៊ុក្តេ សកបតេរ អគ្នេ ហស្តេន វ្ឫសគោទយស៊ែ ។

៣- ខ្ញុំអំណោយ សិនាហ្វ ប្រគត កាយ (៤) ត វិហារ ដ្លហ គេ រ៉ សិរ កន្ត្ត ៥) កុ យោង គោន កុ លាង សិ រ៉ បារ (៦) កន្ត្ត រ៉ កុ សោល គោន កុ លាង តៃ (៧) វរណោហ កុ ចិហ រ៉ ជោងកន្ត្ត (៨) រ៉ កុ មាស កុច

កោន កុ ទេរ តៃលា(៩) ង តៃ ប៉ៅ តៃ កុ ស្រ លាញ កោន កុ លាង តៃ ប៉ៅ តៃ ចំ ទ ក ក់ ថរក់(១១) ទិន ក់ ធមិ មលាក ទំរីងអាយ (១២) ស្តោន ស្វា គ គុំ ១០០-៥ គោង ត្នើ ២០ ប៉ុំ (១៣) គុំ ក់ មេន កន្ថៃ ក់ កុ ល ហ កោន កុ លា (១៤) ង សី ប៉ៅ សី ទំរិង អាយ ញិង វិហារ(១៥) ស្វា គ គុំ ត្នើ ១០០.២០៣ គោង ត្នើ ១០០.២០. ប៉ុំ (១៦) គុំ ក់ ក្តោក ស្វរ វិបិណ្ឌ សក់លវ៑ (១៧) ទ្វ ខ្ញុំ ជោង ក្រោង ប៉ុំ ទំរិង ២០ ១០-២ (១៨) គួង វិហារ គួស សំរិត ៤ ថាស ២ (១៩) ស្រ គេល ២០) បល្ដិតស្ដោងតំប៉ោ(២០) ណាចន្ទក ឧលទ្វ ដ្វីយៅ ៧ កំក់រ (២១) យៅ៧ កាបដ ដ្វីយៅ២០-ពក្យេច (២២) យោ ១០-២ កំក់រយោ ១០ប្អូងត្រិធា (២៣ វ្ទ ប៊ិ ..អាយ បរ កុស(២៤) ស្រែទកន្ទហតិ....ប្រប៊ិត្នើ(២៥) ៥ ប៉ោញ រុ...(២៦) ខ្ញុំអំណោយសិនាហ្វអញ ឯ ត វិហា (២៧) រ.. កន្ថៃ ក់ កុធន កោន (២៨)...លាង សីប៉ៅតៃ ថា (២៩)... ទំរិង១ស្វា ត្នើ (៣០)... ត្នើ គុំ ១០គុំសំ(៣១)....

## ឃ- សេចក្ដីប្រែ.–

(១-២-) នៅក្នុងឆ្នាំនៃព្រះពជាសកៈកន្ទង់ផុតទៅ ដែលមាន បញ្ចាក់តាម(៥)អាយតនានាមាន(៦) សេនិងព្រះច័ន្ទ នាថ្ងៃ១៣កេច នៃឥសៈ(អាស៊ិន)ព្រះច័ន្ទ ឋិតនៅក្នុង ហស្តច្រង់គោចរឡើងលើ ឧសក មណ្ឌល ៗ (៣.១១) ពពួកទាសទាំងឡាយដែល សិនាហ្វ ផ្ដល់ពីមុនទៅ

ឲ្យវិហារ ។ (កយបញ្ជីឈ្មោះទាសៈទាំងនេះ) ។ (១១-១៤) ការ ដាំដំណាំនៅគ្មានគឺដើមស្លា១០៩, ដើមដូង២០ ។ កប់ឈ្មោះឆ្នាំ(តាមបញ្ជី) ។

(១៤-១៦) ដំណាំនៅជិតវិហារគឺដើមស្លា ២៣ដើម ដូង១២០ កយឈ្មោះឆ្នាំក់ក្អែក ។

(១៦-១៧) រួមសារុបពួកទាសៈចាស់និងក្មេង ព្រមទាំងឆ្នាំគេក្រដំណាំ មានចំនួន៣២ ។

(១៨-១៩) ឃ្លាំងទ្រព្យធននៅលើវិហាគឺៈ ក្អម ញើពីសំរិទ្ធ ៤, ថាស ២, ស្រគេហ២០, ក្រែ១... ។

(២៣-២៤)–នៅបរ កុ ស្រែទក់ល ..គោ៥ទីម ។

ពោញរ៉ូ ។

(២៦-៣១)--ទាសៈដែលខ្ញុំឈ្មោះ សិក់ហ្វ វេរថ្វាយទៅព្រះវិហារ (កប់ចំនួនអំណោយ) ។ ដំណាំ....ដើមស្លា. .ឈើ១០ដើម...ទៅព្រះវិហារ រុណ ។

ង- អត្ថន័យទូទៅៈ-

សិលាចារឹកនេះនិយាយពីឧបាសកម្នាក់ឈ្មោះជាសិនាហ្វ បាន សាងព្រះវិហារមួយឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ព្រមទាំងថ្វាយទ្រព្យ

សម្រាប់ព្រះវិហារមានទាសាក្មេងចាស់ ចំនួន៣២នាក់កប់តាំងឆ្នាំចំការ ដូងស្លាផង ។

គឺតាមរយៈសិលាចារឹកនេះ ដែលយើងដឹងនូវអរិយធម៌ខ្មែរ ព្រមទាំងនយោបាយកសិកម្ម ក្នុងសម័យសតវត្សទី៧នៃ គ.ស ។

ទី៣ សិលាចារឹករជ្ជកាលព្រះបាទជ័យវរ្ម័នទី ១

សិលាចារឹកនៅក្នុងខេត្តព្រៃវែងនេះមាន ២ គឺ៖

## ១- សិលាចារឹកនៅវត្តព្រៃវៀរ.–

នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង: ក្នុងព.ស. ១២០៦, គ.ស.៦៦៤)(១)

### ក) លក្ខណៈ.–

ជាសិលាចារឹកសរសេរលើផ្ទាំងថ្មភក់មានកំពស់ ០ម៧២, ទទឹង ០ម៣៥, ក្នុង ម.ស. ៥៨៦ គ.ស. ៦៦៤ ។

ទាំងអស់មាន ១៧ បន្ទាត់គឺ ១០ បន្ទាត់ជាភាសាសំស្ក្រឹត, និង ៧ បន្ទាត់ជាភាសាខ្មែរ ។ អក្សរសរសេរស្អាតល្អណាស់ មានលំនាំគ្នានឹងអក្សរសម័យ គ្រិស្ត សតវត្សទី ១១ ។

### ខ) អត្ថបទ.–

(១) មើល Inscription sanskrite du Cambodge par M.A. Barth, fascicule I ទំព័រ ៦០ តទៅ ។

១)– ធិតំ ឧរុដ្ឋៈសោវេណា កជ្ជា ស្រីជយវរ្ម្ណា តាបលាបិ សតី យត្រ ស្តិក លល្ម៊ី . . . ។

២- កូយិស្តទ្រិស្តិវេយោ ជតទ្រក្សណាទិក្សីណ៍សសាក្សាក សហ-ស្រាក្ស ឥតិ ប្រាជ្យក៏កិ . . . ។

៣- វក្សត៏ស តស្យ ប្រិថិវី ប្រិថុវិក្រមឧទិដ្ឋំ កវេ្យ កិក្សវ-វិស្តៅ ស្ត៏ស សោទវេ ស្តិរ . . . ។(២)

## ក) សេចក្តីប្រែ.

១– ព្រះបាទស្រី ជយវរ្ម័ន ដ៏មានតេជាគ មានវីរិយភាពយ៉ាងមហិមា ទ្រង់បិតនៅជិតព្រះលក្ស្មី ទ្រង់គង់នៅគ្មានករម្រើក ។

២– ទ្រង់មានព្រះនេត្រទតវែងឆ្ងាយ . . . មានព្រះបញ្ញាវាងវៃក្នុងកិច្ចការពារលោក ហើយទ្រង់ត្រូវបានអ្នកប្រាជ្ញសហស្រាស្ត្រលើកដំកើងឡើង ។

៣- ក្នុងពេលដែលទ្រង់គ្រប់គ្រងទឹកដីបានមកពីការវាតទីដ៏វែងឆ្ងាយ ក្នុងខណៈនោះមានព្រះភិក្ខុដ៏ជំនាញ ២ អង្គគង់នៅក្នុងព្រះរាជាណាចក្រព្រះអង្គ ។ ភិក្ខុនេះមានព្រះមាតាវួមឧទរ, ម៉ុងម៉ាត់ក្នុង . . . ។

៤– ទាំងពីរព្រះអង្គប្រកបដោយគុណធម៌ទ្រង់សីល មានចំណេះវិជ្ជា សភាពស្ងប់ស្ងៀម សេចក្តីអំណត់អត់ធន់ មានខ្លួនទូន្មានហើយ

(២) មានតទៅទៀត តែខ្ញុំមិនយកមកកត់ត្រាទាំងអស់ទេ ដើម្បីកុំឲ្យមេរៀនវែងពេក ។

មានករុណា  សមាធិប្រុងប្រយ័ត្នជានិច្ច  ហើយព្រះអង្គមានព្រះគោត្រជាគេ្គ  ដែលនាមបុនប្រាកដទាំងពីរ គឺមួយអង្គនាម ភាណុ ហើយមួយអង្គ-ទៀតនាម សិទ្ធ  ។

៥- បុត្រនៃកូនស្រីដែលជាបងនៃភិក្ខុទាំង ២ រូបនេះមានព្រះកិត្តិនាមខ្ពស់ គឺព្រះវិសុទ្ធ សុកិត្តិ  ដែលមានព្រះសកម្មភាពយ៉ាងបរិសុទ្ធ  ។

៦– តាមការគ្រប់គ្រងជាហូរហែ  នៃព្រះញាតិវង្សមក  ហើយតាមព្រះបញ្ញារបស់ព្រះមហាក្សត្រ   ព្រះរាជបត្រនេះត្រូវបានទទួលពេញបន្ទុកនូវអ្វីទាំងអស់  ដែលព្រះអង្គមានបុព្វសិទ្ធិទីងទទួលពេញសមត្ថភាព  ។

៧- មានសត្វខ្មៅបាទ , បតុបាទ , សួនឧទ្យាន , ដីធ្លី , ព្រៃព្រឹក្សា , ចំការក្ញី  ហើយទីងអស់ទាំងអ្វីដែលឋិតនៅក្នុងព្រះរាជអាណាចក្រ ត្រូវបានមកទ្រង់  ហើយគ្មាននរណាដទៃម្នាក់អាចមកទាមទារបានទេ  ។ នេះគឺជាព្រះរាជបណ្តាំ  និងព្រះរាជបញ្ញារបស់ព្រះមហាក្សត្រ  ។

៨- សេចក្តីនេះសម្រេចឋិតនៅក្នុងសម័យព្រះចៅនៃសក:  ដែលទ្រង់បានទទួលហើយនូវរស: , នូវវសុ និងវត្ថុ របស់អាយតន: , ជាថ្ងៃទី ២ កើត ខែមាឃ  ។ ព្រះរាជបញ្ញានេះប្រគល់ទៅព្រះសង្ឃដែលគង់នៅក្នុងធានីរបស់ព្រះមហាក្សត្រ  ។  គឺសេចក្តីនេះកប់បានថាជា  ព្រះរាជកម្រិះរបស់ព្រះមហាក្សត្រព្រះអង្គឯងប្រកបដោយព្រះវិចារណត្រូវ . . . ។

## ឃ) អត្ថន័យទូទៅ–.

តាមន័យនៃសេចក្ដីរបស់សិលាចារឹកនេះ យើងដឹងថា ក្នុងត្រិស្ត-សតវត្សទី ៧ មានភិក្ខុ ២ អង្គជាបងប្អូនបង្កើត ជាជាតិក្សត្រដែលបានបព្វជា ហើយទ្រង់គង់នៅក្នុងវត្តព្រៃវៀរនេះ សឹងមានសេចក្ដីសម្រួលបន្ថែមថា :(១)

"ក្នុងដែនដីដែលទ្រង់គ្រប់គ្រងនេះ មានភិក្ខុពីរអង្គជាបងប្អូនបង្កើតទាំងពីរអង្គ មានសីលជាពហុស្សុត្រ សុភាព មានខន្តី មានខ្ជួនខ្ជានហើយមានករុណា មានសមាធិចិត្តជាឥរិយទ្រព្យ មាននាមខាងដើមថា រត : ដូចគ្នា ហើយខាងចុងមួយជាកាណ្ឌ មួយទៀតជាសិង្ហ: គឺភិក្ខុរតនកាណ្ឌ ១ ភិក្ខុរតនសិង្ហ ១" ។

តាមសិលាចារឹកនេះទៀត យើងឃើញថា សម័យនោះពុទ្ធសាសនាចំរើន មានភិក្ខុសង្ឃកាន់ក្រិត្យវិន័យ មានសមត្ថភាពបរិបូណ៌ ។ ទាំងបុត្រព្រះមហាក្សត្រ ក៏ចូលបួសក្នុងសាសនា ហើយព្រះរាជាមានព្រះសទ្ធាណាស់ក្នុងកិច្ចទំនុកបំរុងវត្តអារាមសមណព្រាហ្មណ៍ ។ ភោគផលខាងសម្បត្តិទ្រព្យធន ក៏បរិបូណ៌ឥតខ្ចោះ មានតាំងពីគ្រឿងប្រើប្រាស ផលដំណាំដាំដុះនិងសត្វពាហនៈផង ។

---

(១) តាមសេចក្ដីប្រែសំរួលរបស់ព្រះតេជព្រះគុណ ហ៊ាង ខាត់ ក្នុងសៀវភៅព្រះពុទ្ធសាសនា ២៥០០ ទំព័រ ៥៩ ។

## ២ · សិលាចារឹកនៅវត្តប្រាសាទ ..

(នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង) (១)

### ក) លក្ខណៈ

ជាសិលាចារឹកសរសេរលើផ្ទាំងថ្មសំប៉ែតមានសណ្ឋានកងដូចជាទេវរូបនៃព្រះវិស្ណុក្បៀស មានត្រឹមតែកងកាយមួយប៉ុណ្ណោះ ។ គ្មាននាមព្រះមហាក្សត្រទេក្នុងសេចក្តីនៃសិលាចារឹកនេះ ។ តែបើតាមថ្ងៃខែដែលបញ្ជាក់ (គឺក្រោយសិលាចារឹកមុន ៦ ថ្ងៃនោះ) ពិតជាសិលាចារឹកនេះឋិតក្នុងរជ្ជកាលព្រះបាទជយវរ្ម័ន ។ សកករាជប្រាកដនោះ គឺឆ្នាំ ៥៨៩ នៃសកៈឬគ.ស. ៦៦៧ ។

អក្សរមានលំនាំដូចគ្នា ទឹងសម័យទី ៦ ឬ ទី ៧ នៃគ.ស. ។

ទំហំសិលាចារឹកនេះមានកំពស់ ០ម០៨, ទទឹង ០ម៧៤ ។

### ១) អត្ថបទ –.

– នៅខាងស្តាំសិលាចារឹក មានពាក្យដាច់ ៗ គ្នាដូចតទៅ៖

. . យា . . . . .

. . . ន៌ . . . . .

. . . . ន . . . .

---

(១) មើល Inscriptions sanskrites du Cambodge, par M. A. Barth, Ier fascicule ទំព័រ ៣៣ តទៅ ។

# រឿង ចៅគែលលក

សហ. ព្រួច-កុម

រៀបរៀងតាមការនិទានតៗមក

[ក]

ស្ការដែរថា «ខ្ញុំជាស្ដេចពស់ អាចការពារខ្លួនជាមនុស្សជាសត្វ ឬអ្វីក៏បាន សូមលោកអត់ទោស លែងខ្ញុំឲ្យបានរួចជីវិតចុះ បើកាលណាលោកមានទុក្ខធុរៈ គ្រាន់តែនឹកដើមទៅដល់ខ្ញុំ ៗ នឹងមកជួយភ្លាម» , ខ្មោចតូច ខ្សឹបប្រាប់ ថា ឲ្យលែងតាមពាក្យអង្វររបស់ពស់ ទើបវាលែង ហើយនាំគ្នាត្រឡប់មកចំការវិញ ។

លុះដល់ពេលយប់នៃថ្ងៃនេះ នៅពេលអធ្រាត្រស្ងាត់ ខ្យល់ដំនោរបក់រំភើយ ៗ បណ្ដាលឲ្យក្លិនបង្ហើមស្រូវ ផ្សាយទៅពាសពេញទីព្រៃ ពេលក្លិនទៅដល់ស្ដេចដំរីសមួយ ដែលចាស់ជរាណាស់ហើយ ៗ ស្ដេចដំរីសនោះ មានក្លុកម្ខាងទកធំថ្លែក ប៉ុនការុងស្រូវ ៗ នៅក្នុងក្លុកនោះ មានកូនក្រមុំមួយ មានរូបឆោមលោមព័ណ៌សមរម្យស្អាតល្អណាស់ មានកេទជាមនុស្សពិត ៗ ឈ្មោះ នាងពួន មិនដែលចេញខ្លួនឲ្យអ្នកណាឃើញទេ បើប្រសិនជាអ្នកផងបានឃើញៈហើយ នឹងអត់ទ្រាំស្រឡាញ់មិនកើត នាងបានជាទីបេតីនៃស្ដេចដំរីជាឪពុកណាស់ ៗ ស្ដេចដំរីសធុំក្លិនស្រូវដ៏គួរឲ្យឆ្ងាញ់ ក៏ដើរស្រង់ក្លិនកាត់រក ដោយចំណង់ចង់ស៊ីស្រូវខ្លាំង

ណាស់ ស្រេកទឹកមាត់, ដើរដកបមកដល់ បានប្រទះនឹងចំការស្រូវទៅ តែលលក, មុននឹងចូលស៊ីស្រូវ បានពិចារណាផញ្ចឹងរំពឹងគិតថា ខ្លួនអញ្ចជាស្ដេច ធ្លាប់មានខន្តីរក្សាសុចរិតកត់តែដែលល្មៀង ជារៀងដកបមកយូរយារ មិនដែលហ៊ានបំផ្លិចបំផ្លាញប្រវ័ញ្ចកាញ់គេរបស់ទ្រព្យអ្នកណាមួយឡើយ, រីឯចំការស្រូវនេះ ពិតជាមានម្ចាស់គេនៅចាំរក្សា បើអញចូលស៊ីរបស់គេ នឹងមានកម្មពៀរវេរា ខូចខន្តិសីលធម៌, តែធ្វើម្ដងទៅអេះ បើពេលនេះ អញឃ្លានចង់ស៊ីណាស់ ស្រេកទឹកមាត់ទឹកកទៅហើយ, ល្អើយប្រថុយចូលស៊ីសិនចុះ បើម្ចាស់គេមករករៀង សឹមអញឲ្យកូនក្រមុំរបស់អញទៅគេ ជូរជាថ្នូរមួយចំអែតបានហើយ ។ គិតស្រេច ក៏បែរស្រដីនឹងនាងពួនជាកូនខ្លួនដែលនៅកន្ទុកថា នែកូនស្រីឪពុក ! ឪពុកចាស់ណាស់ហើយ នឹងមិនបាននៅយូរប៉ុន្មានថែរក្សាកូនសួនសំឡាញ់ទេ, វេលានេះ ឪពុកឃ្លាន ហានបំណងចង់ស៊ីស្រូវនេះណាស់, ហេតុនេះ ឪពុកនឹងចូលទៅក្នុងចំការស៊ីស្រូវនេះឥឡូវ, តែដោយឪពុកធ្លាប់រក្សាសុចរិតជារៀងមកហើយ ក៏យល់ថា នឹងលើកកូនឲ្យទៅអ្នកម្ចាស់ចំការ សុំគេជូរជាថ្នូរមួយចំអែត ហើយសុំគេនោះជាកូនប្រសាផង តើកូនយល់ស្របដែរឬ? នាងពួនឆ្លើយថា តាមតែបំណងលោកឪពុកចុះ ។ កាលបើដូច្នោះហើយ ស្ដេចដំរីសនិយាយផ្ដាំកូនស្រីរបស់ខ្លួនថា « បើកូនស្រីបានទៅនៅនឹងគេហើយ ចូរនាងប្រយ័ត្នខ្លួន

ឲ្យមែនទែន គាត់យកចិត្តទុកដាក់បម្រើបម្រាស់ប្ដីកុំបីមានធ្វេសប្រហែស ឡើយ, តែនាទីនេះ ឪពុកត្រូវផ្ដាំទុកឲ្យហើយថា ចាប់ពីថ្ងៃនេះទៅ នៅ ប្រាំពីរថ្ងៃទៀត ទើបត្រូវចេញមកនៅរួមវេណី ជាមួយនឹងប្ដីនាងបាន, បើពុំដូច្នោះទេ នឹងមានគ្រោះថ្នាក់ធំណាស់, ប៉ុន្តែបើកូនចង់ចេញមក ខាងក្រៅណាស់នឹងទ្រាំពុំបាន ត្រូវរង់មើល បើគេចេញៈទៅណាបាត់ សឹមលបចេញមកមួយភ្លែត ៗ ចុះ តែកុំឲ្យយូរពេក ត្រូវប្រញាប់ពួន វិញ កុំឲ្យគេឃើញ ។ ផ្ដាំកូនសព្វគ្រប់ហើយ ទើបស្ដេចដំរីសចូល ទៅបោចស្រូវស៊ីអស់ជាច្រើន, ឆ្អែតហើយ មិនទាន់ចេញៈទៅទេ នៅ ឈរពួនក្នុងចំការគន់មើលម្ចាស់គេ ។

ព្រឹកឡើងហើយ ចៅកែលលក ក្រោកពីដំណេក ចេញដើរទៅ មើលចំការ ដូចសព្វកាលរៀងមក បានឃើញដំរីឈរស្ងុកកណ្ដាលចំការ នឹកខ្លាចខ្លាំងណាស់ មិនហ៊ានចូលទៅដេញចេញទេ ក៏រត់ទៅឡើងដើម ឈើមួយដើម ក្រឡេកមើលទៅ ឃើញស្រូវខូចខ្ទីអស់ជាច្រើន ប្រឹងតែ ចំគោងស្រែកបង្អើល ស្រែកហើយស្រែកទៀត បំណងឲ្យដំរីចេញទៅ, ប៉ុន្តែជាការឥតអំពើ ដំរីឥតដើរចេញសោះ នៅតែឈរធ្វើព្រើះៗ បក់ស្លឹក ត្រចៀកឃ្លុបៗ ហើយដើរទៅជិតគល់ឈើដែលតាឡើង លើកប្រមោយ ត្រកងឡើងបក់ហៅថា “អាកូម! កូនអើយ កូន! ចុះមកឲ្យពាប់ កុំខ្លាច” ។ ចៅកែលលកឆ្លើយថា ទេលោកអើយ កុំធ្វើបាបខ្ញុំ ស៊ីស្រូវអស់ជាច្រើន

មានកម្លាំងហើយ ម្តេចក៏ចង់មករករឿងព្រៃខ្ញុំទៀត ចេញឲ្យឆាប់ទៅ ខ្លាចណាស់ ៗ ដំរីសបេះតែទទូចហៅឲ្យចុះ តែវាមិនហ៊ានចុះមកសោះ ទើបដំរីកាច់កូកទទកហុចឲ្យទៅ ៗ មាណពក្មេងឃើញប្លែកផ្លូវពោះ បាត់ខ្លាចបន្តិច សម្រូតចុះមកទាំងញ័រជើងតគ្រុត តែដល់ឮសំដីដំរីនិយាយថា កុំខ្លាចៗ កុំខឹង ហឹយកទៅ! ហើយផ្តាំបន្ថែមថា យកទៅទុកឲ្យស្រួល ដាក់នៅកន្ទួងដេក របស់នេះថ្លៃណាស់ សំខាន់ណាស់ ចូររក្សាទុកឲ្យគង់ កុំឲ្យបាត់ នៅ ៧ ថ្ងៃទៀត នឹងឃើញស័ក្តិសិទ្ធិ, បើថ្ងៃមុខមានទុក្ខធុរៈអ្វី ឲ្យនឹកទៅឪពុកខ្លាម ឪពុកនឹងមកជួយ ឪពុកលាសិនហើយ, ថាហើយ ក៏ដើរចូលព្រៃបាត់ទៅ ៗ ចៅកែវលក យកកូកនោះទៅគ្របបិទបាំង យ៉ាងស្រួលទុកនៅកន្ទួងដំណេកក្នុងខ្ទម ដោយនឹកសប្បាយចិត្តលែងស្តាយស្រូវដែលខូច ហើយបន្តការងារជាធម្មតាទៅទៀត ៗ

និយាយពីនាងពួន ដែលចៅកែវលកយកមកទុកថែរក្សានោះ, នាងនៅចាំមិនភ្លេចទេ សំដីដែលស្តេចដំរីជាឪពុកផ្តាំទាំងប៉ុន្មាន ក៏ខំទ្រាំនៅក្នុងកូកបានតែត្រឹម ៣ ថ្ងៃ លុះសន្តែតទៅឃើញចៅមាណពដែលមានសេចក្តីស្រឡាញ់កូកណាស់ មិនដែលហ៊ានទៅណាពេលយូរ មិនដែលដាក់ឆ្ងាយពីទីដំណេក តែងដេកឱបកូកពេលរាត្រី ពេលចេញទៅណា តែងគ្របបិទបាំងលាក់ទុកដូចបណ្តាំឪពុកខ្លួនប្រាប់ មិនដែលភ្លេសមួយវេលា, ទាំងបានឃើញចៅមាណពតែលកធ្វើការតែដោយផ្ទាល់ដៃឯង ចេញទៅថែ

ចំការផង ដងទឹកពុះឧស ដាំបាយ ទៅព្រែករបស់ផ្សេងៗផងដូច្នោះ នាងទឹកខ្មៅបិត្តអាណិតពេក ៗ ពេលព្រឹកថ្ងៃទី ៣ នោះ កាលដែលគេចេញទៅចំការបាត់ហើយ នាងកាត់ចិត្តប្រថុយចេញមកខាងក្រៅ បោសប្រាសសំអាតខ្ទម រៀបតាក់តែងចំណីអាហារ ទុកដាក់អីវ៉ាន់ផ្សេង ៗ រួចស្រេច ទើបចូលទៅពួនក្នុងក្អមវិញ, នាងបន់ឲ្យតែបានគ្រប់ ៧ ថ្ងៃ នឹងបានចេញមកជួយធ្វើកិច្ចការផ្សេងៗ ឲ្យបានពេញដៃតទៅ ។

លុះដល់ពេលដែលចៅ កែលលក ត្រឡប់មកពីចំការវិញ បានឃើញការចម្លែក ក៏អង្គុយពិចារណាថា ចុះនរណាអេះ មកតុបតែងផ្ទះ មើលទៅឃើញស្អាតប្លែកតាំងអស់ បើកគម្របស្លឹកឈើមើលឃើញអាហារចំណីប្លែក ៗ ធុំក្លិនឈ្ងុយឆ្ងាញ់គួរឲ្យស្រក់ទឹកមាត់ គិតថាពោះជាដូចម្តេចក៏ដោយ ស៊ីសិនហើយអញ ! ក៏ស៊ីឆាបដល់ឆ្អែត ឃើញថាឆ្ងាញ់ឥតសាស្ត្រមែន ៗ ស្អែក ខានស្អែកឡើង ឃើញដូច្នោះទៀត, សេចក្តីសង្ស័យក៏កាន់តែមានខ្លាំងឡើង, ចៅ កែលលក មានគំនិតមួយប្លែកកើតឡើងថា ព្រឹកស្អែកនេះ ជាព្រឹកទី ៤ អញគិតចេញទៅចំ-ការ គ្រាន់តែពេលដើងបន្តិច ត្រឡប់មកចាំឃ្លាំមើលវិញឲ្យដឹងការណ៍, លុះដល់ព្រឹកស្អែកនោះ ក៏ធ្វើជាចេញទៅបានមួយស្របក់ គ្រាន់តែឲ្យអស់សង្ស័យ ហើយលបវារតាមផ្លូវត្រឡប់មកវិញ មកពួនទៅក្បែរខ្ទមចាំលបមើល ៗ នាងពួន ដឹងថា គេចេញទៅបាត់ហើយ ក៏ចេញក្លួតពីក្អមមក

ហើយរៀបចាត់ចែងកិច្ចការផ្សេង ៗ យ៉ាងប្រញាប់ប្រញាប់ រួចស្រេចក៏ចូលបាត់ទៅក្នុងក្ដុកវិញ ៗ ចៅមាណពកែលលក សង្កេតឃើញនាងដែលល្អរកស្រីឯណាផ្ទឹមពុំបាន មានចិត្តទីកស្រឡាញ់ណាស់ កំណត់ទុកក្នុងចិត្ត ចាំថ្ងៃស្អែកនឹងចាំស្ទាក់ចាប់ឲ្យបាន ៗ ព្រឹកស្អែកឡើងទៀតបុរសចេញទៅចំការ ហើយលបធ្វើតាមរបៀបពីម្សិល, លុះនាងពួនចេញមកធ្វើការ ដឹងថាជិតរួចហើយ ក៏ស្ទុះយ៉ាងប្រញាប់ទៅចាប់ទុចនាងជាប់, នាងស្ទុះចូលក្ដុកមិនទាន់ សូម្បីនាងអង្វរថា សូមបងមេត្តាអាណិតលែងខ្ញុំ ៗ ឥតតែទៅណាទេ, ដែលលោកឪពុកឲ្យមកនេះ គឺឲ្យមកនៅធ្វើជាប្រពន្ធរបស់បងហើយ ឯបងក៏ជាប្ដីខ្ញុំស្រាប់ហើយ ប៉ុន្តែចាំមួយថ្ងៃទៀតសិន ព្រោះឪពុកយើងបានផ្ដាំផ្ដាច់ ថាឲ្យបានគ្រប់ ៧ ថ្ងៃ ទើបចេញមកនៅខាងក្រៅបាន ៗ ទោះបីនាងប្រាប់តាមដំណើរបណ្ដាំម្ដេចម្ដាក៏ឥតអំពើ, បុរសពុំព្រមសុខចិត្តលែងវិញសោះ ចេះតែនិយាយអង្វរនាងថា បងស្រឡាញ់អូនណាស់ បងមិនហ៊ានលែងអូនទេ ក្រែងអូនកុហកបងឲ្យតែរួច ហើយនឹងរត់ទៅចោលបង ៗ នៅពេលដែលយុវជនទាំងពីររូបកំពុងតែប្រទាញប្រទង់ ដដែកគ្នាមិនដាច់ស្រេចនោះ តណ្ហាក៏កម្រើកឡើង បណ្ដាលឲ្យខ្លួននាងពួនរីកធំថ្លែកជាងកាលពីមុន ខកការ នឹងចូលក្នុងក្ដុកវិញ ក៏ចូលលែងចុះហើយ ទើបនាងព្រមព្រៀងនៅរួមរស់សុខទុក្ខតាមបែបលោកិយវិស័យតទៅ ។ ឯខ្មោចតូច ដឹងថា ចៅកែលលក

ជាសម្លាញ់បានប្រពន្ធល្អ ក៏ជួយអរណាស់ ៗ ចាប់ពីថ្ងៃនេះមក ខ្មោចតូច តែងមកលេងខ្ទមចៅតែលលករាល់ថ្ងៃ ជួយមើលការពារសុខទុក្ខផ្សេង ៗ ចាំងប្រាប់ឲ្យទៅយករបស់ខ្លះ ៗ មកទុកប្រើប្រាស់ ព្រោះក្នុងខ្ទមគ្មានអ្វីប្រើសោះ ។

មិនទាន់បានយូរប៉ុន្មាន ជាចៃដន្យ បណ្ដាលហេតុពីខុសត្រណម មិនទាន់ដល់កំណត់តាមបណ្ដាំដំរីសជាឪពុកបានផ្ដាំទុក, ថ្ងៃមួយ ជួនជាមាននាយព្រានព្រៃម្នាក់ ដើរត្រាច់ផ្គាត់រុកតត្រកក្នុងព្រៃ វង្វេងមកដល់បានឃើញខ្ទម ត្រូវស្រេកទឹកផង ក៏ចូលទៅរកទឹកផឹក បានឃើញនាងពួនដែលមានរូបសម្បត្តិល្អឥតខ្ចោះរកទាស់ក្ដែកគ្មាន គិតថា នាងនេះមិនសមជាប្រពន្ធមនុស្សកំព្រាអនាថា នៅក្នុងព្រៃស្រោងស្រឹងត្រមង់ត្រមោចដូច្នេះសោះ, ដំបូងនឹកចង់បានខ្លួនឯង ប៉ុន្តែដល់គិតថា បើទុកជាបានមកខ្លួនក៏មិនស័ក្ដិសមគ្នា តែនឹងត្រូវធ្វើដូចម្ដេចអេះ? ដោយនាយព្រានចង់បានសេចក្ដីគាប់ក៏គិតឃើញភ្លាមថា នាងនេះ សមស័ក្ដិជាព្រះរាជទេពី, ទើបព្រាននោះឈ្លបសួរសព្វហេតុការណ៍ ដឹងស្រេចកាលណា ក៏វិលត្រឡប់ចូលព្រះរាជនគរ នាំយកដំណឹងចម្លែកនោះទៅក្រាបទូលព្រះរាជាម្ចាស់ផែនដីរបស់ខ្លួន, ស្ដេចបានជ្រាបកិច្ចការអាថ៌សេចក្ដី តាមពាក្យព្រានទូល ក៏ជ្រួលព្រះទ័យលៃលករកឧបាយ នឹងផ្លាយយកភរិយាចៅប៉ុរសនោះឲ្យខាងតែបាន នឹងចេញទៅរឹបយកភ្លាមតាំងអំណាចហាក់មិនសម ព្រោះទ្រង់ជាព្រះមហា

ក្សត្រខត្តិយជាតិ ខ្លាចក្រែងមនុស្សទេព្តាឃើញថាវៀតឃ្លាតទសពិធរាជធម៌ ក្រៅក្រិត្យក្សត្រខ្លាំងពេក ទើបលើកជាល្បិចកិច្ចកល, ជាដំបូងបង្អស់ បង្គាប់ ចៅព្រានឲ្យនាំរាជសាសន៍ទៅប្រាប់ចៅបុរសថា “ វៃស្អែកនេះ ឲ្យរកមាន់ យកទៅប្រជល់គ្នាល់គ្នា, បើស្ដេចចាញ់ នឹងផ្ទេររាជ្យឲ្យ, បើចៅគែលលក ចាញ់ នឹងត្រូវរៀបយកកិរិយាខ្លួនថ្វាយស្ដេច, បើខកខានមិនបានមាន់យក មកប្រជល់ ស្ដេចនឹងរឹបអូសយកប្រពន្ធចៅ ដោយប្រើរាជអាជ្ញា ” ។

ចៅគែលលក លុះបានទទួលអាជ្ញាស្ដេច ដឹងហេតុការណ៍ហើយ ក៏ភ័យ ស្លុតរន្ធត់ចិត្តណាស់ គិតថា ពេលនេះ អាសន្នធំដល់ហើយ ក៏ដេកសន្ធឹក សន្ធៃព្រួយចិត្ត មិនដឹងជានឹងគិតទៅរកមាន់ឯណា បានយកទៅប្រជល់, កំពុងតែខ្វល់អត់បាយក្រហាយទឹកដូច្នោះ, ពេលព្រលប់ៗ ខ្មោចតួចមកលេង ឃើញចៅគែលលកស្លុតស្លប់ជ្រប់ស្ងាប់ស្ងៀម ក៏សួរ, បុរសប្រាប់ខ្មោច តួច តាមដំណើរដែលមាន, តួចប្រាប់ថា ការប៉ុណ្ណឹងៗ ទៅភ័យព្រួយថ្វី! ក្រោកឡើងរកថ្លុតទឹកស៊ីបាយឲ្យស្រួលខ្លួនទៅ ចាំយើងប្រាប់ជាក្រោយ ។

ឮដូច្នោះភ្លាម បុរសបានធូរទ្រូងបន្តិច ប៉ុន្តែពុំទាន់ដឹងថានឹងបានចេញឲ្យ រួចពីសេចក្ដីកង្វល់នោះតាមផ្លូវណានៅឡើយទេ ។ រួចបាយហើយ ទើបខ្មោច តួចរំឭកថា ចូរឯងនឹកទៅដល់ស្ដេចស្ការឲ្យមកឥឡូវ, បុរសនឹកឲ្យៈស្ដេចស្ការ មក, ស្ដេចស្ការក៏មកដល់ភ្លាមដូចចិត្ត ហើយសួរបុរសថា “ តើលោកមាន ធុរៈអ្វី? ” បុរសថ្លែងប្រាប់ស្ដេចស្ការ តាមដំណើរហេតុកើតមាននោះ,

ស្តេចស្វាថា សូមកុំព្រួយ ការប៉ុណ្ណេះ ៗ មិនជាអ្វីទេ, ព្រឹកស្អែកនេះប្រឹងប្រៀបខ្លួននឹងទៅចុះមិនពាញ់ស្តេចទេ ខ្ញុំហ៊ានធានាយកសាសាបានតាំងអស់, ថាហើយ ស្វានោះលាចូលព្រៃវិញបាត់ទៅ ។ លុះព្រឹកឡើងហើយ នាងពួន ប្រពន្ធហៅគែលលក រៀបចំឲ្យដំណើរប្តីរង់ចាំស្តេចស្វា, ស្តេចស្វាក៏បានមកដល់ ទើបនាំគ្នាធ្វើដំណើរទៅ, លុះទៅជិតទីងដល់ពដដំណាក់ស្តេចហើយ ស្តេចស្វាកាឡាខ្លួនជាមាន់ឈ្មោលសំគមតូចមួយប្រាប់ឲ្យមាណពយកសំពត់រុំឲ្យជិតបីដើរចូលទៅកន្លែងសែវៀន ៗ ដល់កំណត់ពេលទីងប្រជល់មាន់ហើយ, ព្រះរាជា នាម៉ឺនសព្វមុខមន្ត្រី មួយអន្លើដោយរាជបរិពារ ក៏ចូលកាន់ទីសែវៀនគ្រៀបគ្រា ។ ទ្រង់ត្រាស់សួរទៅហៅមាណពថា "មាន់អ្នកឯងនៅឯណា?" ទើបហៅគែលលកស្រាយសំពត់រុំចេញ យកមាន់ថ្វាយព្រះរាជាទត ។ មាន់នោះ ធ្វើសម្លេងក្រុត ៗ ដើរទ្រេតទ្រោតចង់តែលំ ។ ពួកបរិពារស្តេច ឃើញដូច្នោះ នាំគ្នាហ៊ាកញ្ជ្រៀវទះដៃសើចចំអកឲ្យហៅគែលលកៈនោះថា "វ៉ុយ កះយើង មើលមាន់គេ ចុះមាន់ជល់អីក៏សំគមប៉ចញ៉ចក៊ីបេះ មើលទៅកេសាប់ស៊ីគ្មានទេ! វ៉ុយ មាណពអើយ ឯងកុំចង់ប្រឡងអ្វី វាមិនឈ្នះទេ, មើលទៅនាំតែខាតពេលទេ, វិលទៅយកប្រពន្ធឯងមកទុកឲ្យហើយទៅ វាល្អជាង!" ។ ឯមាន់ស្តេចវិញ, ស្តេចបង្គាប់ពួករក្សាមាន់ឲ្យរើសសម្រាំងសុទ្ធតែមាន់ធំៗ

មាំល្អ ជាមាន់ធ្លាប់ប្រជល់មានជ័យ ឈ្នះគេពជាច្រើនលើកមកហើយ ៗ ពេលនោះ ទ្រង់មានព្រះទ័យសោមនស្សណាស់ ព្រះភ័ក្ត្រញញឹម ដោយទ្រង់យល់ច្បាស់ ជាមុនស្រេចថា នឹងបានឈ្នះមាណព គ្មានសង្ស័យ ទើបទ្រង់ត្រាស់ឲ្យលែងមាន់ចូលសែវៀន ៗ មាន់ព្រះរាជារត់ចូលថ្វា ទទះស្លាបរងាវ បញ្ចេញឫកសង្ហារ អួតតែជៀងរកជល់ ៗ ឯមាន់ចៅកែលលកនោះ ធ្វើជាដើរជ្រប់ៗ បែបពងស្ងុរ ធ្វើសម្រែកក្រុច ១ ក្រុចៗ..ៗ លុះមាន់ស្ដេច ចូលសម្រុកមកស្គ្រប់ចាក់មួយឆ្នាល់ពីរ, មាន់ចៅកែល-លក ធ្វើជារត់វិលចុះឡើង ដូចជាត្រូវស្រងល់វឹងស៊ិងហើយ, មាន់ស្ដេចបេះតែស្គ្រប់ចាក់បន្ថែម ៗ ព្រះរាជា ព្រមទាំងបរិពារ និងពួកអ្នកមើលទាំងប៉ុន្មាន មានទឹកមុខញញឹម ទះដៃហ៊ោកញ្ជ្រៀវខ្ញៀវខ្ញារ, ឯចៅកែលលកមានទឹកមុខស្រពោន តែគេនៅមានសង្ឃឹមជានិច្ច ៗ លុះដល់ចុងទឹកទី១ជិតមកដល់ហើយ ទើបមាន់ចៅកែលលក លោតស្គ្រប់ ចាក់មាន់ស្ដេចតែមួយជើង ចឹកចំក្បាលតែមួយចំពុះ, មាន់ស្ដេចបែកក្បាល លៀនក្នែកក្តែ ហូរឈាមសស្រាក់ ប្រកាច់តះៗ ដួលស្លាប់មួយរំពេច ៗ ស្ដេចខ្ញាល់ណាស់ត្រាស់ឲ្យគ្នាក់ងាររក្សាមាន់ លែងមាន់ទាំងអស់ចូលក្នុងសែវៀន, តែឥតប្រយោជន៍ មាន់ទាំងអស់ប្រមាណ ៥០០ ត្រូវស្លាប់នឹងចង្កូមស្លាកទាំងអស់ គ្មានសល់មួយ ៗ ជ័យជំនះរឿងដល់មាន់

ត្រូវបានទាន់ទៅតែលលក ។ ព្រះកដាត្រាស់ថា អើមាណព ! ពេលនេះ មាណពឈ្នះយើងហើយ, ពាក្យពិតដែលយើងនិយាយទាំងប៉ុន្មាននោះ ក៏យើងមិនបំភ្លេចដែរ, តែថាការដែលត្រូវប្រកួតគ្នា មិនមែនអស់ហើយតែ ត្រឹមរឿងប្រជល់មាន់មួយមុខប៉ុណ្ណោះទេ នៅមានច្រើនទៀតទើបអស់កិច្ច ។ ដូច្នេះ ស្អែកត្រូវអ្នករកក្របីយកមកប្រជល់ទៀតកុំខាន ។ កិច្ចការភ្នាល់ ប្រជល់មាន់ ចប់សម័យត្រឹមពេលនេះហើយ, ស្អែកយើងបើកសម័យ ប្រជល់ក្របី, ពេលវេលាដូចសម័យជល់មាន់ដែរ ។

មានជ័យមួយគ្រាហើយ មាណពហាក់ដូចបានធូរទ្រូងបន្តិច, ទើប ថ្វាយបង្គំលាស្ដេច បីមាន់ត្រឡប់ទៅលំនៅឋានវិញ បៀមយកជ័យជំនះ រឿងជល់មាន់ទៅផង បៀមទាំងទុក្ខព្រួយមួយចំណែកទៀត ដែលថាស្អែក ត្រូវតែរកក្របី ឲ្យបានយកទៅប្រជល់នោះផង ។ ពេលដែលមាណព ចេញទៅប្រជល់មាន់ផុតបន្តិច ខ្លាចតូចក៏ទៅតាមក្រោយដែរ ចាំស្ដាប់ ដើមការណ៍ លុះដឹងថា មាន់ទៅតែលលកឈ្នះមាន់ស្ដេចហើយ ទាំង បានឮស្ដេចបង្គាប់ ឲ្យរកក្របីប្រជល់ទៀត ក៏គិតឃើញស្រេចគ្មានព្រួយ ហើយត្រឡប់មកលំនៅវិញមុនទៅតែលលក ។ ឯមាណពតែលលកនិង ស្ការក៏បានមកជាក្រោយ, ដល់មកកន្លែងមួយ ស្ដេចស្ការនិយាយប្រាប់ មាណពថា បើមានធុរៈអ្វីទៀត ឲ្យនឹកដល់ខ្លួនរាំទៀតចុះ រាំនឹងមកជួយ តែចំពោះរឿងជល់ក្របីជួយមិនកើតទេ ហើយលាចេញបាត់ទៅ ។

ចំណែកឯនាងពូនវិញ នាងនៅចាំខួមព្រួយចិត្តណាស់ អង្គុយចាំមើលផ្លូវប្តី ផ្សារកាំភ្លែក ១ ថ្ងៃទល់ល្ងាច , លុះបានឃើញប្តីមកដល់វិញហើយ នាងត្រេកអរណាស់ ស្ទុះរត់ចេញទៅទទួល សម្តែងការគួរសមនិងសេចក្តីស្រឡាញ់ អញ្ជើញប្តីឲ្យងូតទឹក រួចរៀបបាយទឹកឲ្យប្តីអា·ស្រ័យ, ជាបណ្តើរនោះ មាណពនិយាយប្រាប់ប្រពន្ធថា រឿងប្រដល់មាន់មិនជាអ្វីទេ ព្រោះបានស្តេចស្ការជួយរួចមួយគ្រាហើយ, តែនៅមានរឿងប្រដល់ក្របីមួយខ្សែកថ្មីធ្លាក់មកដល់ទៀតហើយ ។ គ្រាន់តែលេបបាយបាន ៤-៥ មាត់ មាណពនឹកព្រួយក្តុកអួលដល់ដើមក លេបបាយលែងចូល ក៏យកទឹកមកផឹកហើយទៅប្រះផេកយកដៃគងថ្ពាល់សន្ទឹកសង្វៃ នឹកគិតមិនលេចថានឹងទៅរកក្របីឯណាបាន ។ លុះដល់ពេលព្រលប់ ខ្មោចតូចមកសួរ, មាណពថ្លែងរឿងប្រាប់ តាំងពីរឿងដល់មាន់រហូតដល់រឿងត្រូវប្រដល់ក្របីស្អែកទៀត ហើយប្រាប់ឲ្យខ្មោចតូចជួយគិតផង ។ ទើបខ្មោចតូចប្រាប់ថា សម្លាញ់កុំទៅគិតអី កុំព្រួយពេក , រឿងដល់ក្របីនោះងាយសោះទេ, ចូលនឹកទៅស្តេចខ្លាដែលជាប់អន្ទាក់ឯងពីមុននោះឲ្យមកជួយទៅបានហើយ ។ គ្រាន់តែតូចថាភ្លាម មាណពក៏នឹកឃើញភ្លាមទៅដល់ស្តេចខ្លា ។ ក៏មកដល់ដូចចិត្ត ហើយសួរពីបំណងដែលនឹកឲ្យខ្លួនមក, មាណពអធិប្បាយរឿងប្រាប់ស្តេចខ្លា ។ ថា រឿងនេះកុំព្រួយ ខ្ញុំហ៊ាន

ធានាជួយបាន, សូមលោកសម្រាន្តឲ្យស្រួលខ្លួនទៅចុះ ចាំស្អែកខ្ញុំមក, ចាំហើយ ខ្លានោះក៏លាទៅវិញបាត់ទៅ ។

ព្រឹកស្អែកឡើង ចៅគែលលកវង់ចាំស្តេចខ្លា ។ ក៏បានមកជួបសន្យា ហើយនាំគ្នាធ្វើដំណើរចេញទៅ លុះទៅដល់កន្លែងស្ងាត់មួយ ខ្លាក៏សម្តែងរិទ្ធិកាឡាខ្លួនធ្វើជាក្របី, មុនដំបូង ធំធាត់មាំ រួចហើយធ្វើខ្លួនឲ្យតូច នៅប៉ុនកូនក្របីទើបកើតបាន ១ ខែ ស្គមរយីង លេចឆ្អឹងជំនីររគាម ថួចង៉ើក ៗ ។ ។ កាលដែលចូលទៅដល់ទីប្រជុំហើយ មាណពក៏ថ្វាយបង្គំព្រះពជា ។ ទត ឃើញកូនក្របីតូចដូច្នោះ ទ្រង់ញញឹមសង្ស័យថាទីឯឈ្មោះឥតសង្ស័យ, ទើបត្រាស់ឲ្យគ្នាក់ងារលែងក្របីស្តេច ចូលទីលានប្រជល់ បង្គាប់ឲ្យមាណពលែងកូនក្របីនោះទៅដែរ ។ កូនក្របីរបស់ចៅគែលលកក៏បោលចូលទៅរកក្របីស្តេចសសុលក្រោមពោះរកបៅបោកពង ។ ក្របីស្តេចរេរើបណាស់ ប្រឹងតែបោលពាសពេញទីលាន, កូនក្របីចេះតែបោលដេញមិនឈប់, លុះដល់ទីបំផុត កូនក្របីខាំផ្តាច់បោកពងរបស់ក្របីស្តេច, ក្របីស្តេចបោលទាំងហូរឈាមសស្រាក់ ដកបដល់សោះឈាមដាច់ខ្យល់ស្លាប់ទៅ ។ ស្តេចបង្គាប់ឲ្យយកក្របីទី ២ ចូល, ក្របីទី ២ ត្រូវដាច់បោកស្លាប់ទៀត ។ ស្តេចខ្ញាល់ណាស់ ត្រាស់បង្គាប់ឲ្យលែងក្របីទាំងហ្វូងចូលទៅទៀត, ក្របីទាំងនោះត្រូវស្លាប់ដូចគ្នាអស់គ្មានសល់មួយ ។ សម័យនៃការគ្នាល់ជល់ក្របី

ក៏បានបិទ ៗ ព្រះរាជា ត្រាស់ហៅមាណពទៅប្រាប់ថា រឿងភ្នាល់ជល់ក្របី ទុកជាជ័យជំនះបានទៅខាងឯចៅហើយ, ប៉ុន្តែនៅពេលព្រឹកស្អែក ត្រូវបើកសម័យជល់ដំរីទៀត, ចូរអ្នករកដំរីយកមកប្រជល់កុំខាន, កំណត់ពេលវេលាដូចមុន ៗ ៗ

ដល់មករឿងជល់ដំរី ចៅកែលលកភ័យណាស់ ព្រោះគាន់តែជូនទៅទៀត, ហើយថ្វាយបង្គំលាស្តេច នាំក្របីតូចនោះត្រឡប់លំនៅវិញ ដើរមកដល់ពាក់កណ្តាលផ្លូវ ប្រទះនឹងខ្មោចតូច ១ សួរ, មាណព ប្រាប់តាមរឿងហូរហែ, ខ្មោចតូចប្រាប់ថា ចូរសម្លាញ់ទឹកទៅដំរីសជាឪពុកក្មេកឯងនោះ ឲ្យមកជួយទៅបានហើយ ៗ លុះនាំគ្នាមកដល់ខ្ទម, ស្តេចខ្មោចលាចេញទៅ, ចៅកែលលក ក៏សំបូងសម្រែងទឹកទៅដល់ស្តេចដំរីស ១ ក៏មកដល់ភ្លាម សួរថា អីកូន ! តើកូនមានការធុរៈដូចម្តេច ? មាណពរៀបរាប់ប្រាប់ស្តេចដំរីឪពុកក្មេកពីរឿងស្តេចឲ្យរកដំរីយកទៅប្រជល់នោះ ដោយសព្វគ្រប់, ស្តេចដំរីថា ទៅភ័យអីប៉ុណ្ណឹង ១ កុំព្រួយកូន ! លុះស្អែកឡើង ក៏ចេញដំណើរទៅកាន់ទីលានប្រជល់, ស្តេចដំរីបាននិម្មិតខ្លួនឲ្យគាន់តែចាស់ជាងប្រក្រតី ស្គមរំពេក ឡូលចក់ស៊ើររលំ ដើរទ្រេតទ្រោតៗ ចាក់ឃ្វយ ១, ទៅដល់ហើយ ចៅមាណពកែលលក ចូលក្រាបថ្វាយបង្គំស្តេច ១ ត្រាស់ឲ្យលែងដំរីចូលលានប្រយុទ្ធគ្នា ៗ ឯដំរីស្តេច គ្រាន់តែក្រឡេកឃើញស្តេចដំរីសនោះភ្លាម ក៏ដួញជង្ឃ្លលើកប្រមោយត្រកងឡើង

លើ ជាសញ្ញាក្រាបថ្វាយបង្គំស្តេចដំរីស ។ ស្តេចខ្លាល់ណាស់ត្រាស់បង្គាប់ឲ្យលែងដំរីទាំងអស់ឲ្យចូលចំប្រាវបំព្រេចដំរីសំគមនោះ, ប៉ុន្តែជាការឥតអំពើសោះ, ព្រោះដំរីស្តេចទាំងអស់ សុទ្ធតែលុតជង្គង់ថ្វាយបង្គំស្តេចដំរី ដោយតាញ់បុណ្យបារមីស្តេចដំរីនោះខ្លាំងពេក ស្តេចទាំងខ្លួនប្រាណរហូតដល់សរសៃធំនាំឈាមហូរលែងកើត ក៏ស្រាប់តែគាំងបេះដូងស្លាប់ទាំងអស់គ្មានសល់មួយ ។ ស្តេចរីងរៃតែខ្លាល់ គិតរករឿងចាប់ថ្នាក់ថ្នាញ់ផ្កាលទៅតែលលក ហើយត្រាស់ប្រាប់ទៅថា រឿងដល់ដំរី បញ្ចប់ត្រឹមប៉ុណ្ណោះ ទុកជាទៅឯងឈ្នះចុះ, តែថា មាន់ក៏ច្រើន ក្របីក៏ច្រើន ដំរីក៏ច្រើន សុទ្ធតែជារបស់ផងយើងជាស្តេច ត្រូវទៅឯងសម្លាប់អស់ហើយ, បើដូច្នេះត្រូវឯងមកស៊ីសាច់សត្វ ដែលអ្នកឯងបានសម្លាប់ឲ្យអស់ , បើស៊ីមិនអស់ត្រូវតាញ់យើង ។ ទីងរៃយកប្រពន្ធឯងហើយ ។ ទៅតែលលក ថ្វាយបង្គំលាស្តេច នាំដំរីត្រឡប់ទៅលំនៅវិញ, ខ្មោចតូចមកសួរដូចកាលមុនៗ ដឹងរឿងហេតុហើយ ប្រាប់ឲ្យទឹកទៅដល់ស្តេចពស់ ហៅឲ្យមកជួយ, ស្តេចពស់មកដល់ភ្លាម, ទៅតែលលកប្រាប់ស្តេចពស់ឲ្យជួយតាមដំណើរហេតុៗ

ព្រឹកស្អែកឡើង ទៅតែលលក និងស្តេចពស់ នាំគ្នាចេញទៅកាន់រាជវាំង, ប៉ុន្តែគ្រានេះ ស្តេចពស់មិនឲ្យទៅតែលលកទៅផងទេ ឲ្យពួននៅក្នុងព្រៃបានហើយ ។ វាក៏ណែងខ្លួន ធ្វើឲ្យដូចទៅតែលលក ដើរចូលទៅ ។ នៅទីព្រះលានស្តេច គេរៀបមាន់ស្ងោរទាំងមូល ៥០០ ក្របី

ស្បូវទាំងមូល ៥០០ ដំរីអាំងទាំងមូល ១០០ និងបាយ ១០០ ខ្ទះគោត ទុក
បម្រុងជាស្រេច ។ ស្ដេចទតឃើញពស់ក្លែងខ្លួននោះទៅដល់ ទ្រង់នឹក
ស្មានជាទៅតែលលក ក៏ត្រាស់ថា នែមាណព! នុះហ្ន៎ ជាក្រយាហារ
សម្រាប់ឯងហើយ ចូរឯងអំពះឲ្យអស់ទៅចុះ ។ ពស់ក្លែងគេទ ក៏ធ្វើការ-
កិច្ចចំពោះព្រះភក្ដ្រា ដូចលំនាំទៅមាណពតែលលកពិត ៗ រួចហើយក៏ចូល
ទៅកាន់គោជនដ្ឋាន លាតសន្ទឹងកន្ទុយទៅដល់ស្ទឹងដែលមានទឹកហូរយ៉ាង
គ្របាញ់ ឥតឲ្យនរណាម្នាក់មើលឃើញ ហើយចាប់ស៊ីអាហារតាំងតែពី
ព្រឹកទល់សៀល , មាត់តែពម គួទពីតតែបញ្ចេញទោលទៅក្នុងស្ទឹង,
ស៊ីដកបដល់អស់ តាមដែលស្ដេចដាក់កំរិត គ្មានឲ្យនៅសល់អ្វី ។ ស្ដេច
ទ្រង់នឹកស្ញើបជាខ្លាំងពន់ពេក ទើបត្រាស់ហៅមកប្រាប់ថា រឿងស៊ីបិទ
សម័យត្រឹមប៉ុណ្ណោះចុះ, ប៉ុន្ដែ ចូរអ្នកទៅរកទូក យកមកអុំប្រណាំងផ្ដាច់ព្រ័ត
ឲ្យបានប្រញាប់ឥឡូវ ខានមិនបាន ។ មាណពក្លែងក្លាយ ថ្វាយបង្គំលា
ស្ដេច ចុះតាកកដដំណាក់យ៉ាងរហាស់ ទៅកាន់កន្ទុងដែលបានមត់គ្នា
ឲ្យមាណពតែលលកនោះពួនចាំ , បានដល់ហើយ ក៏យកប់ប្រាប់ក្លាយថា
ស្ដេចឲ្យរកទូកយកទៅប្រណាំងទៀតហើយ, ដូច្នេះ ចូរលោកអញ្ជើញមក
នឹងចុះកាត់តម្រង់ទៅស្ទឹងតែម្ដង, ដល់ស្ទឹងហើយ ស្ដេចពស់ប្រាប់មាណព
តែលលក ឲ្យរកបន្ទះឈើមួយកំណាត់ ប្រាសធ្វើជាច្រវាឲ្យតែបាន
ហើយខ្លួនវានិមិត្តជាទូកកម្រោលមួយតូចស៊កប៉ឺក តៀបប្រហៀស្ទើរនឹង

លិច ឲ្យមាណពឡើងជិះខាងកន្ទៀ យកប្រាក់គ្រាន់តែធ្លុតទឹក ធ្វើដូចជាប្រឹងអុំ ហើយក៏ហែលទៅដល់កំពង់ស្តេចក្មាម, ប្រាប់មាណពឲ្យឡើងទៅទូលស្តេចថា គេទូកបានហើយ ។ ស្តេចឮដូច្នោះ ក៏ឲ្យក្មាក់ងាររៀបទូកស្តេច កេណ្ឌអគ្គសេនាបតីទាំង ៤ និងនាម៉ឺនក្រុមកាំងចុះទូក , ស្តេចគង់កណ្តាល ចេញអុំប្រណាំង, ទ្រង់ត្រាស់ថា អស់លោក! ចូរអស់លោក យកចិត្តទុកដាក់ ប្រុងជើងការឲ្យមែនទែនណា៎ ! ប្រឹងយ៉ាងណាឲ្យអស់សរសៃ ឲ្យតែចាញ់គេម្តងនេះ ខ្ញុំនឹងសម្លាប់ចោលទាំងអស់ ។ ការប្រណាំងទូក ក៏ចាប់ផ្តើមឡើង ។ ពួកទូកស្តេច ប្រឹងយ៉ាងអស់ទំហឹង តាំងពីលើកទី ១ ទី ២, ឯទូកមាណព ។ គ្រាន់តែធ្លុត ៗ គ្រាក់សប្រាក់ធ្វើជាលើកដាក់ ១ ផ្ទឹក ១ ឥតមានទៅប្រឹងអុំសោះ ក៏ក្បាលទូក លឿនស្មើនឹងទូកស្តេចខ្លះ ថយអន់ជាងបន្តិចបន្តួចខ្លះ ល្មមតែឲ្យពួកខាងទូកស្តេច មានសង្ឃឹមថា នឹងផ្តាច់យកជ័យនៅលើកទី ៣ បាន ។ លុះដល់លើកទី ៣ ពស់ក្លែងគេនោះ ក៏ធ្វើជាប្រឹងបន្តិចទៅពីដើមទី ឲ្យពួកទូកស្តេចប្រឹងពីតតាម តែមិនឲ្យទូកស្តេចមានក្បាលលូតលឿនជាង, ពួកនោះ កាន់តែពឹតឡើង ។ ប្រឹងយ៉ាងអស់សរសៃ អស់ពីមួយអើយមួយ សាប់ផង ចកផង មើលទៅប្រាក់ញាប់សេញ ទូកលឿនដូចព្រួញ , ពស់វែកក់កន្ទុយវាយព្វិចទូកស្តេច ព្រួសពិសចំកខាំសម្លាប់ទាំងស្តេច ទាំងបរិពារអ្នកអុំគ្មានឲ្យសល់ម្នាក់ ។

ក្នុងនោះ សេតស្តេចទៅយកកំណើតជា សត្វទន្សាយ, សេនាបតីធំទាំង ៤ ទៅកើតជា ខ្លែងស្រាក ខ្លែងខ្លោច ទីទុយ មៀម, នាម៉ឺនធំតូចក្រៅពីនេះ ទៅកើតជា ពស់ ក្អែម ខ្មួយ ខ្យាដី ស្ទុះសឹងជាសត្វកាសិរពិស ហើយនាំគ្នាទៅដល់ខ្ទមមុនចៅកែលលក ខ្លះទំនៅលើចុងឈើ ខ្លះចូលទៅសម្ងំនៅក្នុងផ្ទាំងឬាយ -បំពង់ទឹក-គំនរខុស-ដញ្ញាំងខ្ទមប្រុងចាំសម្លាប់នាងពួនទិងចៅកែលលក ។ ខ្លោចតូច បានដឹងហេតុការណ៍នោះទាំងអស់ ព្រោះវាមើលឃើញខ្មោចដូចគ្នា, តួចទៅប្រាប់នាងពួនឯខ្ទមឲ្យប្រយ័ត្នសព្វគ្រប់ហើយ ក៏ប្រញាប់ទៅស្លាក់ផ្លូវចាំប្រាប់ការណ៍ទាំងអស់នោះដល់ចៅកែលលកទៀត ។ ក្រោយបន្តិចមក ទើបមាណពទិងពស់មកដល់, ជួបជុំគ្នាហើយ តូចប្រាប់ឲ្យមាណពយកស្នាមកតម្លើងផ្ទាប់ព្រួញប្រុងចាំជាស្រេច ហើយមិនដឹងជាបានប្រទាលអ្វីមួយជុំតូចហុចទៅឲ្យមាណពទំពារស៊ី ។ ហើយទើបវាប្រាប់ថា ឲ្យប្រុងចាំមើលទីងឃើញទន្សាយ ជាតួស្តេចខ្មោច និងសត្វផ្សេង ៗ ទៀត, បើកាលណាវាស្រែកយំ ឲ្យបាញ់ភ្លាម ៗ ថាមិនទាន់ផុតពីមាត់ ទន្សាយស្រែក ឡូ ! ឡេវ ! ឡេវ៊ីង, នាងពួនត្រូវសន្ធប់បាត់ស្មារតី, មាណពបាញ់ធ្លាក់ខ្លោក, នាងពួនក៏បានភ្ញាក់ដឹងខ្លួនឡើងវិញ, លេចឯខ្លែងស្រាក ខ្លែងខ្លោច ទីទុយ មៀម មកស្រែកក្រោក ១! ទីទុយ ១!.. ម៉ឺម ១! នាងពួនត្រូវសន្ធប់បាត់ស្មារតីទៅទៀត, មាណពបាញ់សម្លាប់អស់ទៀត ទើបនាងពួនភ្ញាក់

ឡើងវិញ (ជាទម្លាប់ សូម្បីក្រោយមក នគរសុខសាន្តត្រាណហើយ ក៏អ្នកស្រុកអ្នកនគរនៅតែខ្លាចព្រឺក្បាលខ្លាក ៗ ទល់សព្វថ្ងៃ ចំពោះសម្រែកសត្វស្លាបទាំងប៉ុន្មានចំពូក ដូចជាតាំងតែពីមានរឿងដូចនិទាននេះឡើង ) ។ បន្ទាប់ពីនោះ ខ្មោចក្ងួច ប្រាប់ឲ្យមាណពយកដំបង វាត់របស់ទាំងប៉ុន្មាន ដែលសត្វដទៃទៀតជ្រកពួនសម្ងំនៅ ធ្វើប្រមូលយកទៅដុតចោលមួយគក់ ។ ពួកខ្មោចទាំងអស់នោះ ក៏ត្រូវស្លាប់វិនាសរត់ខ្ចាត់ខ្ចាយអស់គ្មានសល់ ។ ពស់ក៏លាទៅនៅព្រៃតាមប្រក្រតី ។

ចាប់ពីពេលនោះមក នគរនោះក៏ទៅជាសូន្យស្ងាត់ ។ ពួកបណ្ដាប្រជាជនទៅជាច្រួលច្របល់ ទីងរែរកស្ដេចសោយរាជ្យពុំបាន ក៏នាំគ្នាប្រជុំជាពួកជាក្រុម ចូលទៅរកព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតហោរ ឲ្យគិតគូររឿងនោះ ។ ករបណ្ឌិតព្រាហ្មណ៍ព្រឹទ្ធហោរ ក៏តាំងបើកក្បួនមើលទៅឃើញថា ត្រូវផ្សងដំរីមង្គលរើសរកអ្នកមានបុណ្យ ។ ពួកភ្នាក់ងារមន្ត្រីធំតូច មុខងារសេនា សេនីយ៍ ក៏ចាត់រៀបក្បួនតាមប្រពៃណី ហើយពួកព្រាហ្មណ៍ព្រឹទ្ធសូត្របួងសួងនូវអស់ឥន្ទព្រហ្មទេវតាអារក្សអ្នកតា បិតនៅនាបព្វតាគុហាជ្រោះជ្រលងដងស្ទឹងបឹងបួ ប្រាសាទវិមានគ្រប់ទិសទីថា បើអ្នកឯណាមានរិទ្ធិតេជោបារមី ឲ្យដំរីទៅនាំយកមកគ្រងក្រុងឥឡូវនេះកុំបីខាន ។ ផ្សងហើយ មុខមន្ត្រីតាមលំដាប់ បើកបាំងក្លស់ក្លុំទូងគោរ រាយភ្លេងនាគពាទ្យគងចេញទៅ ៗ ដំរីមង្គល ក៏ចេញឆ្ពោះសំដៅទៅ

ចូលព្រៃ ដរាបដល់ទៅខ្ទមចៅតែលលកនិងនាងពួន ។ តាំងពីនាក់នោះ ឃើញដូច្នោះ នឹកភ័យណាស់ថា ក្រែងមានអាសន្នធំមួយជាន់មកដល់ទៀត ដឹកដៃគ្នារត់ ប៉ុន្តែខ្មោចតូចមកទាន់ប្រាប់ថា កុំរត់ទៅណា កុំខ្លាច! កុំខ្លាច! គ្មាននរណាហ៊ានធ្វើអ្វីទេ ប្រុងប្រៀបរៀបចំចាំចុះ ពេលវេលាដល់ហើយ ៗ ក្បួនពិធីនោះ ក៏បានមកដល់, ដំរីមង្គល ក៏លុតជង្គង់នៅមុខចៅតែលលកនឹងនាងពួន, ព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតហោរា នាម៉ឺន អគ្គមុខអគ្គការ សេនីយ៍សេនាហេពល ក៏លើកករប្រណម្យ អញ្ជើញតាមបុរាណរាជប្រវេណី សុំជាទីជ្រកកោនក្រោមម្លប់បុណ្យរាជសម្ភារបារមី និងដង្ហែចូលកាន់រាជបុរី បានជាទីពឹងពំនឹងតទៅ ៗ ចៅតែលលក ធ្វើឡើងឡង់ មើលទៅនាងពួនបន្តិច មើលទៅខ្មោចតូចបន្តិច មិនទាន់ហ៊ានជាម៉េចនៅឡើយ លុះតែខ្មោចតូចប្រាប់ថា ចាំអីទៀតពេលដល់ហើយមិនអីទេ ទទួលយកពាក្យនេះទៅចុះ អស់មានគ្រោះថ្នាក់ហើយ ៗ បន្ទាប់នោះ ពួកអញ្ជើញគ្រឿងក៏នាំយកប្រដាប់សម្រាប់ទ្រង់ ដាក់តម្កល់លើពានមាស ព្រមទាំងទឹកអប់ប្រេងម្សៅក្រេះចួងចន្ទន៍ ដ៏មានគន្ធពិដោរល្ហែងល្ហើយមកថ្វាយ ៗ ចៅតែលលកនឹងនាងពួន ជម្រះអង្គរួចហើយ ក៏ទ្រង់គ្រឿងកកុធភ័ណ្ឌជាស្ដេចស្រេចកាលណា ទើបបង្គាប់ឲ្យពួកសេនា ដ៏មានខ្មោចតូចជាអ្នកនាំមុខ ទៅជីកគាស់យកទ្រព្យរបស់ពីដំបូក យកមករៀបចំស្រេច ស្ដេចក៏ឡើងគង់ដំរីរ័តន៍ជាមួយនឹងនាងពួន, ស្ដេចដំរីជា

ឪពុកដើរយោងមុខការស្រូវ ដង្ហែស្តេចគែលលកចូលក្រុង ។

និយាយពីចៅព្រាន និងពួកអ្នកដែលមានខ្លួនទាំងប៉ុន្មាន ឈរមើលពិធីហែស្តេចគែលលកនោះ យ៉ាងស្ងៀមស្ងាត់បាត់មាត់ដូចគេចុក មានចិត្តគិតបារម្ភតែរៀងខ្លួន អ្នកខ្លះធ្វើស៊ីងស្រឡើកើ ឡើងក្អកមួលដូចគាក់ ខ្លាចណាស់ ក្រែងស្តេចយកទោស ព្រោះពីថ្ងៃមុន ពួកខ្លួនបានជ្រុលហ៊ាកញ្ច្រៀវសើចចំអក ចាំផ្តើសផ្តាសសន្ធឹកសន្ធាប់ណាស់ ។

លំដាប់នោះ ពិធីរាជាភិសេកដ៏មហោឡារិក ក៏បានប្រព្រឹត្តទៅក្នុងព្រះបរមរាជវាំងចំនួន ៧យប់ ៧ថ្ងៃ, ក្នុងពិធីនោះ គេឃើញខ្មោចតូច លេចមុខមាត់ជាងគេទាំងអស់ ហើយស៊ីផឹកហ៊ឺហាសប្បាយចិត្តណាស់ផង ។ ស្រេចបាច់អស់កិច្ចហើយ ខ្មោចតូចក៏លាទៅយកកំណើតជាមនុស្សទៅ ។

ពីរ-បីថ្ងៃ ក្រោយពិធីរាជាភិសេកមក, ស្តេចដំរីស ដឹងថា ខ្លួនទឹងដល់កំណត់អស់អាយុសង្ខារ ទើបហៅកូនទាំងពីរមកផ្តាំថា ឪពុកនឹងស្រុត (ស្លាប់) បើឪពុកស្រុតទៅហើយនោះ ចូរកូនយកភ្លុកម្ខាងទៀតនេះទុកថែរក្សា យកប្រអប់ជើងឪពុកធ្វើជាប្រអប់ស្លា ឲ្យសន្មតថា ប្រអប់ជើងដំរី យកស្បែកត្រចៀកទុកធ្វើជាចង្អើ, ផ្តាំស្រេចក៏ទៅស្រុតនៅក្បែរចំការស្រូវរបស់ចៅគែលលកនោះទៅ ។ ចៅគែលលកនិងនាងពួន ក៏បានធ្វើតាមបណ្តាំនោះ ព្រមទាំងរៀបទុកដាក់សពស្តេចដំរីនោះយ៉ាងអធិអធមផង ;

កន្លងបន្តិចមក ស្តេចគែលលកចាប់ផ្តើមនឹកទៅដល់មាតាបិតា នឹកកាល

ត្រាកំសត់កម្រហូតមកបានជាស្តេច គិតបង់យកទ្រព្យរបស់មាសប្រាក់ទៅឲ្យគាត់ខ្លះ, ទើបថ្ងៃមួយទ្រង់ត្រាស់បង្គាប់ឲ្យនាងពួនរៀបរបស់ទ្រព្យសុទ្ធតែល្អៗ មួយបង្វិចធំ ឲ្យនាយស្មៀនចារឹកអក្សរដាក់បង្កប់ក្នុងបង្វិចនោះថា "សូមម៉ែនិងឪយកទ្រព្យរបស់នេះប្រើប្រាស់ចុះ ខ្ញុំជាកូនដែលម៉ែនិងឪដេញពេលពីថ្ងៃមុននោះផ្ញើមកជូន" ស្រេចហើយក៏ចេញទៅជាមួយនឹងអាមាត្យម្នាក់ក្នុងពេលដ៏ស្ងាត់កាត់តម្រង់ទៅ លុះបានទៅដល់ខ្ទមឪពុកម្ដាយហើយរង់ចាំដល់ពេលពក្រស្ងាត់ ក៏ឲ្យអាមាត្យលបយកចូលទៅហែកជញ្ជាំងទុកត្រង់ក្បាលដំណេក រួចត្រឡប់មកវាំងយប់នោះវិញ ។

តមក ក៏បាននៅសោយរាជសម្បត្តិ ជាសុខសាន្ត ជាមួយនឹងនាងពួន បានបញ្ញត្តនាមរបស់ខ្លួន ឲ្យមនុស្សម្នាមហាជន ដឹងឮទៅថា "ព្រះពៅគៃលលក " បញ្ញត្តចំការស្រូវដែលធ្លាប់ធ្វើមកនោះ ឲ្យហៅថា "ចំការពៅគៃលលក" ទាំងស្មៅដែលមានដុះក្នុងចំការនោះ ឈ្មោះថា " ស្មៅគៃលលក " ។ ឯពួកអាណាប្រជាជនក្នុងនគរ ក៏បានប្រកបដោយសេចក្ដីសុខសាន្តសម្បូណ៌សប្បាយតទៅហោង ។

| | |
|---|---|
| អាយុមិនអស់ | គង់តែមិនស្លាប់ |
| គូព្រេងគួរគាប់ | គង់តែបានជួប ។ |

(អត្ថបទពុំទាន់មានពីរ)

ហត្ថលេខា : ព្រូប-ភុម

# រឿងសាមកុក

ចាកញ៉ាំវិបុលភជសេនា

ង្វួ-កាង

ប្រែ-រៀបរៀង

(៣)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ   អ្នកអងវៃឆ្លាស់បើបានអាន<br>នឹងចេះទាយកលចំណាន   ទាំងមានសត្តានស្នេហាជាតិ<br>យូរ-អ៊ុន |

បញ្ញាតយើងទេ មុខជាគេមានយកទាហានទៅឲ្យពួនបង្កប់ទុកក្នុងច្រកភ្នំជាប្រាកដ អ្នកកុំចេញទៅច្បាំងឡើយ ទាហានទាំងពួងឮឡកស៊ុនថាហើយ ក៏នាំគ្នាសើច ហើយទាំងអស់គ្នានិយាយថា ឡកស៊ុននេះខ្ចីប្រាជ្ញស្មារតីពេកណាស់ ចេះតែភ័យខ្លាចសឹកសត្រូវមិនសូវហ៊ានទំលុះទំលាយការអ្វីសោះ ។

ឯងីប៉ាន់នាយទ័ពមុខ លុះព្រឹកឡើងក៏ដេញទាហានចូលទៅស្រែកឡកចំអកជេរនៅមាត់ទ្វារបន្ទាយ នោះឈីសេង, តេងហងនាយកងទ័ពបានឮ ក៏យកសេចក្ដីទៅប្រាប់ឡកស៊ុនថានឹងសុំចេញច្បាំង ឡកស៊ុនក៏ថា អស់អ្នកទាំងអម្បាលនេះមិនចេះដឹងអ្វីសោះ ព្រោះនឹងគិតធ្វើការអ្វីសុទ្ធតែកាប់បំបាក់យកតាមកំឡាំង មិនរាំងគិតតាមគំនិតប្រាជ្ញាប្រើកល

ក្រាស់ក្រួនទឹងចេញខ្លួនទៅ រង់ទទួលពីមុខដូចផ្ញុំភ្លើងពីក្រោមខ្យល់ទឹង បានប្ដូ វេលានេះនឿយហត់ណាស់ហើយបានជាថយទៅ ឯឡសំពល ទាហានក៏មានចិត្តភ្លើតភ្លើនមិនសូវគិត ព្រោះដឿតថាមកគ្រាណាៗក៏មិន តប៉ាំងគ្នា គង់ទឹងពារេកបែកចិត្តគិតទៅជ្រៀតជ្រកដេកលេងឲ្យសប្បាយ ខ្ចាត់ខ្ចាយបែកចេញពីគ្នា យើងត្រូវចាំមើលកលការគ្រាតែបានចំណាប់ទឹង លើកទ័ពចេញទៅកំហុកវាយគង់ទឹងបែកធ្លាយមិនខាន ។

ពេលនោះអស់ នាយទ័ពនាយកងទាំងពួងបានស្តាប់ក៏យល់ឃើញ ត្រូវណាស់ តាំងពីនោះមកក៏ឲ្យក្រែងខ្លាចប្រាជ្ញាឡុកស៊ិនៗក៏ចាត់ចែង ចែងទាហានត្រៀមទុក ហើយធ្វើសំបុត្រមកប្តឹងតាមផ្លូវរាជការ ឲ្យបំរើ កាន់ជាហេស៍នាំចូលទៅថ្វាយព្រះចៅឡុកគួនសេចក្ដីថា ឃើញកំឡាំង ព្រះចៅឡេវពីទន់ចុះហើយ ឥឡូវលើកទ័ពថយត្រឡប់ទៅតាំងក្រោមម្លប់ ឈើទឹងក្បែរមាត់ទឹក ក្នុងវាង ១៥ ថ្ងៃទៀត ទូលព្រះបង្គំជាខ្ញុំទឹងសំវាយ ឲ្យបែក ព្រះចៅស៊ុនគួនឃើញសេចក្ដីសំបុត្រដូច្នោះក៏ព្រះអំណរណាស់ ទើបកេណ្ឌទាហានថែមទៅបំពេញឲ្យឡុកស៊ុនទៀត ។

វេលានោះ ព្រះចៅឡេវពីក៏ត្រាស់បង្គាប់នាយទ័ពជើងទឹក ឲ្យតាំង បន្ទាយទឹកល្អមបាំងទូកបាន ហើយកាយចុះទៅក្នុងដែនស្រុកកាំងតាំង ហងគួនទូលថា ដែលទឹងឲ្យទ័ពទឹកលើកចូលទៅនោះឃើញមិនងាយសោះ

ព្រោះខ្មាំងត្រឡប់មកវិញពីប៉ាកណាប់ ដោយប្រាសចាកកំពង់ឡើង ទូល
ព្រះបង្គំជាខ្ញុំ ខ្ញុំសុំទៅតាំងជាខាងវិញមុខទ័ពប៉ាខលុបទ័ពទឹកដោយឆាយ
ព្រះអង្គជាទ័ពក្រោយហើយមុខជាមិនខឹងខាតដោយសឹកសត្រូវនោះ ព្រះ
ចៅឡៅពីត្រាស់ថា វេលានេះអាពួកស្រុកកាំងតាំងវាគេចក្បាលខ្លាចយើង
អស់ហើយ កាលណាឡើយវាខ្មាំងហានលៀនមុខមកច្បាំង កុំសង្ស័យ
យើងត្រូវតែស្រូតចូលទៅប្លុះ ខណៈនោះអស់នាម៉ឺនប្រឹក្សាក៏បានទាំងខា
ទូលភាស់ព្រះអង្គស្រ័យមិនឲ្យលើកទៅ ព្រះចៅឡៅពីក៏ពុំព្រមស្តាប់
ទើបចាត់កងទ័ពជា ២ ប៉ែក ១ ប៉ែកឲ្យហង្សតួនជានាយកងលើកចូលទៅ
តាំងខាងទិសឯជើងខ្ទាចប៉ូតីលើកមកវាយប្រសព្វខ្លួន ព្រះចៅឡៅពីក៏
តាំងបន្ទាយកាយនៅតាមក្បែរមាត់ទន្លេ ជិតគ្នានឹងទ័ពទឹក ។

ចាហានល្បាះក៏នាំសេចក្តីចូលទៅក្រាបទូលព្រះចៅប៉ូក៏ថា ព្រះចៅ
ឡៅពីលើកទ័ពទៅវាយស្រុកកាំងតាំង តាំងបន្ទាយកាយទៅតាមក្បែរមាត់
ទឹកចំនួន ៤០ បន្ទាយចម្ងាយ ១.០០០ សិន ហើយឲ្យហង្សតួនឃុំពាហាន
លើកទៅតាំងខាងទិសឧត្តរផ្លូវខ្មែរមកស្រុកយើង ព្រះចៅស៊ិនតួននោះតាំង
ឡុកស៊ិនជាមេទ័ពធំលើកទៅច្បាំងនឹងព្រះចៅឡៅពី ។ ព្រះចៅប៉ូក៏បានឮ
ដូច្នោះក៏ទ្រង់អស់សំណើចហើយថា ព្រះចៅឡៅពីគ្រានេះនឹងចាញ់ស៊ិន
តួន អស់ពួកនាម៉ឺនខ្ញុំរាជការនឹងទីប្រឹក្សាទាំងពួងឮហើយក៏ទូលសួរថា

ព្រះអង្គទ្រង់ឃើញយ៉ាងម្ដេច ចូកឺថា ព្រះចៅឡៅពីមិនចូលចិត្តគិតការទ័ព បានជាតាំងបន្ទាយវែងជាប់ដល់ ១.០០០សិន ប្រសិនបើសត្រូវត្រូវចូលច្បាំងខាងដើមឬខាងចុងនឹងជួបគ្នាបានឬ មុខជានឹងប៉ះការរបស់ស៊ុនគួនជាប្រាកដ យើងចាំមើលចុះ អស់នាម៉ឺននឹងទីប្រឹក្សាទាំងនោះនៅមិនទាន់ជឿតែម្ដងក៏ទូលសួរថា ទូលព្រះបង្គំជាខ្ញុំនឹងសុំរៀបចំកងទ័ពទុកឲ្យព្រមជាមុនៗ

ព្រះចៅចូកឺត្រាស់ថា ៖ ឡុកស៊ុនវាយទ័ពព្រះចៅឡៅពីបែកហើយ មុខជានឹងលើកដេញជិតប្រកិតតាមទៅដល់ស្រុកសៃឈួន ខាងស្រុកកាំងតាំងមនុស្សក៏នឹងស្ដួចស្ដើងតិចទៅ ត្រូវយើងលើកទៅវាយយកស្រុកកាំងតាំង ធ្វើអាការបើដូចនឹងលើកទៅជួយឲ្យគេជឿទុកចិត្ត វេលានេះយើងត្រូវត្រៀមទាហានទុកឲ្យស្រេចនឹងលើកទៅជា៣ផ្លូវ ទើបចាត់ចោយិនជានាយកងឃុំទាហានលើកទៅផ្លូវយូស៊ូ ឲ្យចោហ៊ុវឃុំទាហានលើកទៅផ្លូវតុងខៅ ឲ្យចោជិនឃុំទាហានលើកទៅផ្លូវណាំគុន ទាំង៣ទ័ពនេះត្រូវតាំងបង្កប់នៅក្នុងដែនយើងសិន យើងនឹងចាំស្ដាប់ដំណឹងល្បាត បើកាលណាបានឱកាសហើយសឹមលើកទៅឲ្យព្រមគ្នា ខ្លួនយើងត្រូវនៅជាទ័ពជំនួយ មុខជានឹងវាយបានស្រុកកាំងតាំងដោយងាយ ទីប្រឹក្សានឹងបណ្ដានាម៉ឺនទាំងពួងក៏យល់ឃើញត្រូវ ទាំងអស់គ្នា

ក៏លាថយចេញទៅចាត់ចែងចែងរំលែកកងទ័ព តាមត្រាស់បង្គាប់គ្រប់ប្រការ ៗ

ឯម៉ាលៀងដែលគួរផែនទីទៅឲ្យខុងបេងមើលនោះ លុះទៅដល់ស្រុកតាំងឈួន ក៏ចូលទៅរកខុងបេង ហើយយកផែនទីដែលតាំងបន្ទាយនោះឲ្យខុងបេងមើល ខុងបេងនោះលុះឃើញរបៀបផែនទីដូច្នោះ ហើយក៏ឲ្យស្ទុះទន្ទត់ស្មារតី លើកដៃទះគុហើយថា កម្មអើយកម្ម មុខជាចាញ់ឡូនស៊ុនជាប្រាកដហើយ នរណាជាជាងគិតឲ្យព្រះចៅឡៅពីធ្វើបន្ទាយដូច្នេះឲ្យយកខ្លួនមកសម្លាប់ចេញ ៗ ម៉ាលៀងថា គ្មាននរណាដឹងដែលគិតតាមគំនិតរបស់ខ្លួនបានទេ គឺរបៀបទាំងអស់នេះជាតម្រិះរបស់ព្រះចៅឡៅពីទ្រង់ត្រិះរិះចិន្តាឯង ដែលលោកថានឹងខូចផុសការដោយថ្វីដៃឡូកស៊ុននោះ លោកយល់ឃើញប្រការម្ដេច ខុងបេងថា ព្រោះតាំងបន្ទាយ៤០អាទ្រឹ ហើយវែងដល់៧.០០សិននោះ បើសត្រូវចូលច្បាំងឬដុតភ្លើងឆេះឡើងក្ដី នឹងរត់ទៅមកជួយគ្នាកាលណានឹងទាន់ការ ត្រូវតែរៀបបន្ទាយបញ្ចូលគ្នាជាចំឲ្យល្មមនឹងជួយការពារគ្នាបាន ម៉ាលៀងថា ខ្ញុំបាទនឹងវិលត្រឡប់ទៅវិញមុខជាមិនទាន់ការ ព្រះចៅឡៅពីមុខជាបែកទ័ពជាមុនហើយ ។ ទ័ពសត្រូវពុំនឹងមិនដេញមកដល់ស្រុកសែឈួនទេឬ ៗ

ខុងបេងថា ទោះបីព្រះចៅឡៅពីបែកហើយក្ដី ឡូកស៊ុនពុំមិន

មិនដេញតាមមកទេ ព្រោះវានៅគិតរិះរករាំងក្រោយ ក្រែងពួកនឹងចូលវាយយកស្រុកកាំងតាំង ខាងព្រះចៅឡាវពីនោះ ទោះបែកហើយ គង់នឹងទៅសំណាក់អាស្រ័យនៅស្រុកបុកគេ ឯស្រុកបុកគេនោះ បើយើងនៅមិនទាន់ចូលមកស្រុកសែឈួនទេ យើងគង់បានចាត់ចែងទាហានទុកដល់ ១០ម៉ឺន តាំងទុកនៅទីដំបន់អ៊ុប៉ាក់ប៉ោ មាត់ផ្លូវដែលចូលទៅស្រុកបុកគេនោះ ១ កង ។

ម៉ាលៀងថា ខ្ញុំបាទក៏បានដើរមកតាមផ្លូវអ៊ុប៉ាក់ប៉ោ លោកថាមានទាហាននៅទីនោះ ១ កង ហេតុម្ដេចក៏ខ្ញុំបាទមិនបានជួបប្រទះឃើញសោះ ខុងបេងថា អ្នកកុំអាលនិយាយឡើយ បើកាលណាអ្នកវិលទៅវិញហើយ គង់នឹងឃើញសេចក្ដីដែលយើងគិតទុកនោះជាក់នឹងភ្នែកប្រាកដ ម៉ាលៀងបានឮដូច្នោះក៏សុំសំបុត្រខុងបេងឡើងសេះត្រឡប់ទៅវិញ ខុងបេងក៏ចូលទៅក្នុងស្រុកសែឈួន រៀបបំរុងទាហានទុកឲ្យព្រម ។

ឯឡុកស៊ុននោះ លុះដឹងថាព្រះចៅឡាវពីតាំងបន្ទាយកាយតាមក្បែរមាត់ទន្លេ៤០អន្ទើវែងដល់១.០០០សិន ហើយឃើញទាហានទាំងអស់សុទ្ធតែភ្លើភ្លើមិនអើពើនឹងរាំងរក្សាខ្លួនដូច្នោះក៏មានអំណរណាស់ ទើបឲ្យប្រមូលនាយទ័ពនាយកងទៅប្រជុំព្រមគ្នាហើយបង្គាប់ថា វេលានេះជាឱកាសស្រួលរបស់យើងហើយ យើងនឹងឲ្យលើកទ័ពទៅកណ្ដាលយប់

វាយយកបន្ទាយដែលតាំងនៅទីតាំងណាំឲ្យបាន នរណាមានចិត្តនឹងសុំអាសាចូលទៅវាយខ្លះ ហានគុងទិងដីវថាយ, ឡេងថងទទួលថា យើងខ្ញុំនឹងសុំអាសាទៅវាយយកបន្ទាយឲ្យបាន ឡុកស៊ុនថា អ្នកទាំង៣នាក់កុំទៅចុះ ទើបឡុកស៊ុនហៅទាហានម្នាក់ឈ្មោះទុនអ៊ីគាន់ ឲ្យលើកទាហាន៥ពាន់ទៅវាយបន្ទាយប៉ៅទៀវឲ្យបានក្នុងពេលយប់នេះ យើងនឹងលើកទ័ពជំនួយទៅតាម ទុនអ៊ីគាន់ក៏លើកទាហានទៅតាមបង្គាប់ ឡុកស៊ុនក៏ប្រាប់ឲ្យឈីសេង, គេងហងនាយកង២នាក់នេះ ឲ្យឃុំទាហានម្នាក់៣ ០០០ទៅពួនបង្កប់នៅមាត់ផ្លូវ បើឃើញទុនអ៊ីគាន់ចូលទៅច្បាំងចាញ់សត្រូវដេញមកឲ្យចេញជួយស្កាត់ បើសត្រូវបកខ្លាត់ខ្លាយទៅហើយកុំឲ្យដេញតាមឈីសេង, គេងហងក៏លើកទ័ពចេញទៅធ្វើតាមបង្គាប់ ។

លុះពេលយប់ស្ងាត់ ទុនអ៊ីគាន់ក៏ឃុំទាហានស្រែកហោចូលវាយបន្ទាយប៉ៅទៀង ១ ឃើញផ្លូបោះក៏ឡើងសេះ កាន់លំពែងដេញទាហានចេញតតាំងច្បាំងគ្នា ទុនអ៊ីគាន់តស៊ូមិនបាន ខ្លួនក៏ត្រូវព្រួញទៀតក៏បរសេះរត់ទៅ ទៀវយ៉ាំងទិងសៈម៉ោខោតាំងបន្ទាយនៅក្រោយភ្នំ លុះឃើញទាហានស្រុកកាំងតាំង ស្រែកហោក៏កកងចូលវាយបន្ទាយប៉ៅទៀវផ្លូបោះ ក៏លើកទាហានចេញស្កាត់តច្បាំង ទុនអ៊ីគាន់ក៏រលះរលាំងរត់ទៅ នោះទៀវយ៉ាំងទិងសៈម៉ោខោ, ប៉ៅទៀវក៏លើកទ័ពដេញតាមទុនអ៊ី

តាន់ទៅទៀត ឯឈើសេង, តេងហានដែលពួនបង្កប់ក្បែរផ្លូវ ក៏លើកចេញប្រសព្វខ្ទប់ទាំងសងខាង ទ័ពព្រះចៅឡៅពីក៏បែកតែចូលបន្ទាយវិញ ឈើសេង, តេងហាង ក៏នាំគ្នាត្រឡប់ចូលបន្ទាយ ទុនអ៊ីតាន់ត្រូវព្រួញជាប់នៅខ្លួន ក៏ចូលទៅដល់ឡុកស៊ុនហើយយុំសុំទោសដែលបែកទ័ពតែមកនោះ ។

ឡុកស៊ុនថា យើងមិនយកទោសទេ ដែលប្រើទៅធ្វើការគ្រានេះ គឺប្រាថ្នាចង់ដឹងកម្លាំងនឹងកលសឹកព្រះចៅឡៅពី ក៏បានឃើញអស់ហើយ អ្នកកុំវិតក្កឡើយ យើងនឹងគិតកយឲ្យបែកទាល់តែបាន ។ ឈើសេង, តេងហាងថា យើងខ្ញុំបានដឹងច្បាស់ជាព្រះចៅឡៅពីមានទាហានខ្លាំងពូកែច្រើនណាស់ នឹងប្រាថ្នាកយឲ្យបែកនោះឃើញថាមិនងាយ ក្រែងខូចខាតទាហានច្រើន ។

ឡុកស៊ុនព្រះហើយក៏អស់សំណើចហើយថា ប្រវេណីធ្វើសង្គ្រាមរមែងមានស្លាប់ស់ជាធម្មតា តែអ្នកមានតម្រិះប្រាជ្ញាចេះគិតឲ្យខូចតិច បានច្រើន ប្រការខ្ញុំបេងជាចៅបញ្ញាក៏មិនបានមកធ្វើការផងទេ យើងនឹងខ្លាចថ្វី វេលានេះគឺទេវតាឲ្យទំនងយើងមានបន្ទោះនឹងយកជ័យជំនះជាទីរុងរឿង នៃព្រះចេស្តាព្រះចៅស៊ុនគួនហើយ ។ ក៏ឲ្យប្រមូលនាយទ័ពនាយកងមកប្រជុំគ្នា ទើបឡុកស៊ុនចាត់ឲ្យជួបហៀនជានាយកងខាងទ័ពទឹក មានទូកផ្ទុកចម្បើងជាយ៉ាងច្រើន ឯខាងទ័ពគោកចាត់ហាន់តុងឲ្យ

លើកទាហានៈ ពួកទៅចាំវាយទ័ពផ្លូវទិសឧត្តរ ចាត់ដំរីថាយឲ្យលើកទាហាន ពួកទៅចាំវាយទ័ពផ្លូវទិសទក្សិណ ឲ្យទាហានមានចាយក្រៀមជាអាហារបង្ការ ដែកក្បូងចងគប់ចម្បើង ហើយរើចាំសរដាក់ក្នុងដៃស្ពាយបន្ទាយឈរខាងគ្រប់ខ្នងចេញទៅ ដល់ថ្ងៃស្អែកពេលយប់មានខ្យល់ជំនោរធ្លាក់ ឲ្យទាហានទ័ពគោកទ័ពទឹកព្រមគ្នាវាយចូលទៅឲ្យដល់បន្ទាយទាំង៤០អន្ទើ ហើយឲ្យបេកភ្លើងដុតឲ្យឆេះឡើងគ្រប់បន្ទាយ បើទ័ពនោះបែកវេលាណាឲ្យអស់ពលគ្នា តាមដេញចាប់ព្រះចៅឡៅពីឲ្យបាន ទាហានគ្រប់ក្រុមក៏ស្តុះគ្នារៀបចំធ្វើតាមបង្គាប់ ។

ឯព្រះចៅឡៅពីគង់លើកៅអីស្តីពជការចាត់ទាហានទឹងលើកទ័ពចេញច្បាំងមិនទាន់ស្រេចការ បង្កើតអស្ចារ្យអាកេទទង់ជ័យដែលដោតរឹងនៅមុខព្រះទីនាំងគ្មានខ្យល់បក់ជាខ្លាំងសោះ ដងទង់ជ័យនោះក៏បាក់ធ្លាក់ចុះដល់ដីព្រះចៅឡៅពីព្រួយព្រះទ័យណាស់ ត្រាស់សួរធៀតទីប្រឹក្សាថា អាកេទនេះកាចឬជាប្រការម្តេច ធៀតក្រាបទូលថា អាកេទនេះកាចណាស់ មុខជាឡុកស៊ុនទឹងលើកទ័ពមកវាយយកជ័យជំនះយើងហើយ ព្រះចៅឡៅពីថាច្បាំងគ្រាណាយើងក៏វាយបែកគ្រប់គ្រាពុំដែលខាន ទាហានពួកវាស្លាប់ច្រើនណាស់ហើយ យើងទឹងខ្លាចបុំមិនមែនវាទឹងលើកមកវាយយើងទេ និយាយមិនទាន់ផុតមាត់ មានទាហានពួកបន្ទាយខាងលើចូលមកទូលថា

(នៅមានត)

# ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត

ដែលមាននៅពុទ្ធសាសនបណ្ឌិត្យ

លោក ញ៉ុក-ថែម រៀបរៀង

(៩)

បំណងជើង: "សាស្ត្រា ក្រមច្បាប់"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធន៍: ពាក្យកាព្យ : បទកាកគតិ ។

ប្រភពរឿង: គ្រូទូន្មានសិស្ស តាមប្រពៃណី ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១០ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពី វត្តវេឡុការាម ចុះលេខឯកសារ ១៣៧៦ ។

អត្ថបទដើម:

៙ អញខ្ញុំទូនអង្គ ទន្ទាបក្រញូញក្រុង ក្រញូ
ក្រាបអាត្មា លុតលើកករកប ប្រៀបប្រប
ហត្ថា ដោមដាក់សិរសា ក្រាបថ្វាយបង្គំ ។
សម្តេចព្រះស្រី មុនីធិបតី សព្វញ្ញជាធំ គ្រូ
គ្រប់ទេវា សុរាឥន្ទ្រព្រហ្ម ស្តែងស្តេចតែងបំ-

ប៉ាក់បបសប្បាយ ៗ . . . . . . . .

. . . . . . . . . . . . . ៕ល៕

អត្ថបទបញ្ចប់: មួយសោតទៀត រករៀនអាគម មន្តព្រះគាថា

នូវថ្នាំឱសថ ឆាប់ជុតនោះណា គ្រាន់នឹងរក្សា

សន្តានផៅផង ៗ ខិតខំសង្វាត ឲ្យចេះក្បួន

ខ្នាត ទៀងទាត់ជាមុន ចេះមើលគ្រោះយាម

វាយតាមទំនង ឫក្សពារពេលផង ការគប់វិជ្ជា

ឲ្យរៀនឲ្យសព្វ ឲ្យស្លូតស្ងៀមស្ងប់ សង្រួម

ឥន្ទ្រិយ ឲ្យសមគួរគាប់ តាមច្បាប់អំពី បុ-

ពណមុនី តែងទុកឲ្យស្រាប់ ៗ ពាក្យពិត

វិសាល វិសេសត្រកាល គ្រប់ជាច្បាប់

ឲ្យអស់សិស្សផង រៀនវែងត្រងត្រាប់ បរិបូណ៌

ស្រេចស្រាប់ អម្បាលនេះហោង ៗ

X

X X

ចំណងជើង: „សាស្ត្រាច្បាប់ត្រូវធម៌„(១)

អ្នកនិពន្ធ: រកពុំទាន់ឃើញ

កាលបរិច្ឆេទ: គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យៈ បទកាកគតិ

ប្រភពរឿង : ឪពុកទូន្មានកូន តាមប្រពៃណីពីព្រេងនាយ ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹតក្រៃមានលេខសន្លឹក ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តវេឡុកាកម វែរ លេខ ១.៣៧៦ ។

អត្ថបទផ្ដើម: ឱនេះបទកាកគតិ ។ កូនអើយមកអាយ ឪពុក និងប្រាយ ប្រាប់ច្បាប់គ្រូធម៌(?) កូនស្ដាប់ឪពុក រៀនទុកឲ្យចាំ(?) មន្ទិលគ្រូធំ ច្បាប់នេះមិនឆាយ ។

---

(១) ច្បាប់នេះ តាំងពីចំណងជើងជាដើមទៅ មិនដឹងជាគេចង់ពោលថា "ច្បាប់ត្រូវធម៌ឬច្បាប់គ្រូធម៌ ឬច្បាប់គ្រូធំ"? ប្រសិនបើគេពិនិត្យមើល ពាក្យពេចន៍ ក្នុងផ្ទៃអត្ថបទ គេអាចយល់ថា "ច្បាប់គ្រូធំ" ឬច្បាប់មន្ទិលគ្រូធំ "ឬច្បាប់បណ្ឌិតគ្រូធំ"? ផ្ទុយពាក្យបញ្ជាក់ក្នុងក្បួនទី១ ខាងលើនេះស្រាប់ ។ ឯចំណងជើងខាងលើនេះ សូមអ្នកអានសំគាល់ទុកជាបណ្ដោះអាសន្នសិន ។ ប្រសិនបើមានច្បាប់ផ្សេងទៀតយកមកផ្ទៀងផ្ទាត់ទៀងផង ប្រហែលរកឃើញនូវចំណងជើងពិតប្រាកដបាន ។ សាស្ត្រានេះមានកំហុសច្រើនអន្លើណាស់ ទាំងពាក្យពេចន៍ទាំងចុងក្លួន ។

កូនអើយលោកថា មានទ្រព្យក្ដីណា មិនដូច
មានបាយ ទោះមានដីពុក មិនដូចមានម្ដាយ
មានញាតិភាន់ឡាយ មិនដូចគូគ្រង ។ល។

**អត្ថបទបញ្ចប់:**

ច្បាប់នេះប្រពៃ ត្រូវធម៌ថ្លៃ អាចារ្យដំណាល
ដំណើរពីព្រេង នេះឯងត្រកាល ទោះ
ចាស់ក្មេងពាល ឲ្យរៀនឲ្យស្ទាត់ ។ ឲ្យចេះ
ឲ្យចាំ មន្ទិលគ្រូធ័ម ប្រសើរជាក្ដាត់ ទោះកើត
ក្ដីហោង រៀនឲ្យចាំមាត់ មិនដែលភ្លាំងភ្លាត់
កាត់ក្ដីបានហោង ។ ពាក្យនេះស្រួលស្រេច
ពាក្យច្រើនកន្ទេច កន្ទៀតកន្ទង ចំណោះចំណាប់
ប្រចាំប្រចង ទ្រគោះទ្រគង ទំនងដោះស្រាយ ។
ត្រូវធម៌ថ្លៃថ្លា ព័កងកនក្រែ(?) ព្រឹទ្ធព្រេងនិយាយ
ក្រៈណាស់មិនឆាយ ក្រណាស់មិនឆាយ(?)
ចំណាំបរិយាយ ច្បាប់នេះមិនឆាយ ពីព្រេង
បូរាណ ។

X
X X

ចំណងជើង : "សាស្ត្រា សុខ មាណព "(១)

អ្នកនិពន្ធ : អ្នកឧកញ៉ា ធម្មាធិបតី បទុ ។

កាលបរិច្ឆេទ : រជ្ជកាលព្រះបាទអង្គដួង ( ក្រុងឧដុង្គ ) ។

របៀបនិពន្ធ : ពាក្យកាព្យ : បទកាកគតិ និងព្រហ្មគីតិ ។

ប្រភេទរឿង : ជាតក ១ ប៉ុន្តែគ្មានបញ្ជាក់ពីការសជាតិទេ ឯផ្ទៃរឿង ដំណាលពីសកម្មភាព នៃពោធិសត្វកសាងបារមី ដូចជាជាតកនានាដែរ ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ១០ សន្លឹក ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្ត វេឡុកាពមដែរ ចុះលេខ ១.៣៧៦ ។

អត្ថបទដើម : ៙ នេះបទកាកគតិ ។ គេជគេជៈខ្ញុំ សូម
សរសើរស- ម្ដេចកគក់ សូមទេពទិសទស
សោឡសសួគ៌ា ចំរើនទីឃា យុយឺនឡើ ។
កាលពជ្រក្សត្រា ព្រះនាពយណ៌ពមា ធិពជ

(១) សាស្ត្រាសុខមាណព នេះប្រហែលនៅមាន អត្ថបទតទៅទៀត ឯច្បាប់នេះ អស់អត្ថបទត្រឹមប៉ុណ្ណោះ ឃើញថាមិនទាន់ចប់រឿងទេ ហើយមិនស្រួបតាមគោលការណ៍ នៃចលនាជាតកទាំងឡាយ ដែលគេតែងតែបញ្ចប់រឿងដោយការសជាតិ ។

ធិបតី សុរិយោពារពង្ស ឯកអគ្គចក្រី ចក្រវត្តិ

សិរី សុរិយោវង្ស ៗ . . ។ល។ . .

អត្ថបទបញ្ចប់ មាណពព្ភពាក្យ ជាន៍ស្រដីហាក់ មានចិត្ត

សង្ស័យ គិតក្រែងពុំមាន ធនធានដល់ដៃ

ទើបឆ្លើយថាហៃ អ្នកជាងតាំងឡាយ ចាំខ្ញុំ

ទៅយក មាសនាំវិលមក ឲ្យអ្នកចែកចាយ

អស់អ្នកដែលធ្វើ កាប់ឈើនៅអាយ កុំអ្នក

តាំងឡាយ បារម្ភឡើយណា ៗ ទើបជាង

ឆ្លាសឆ្លើយ ថាហៃអ្នកអើយ. . . .

. (បាត់) យកមកឲ្យខ្ញុំ ពោះអ្នកឯណា

គ្រាប់បរកតម្រាប់ កុំបីឲ្យឆ្ងាយ តំណទៅ

ឯក្រោយ ជាសូរេចម៉្ងះហោង ៗ

X X

បំណាងជើង: « ក្រាំងស្តុតីព្រះជាម្ចាស់ »(១) (ព្រះអាទិទេព)

---

(១) ក្រៅពីពាក្យស្តុតីព្រះព្រហ្ម មានពាក្យស្តុប្រស្តុតី ព្រះអាទិទេពដទៃទៀត ប្រចាំទិសផ្សេងៗ ។ មានពាក្យស្តុតីធំ សំរាប់ទិសបស្ចិម ថ្វាយព្រះឥស្វរ ។ មានបទឧទស្តារព្រះរដ្ឋព្រៃ ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះពិស្ណុការ ព្រះចតុលោកបាល. . . . មានបទឧមស្តារ ព្រះស្រីអារ្យមេត្រី ។ មានបទថ្វាយជ័យ សូមជ័យពីព្រះអាទិទេព នៅខាងចុងនៃក្រាំងនេះ

អត្ថបទទាំងប៉ុន្មាន ក្នុងក្រាំងស្តុតីនេះ មានវិបត្តិទាំងអក្ខរាវិរុទ្ធ ទាំងឃ្លាល្បះទាំងពាក្យពេចន៍ខ្លះ អ្នកអានមិនអាចយល់ន័យ បានច្បាស់លាស់ទេ ។

អ្នកនិពន្ធ : គេពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកម្រងកែវ ។

ប្រភពរឿង : គម្ពីរត្រៃវេទ របស់ពួកព្រាហ្មណ៍ ។

លក្ខណៈឯកសារ : ក្រាំងសរសេរដោយទឹកខ្មៅ ។ ក្រាំងនេះមាន ៣៥ សន្លឹក ។ ឯកសារនេះគេទុកក្នុងបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ ចុះលេខ ១.៤៤២ ។

អត្ថបទផ្តើម : ៙ ទិសបូពិ ៖ ពាក្យស្តុតិព្រះព្រហ្ម ។ នមស្សការ ជ័យពាលប្រាបភាល ជ័យមិលយល់ទេព្តាផងកុំបីប្រែ ជ័យៗជខែ ជ័យៗដំឆ្នាំ ជ័យៗកាំធ្បជារ ខែល សារពើ ជ័យៗហោរែង ហោរៃ ជ័យៗប្រថពីផ្ទៃក្រោម ជ័យៗរូបឆោមដូចទេព្តា ជ័យៗសេនាទូរអស់បរិពារ ជ័យៗទូរអស់សង្ហារយុទ្ធ ជ័យៗវេសិទ្ធីឈ្នះចម្បាំង ជ័យៗកំឡាំងដូចពេជ្រ ជ័យៗតាបសគរូ ជ័យៗខែលមូទូតតរង្គល . . . . . . . ។ល។ .

អត្ថបទបញ្ចប់ : អម្ពត្យវិនាសមរណ៍ ឈ្នះប្រាបរាបខ្ចាយខ្ទេរ ឈ្នះអស់ពលវីរ អស់ទាំងនគរជលធី ឈ្នះ អស់អាកាសធរណី ឈ្នះអស់ពៃរី សូមថេរស-ម្រិទ្ធីបេស្កា សូមបានសោយរាជ្យមហិមា គ្រង រាស្ត្រប្រជា ទីឃាយុះដល់កាលហោង ។ សូម បានសេពសុខបរិពារ មានបុណ្យសម្ភារ អធិក ពន្ធឹកមហិមា សូមល្បីទាំងអស់ទិសទី ជាឯក រាជាធិរាជ ឥស្សរជាទី ពោះសត្រូវទឹងមកពាធា សូមឲ្យឈ្នះ ប្រាកដវិនាសស្អែងហោង ។

X

X X

បំណាងដើង : « ក្រាំងតម្រាទៀងស័ក ធ្វើស្បូវក្រ . . . »

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធន៍ : ពាក្យរាយ ។

ប្រភេទរឿង : តម្រាទៀងស័កតាមក្បួនហោរាសាស្ត្រពីបុរាណ ។

លក្ខណៈឯកសារ : ក្រាំងសរសេរដោយទឹកខ្មៅ ។ ចំនួនសន្លឹក៤៥

សទ្ទឹក ៗ ឯកសារនេះ បានមកអំពីណា គ្មាន
បញ្ជាក់ ៗ ពុទ្ធសាសនបណ្ឌិត្យបានចុះលេខ
១ ២៤៣ ៗ

**អត្ថបទដើម :** ៥ សង្ខារ្យ : ដោះនូវគូរគត្តាឡើងស័កឯណា ៗ
គឺ ឲ្យតាំងចុល្លសករាជឆ្នាំនោះចេញ ហើយ
យក ២៩២.២០៧ គុណ ហើយយក ៣៧៣
បូក ហើយយក ៨០០ ហារ លទ្ធនោះ យក ១
បូកឡើង ជាអហគុណឡើងស័កត្រាទុកសេស
នោះ លុបចុះដើងហារ ជាក្រមុតពលឡើងស័ក
ត្រាទុកក្រោមអហគុណ ៗ តាំងអហគុណ
ចេញហើយ ឲ្យយក ២.៦១១ បូកហើយយក
៣.២៣២ ហារ សេសនោះជាឧចពលឡើងស័ក
ត្រាទុកក្រោមក្រមុតពល ៗ . . . ៗលៗ.

**អត្ថបទបញ្ចប់ :** ដោះនូវដឹងថ្ងៃត្រង់ ឆាយាអម្បាលមាណ ឲ្យ
តាំងសំផុតព្រះអាទិត្យថ្ងៃនោះចេញ ដោះពសី
០ ១ ២ } ឲ្យយកពីរហារ លទ្ធជាឆាយាណ្ណនាដោះ

រាសី ៣ ៤ ៥ ឲ្យយក ៣ លុបរាសីសេសនោះ យក
ទៅលុបត្រីចក្រសេស ឲ្យយក ៤ ហារ លព្ធ
ជាធាយាហិណ្ណរាសីទាំង ៦ នេះ ស្រមោល
ហោលទៅខាងត្បូងខេយើងហោង ៗ នោះ
រាសី ៦ ៧ ៨ ឲ្យយក ៦ លុបរាសីសេស ជាធាយា
វណ្ណនា នោះរាសី ៩ ១០ ១១ ឲ្យយក ៩ លុប រាសី
សេសឲ្យយកទៅលុបត្រីចក្រ សេសជាធាយា
ហិណ្ណរាសីទាំង ៦ នេះ ស្រមោលចេញទៅខាង
ជើងខេយើងហោង ៗ វិសេសបាទលើជា
បាទជើងជាន់ បាទកណ្ដាលឲ្យយកដៈហារ
លព្ធជាអង្គុលី សេសយក ៦០ គុណ បូកបាទ
ក្រោមឡើងយក ៣០ ហារ លព្ធជាគ្រាប់ស្រូវ
សេសយក ២ គុណ ១០ ហារ លព្ធជាគ្រាប់ល្ង
សេសជាសរសៃសក់ ដឹងធាយាថ្ងៃត្រង់ស្មើរបេ
ហោង ៗ នោះចង់ដឹងធាយាជាន់ទ អង្គុលី
៩៨ អង្គុលី ១ ជាស្រូវ ៤ ស្រូវ១ ជាល្ង៦ ល្ង១
ជាសក់ ១០ សរសៃហោង ៗ

# ជីវប្រវត្តិសង្ខេប

## នៃសហជីវិន ហ៊ិល-ស៊ុំផា

(ផ្ដល់ទៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យថ្ងៃទី ២៩ តុលា ១៩៦៦)

សហជីវិនហ៊ិល-ស៊ុំផា កើតនៅថ្ងៃ ២៣ មេសា ១៩២៦ នៅផ្សារក្រោម ស្រុកបាកាន ខេត្តពោធិសាត់ ពុកឈ្មោះ ម៉ៅ-ហ៊ិល ម្ដាយឈ្មោះ ផេង-លិញ ។ កាលនោះលោក ម៉ៅ ហ៊ិល ជាបិតា ដែលមានកំណើតនៅស្រុកកោះសូទិន (កំពង់ចាម) ជាលេខាធិការរ៉េស៊ីដង់ បានផ្លាស់ទីកន្លែងធ្វើការទៅកាន់ខេត្តជាច្រើន មានខេត្តតាកែវ, ពោធិសាត់, កំពង់ស្ពឺ និងកំពង់ចាមជាដើម ។ សហជីវិនហ៊ិល-ស៊ុំផា កាលនៅកុមារបានចូលរៀនដំបូងនៅកំពង់ស្ពឺ និងកំពង់ចាម លុះឪពុកស្លាប់ទៅ ក៏បានមកជ្រកអាស្រ័យជាមួយឪពុកមា ធ្វើការក្នុងក្រុមប៉ូលិសនារាជធានីភ្នំពេញ ហើយបន្តការសិក្សានៅសាលាបឋមសិក្សា ព្រៀងស្វា-ប្លាំងភ្នំពេញ (គឺអគារមហាវិទ្យាល័យគរុកោសល្យកន្លែងអនុស្សាវរីយ៍ឯករាជ្យសព្វថ្ងៃ) ។ លុះប្រឡងវិញ្ញាបនប័ត្របឋមសិក្សាបារាំង-ខ្មែរ ជាប់ក៏ទៅរៀននៅអនុវិទ្យាល័យម៉ីស្ហ ។ រៀនបានបីឆ្នាំ គឺឆ្នាំ ១៩៣៧ ដល់ ១៩៤០ ប្រឡងសញ្ញាប័ត្រប្រឹវេ រួចក៏ចូលរៀនក្នុងសាលារដ្ឋបាលតុលាការខ្មែរ (Ecole d'Aministiation Cambodgienne) ផ្នែកតុលាការ ចំនួន ២ ឆ្នាំ បានជាប់សញ្ញាប័ត្រសាលានេះ ។

នៅថ្ងៃទី ៣១ មីនា ១៩៤៣ សហជីវិន ហែល · ស៊ុំផា បាន ចូលធ្វើការរាជការ ដោយទទួលឋានៈជាសមុហបញ្ជីថ្នាក់លេខ ២ បំរុងរាជការ នៅសាលាដំបូងកំពង់ធំ ។

នៅថ្ងៃ ១១ កញ្ញា ១៩៤៥ បានឡើងកាន់ឋានៈជាមន្ត្រីបំរុងរាជការ Mandarin stagiaire ហើយកាន់មុខងារជាសុភាចារបុរស នៅសាលាដំបូងសៀមរាប ។

នៅថ្ងៃ ៤ វិច្ឆិកា ១៩៤៦ សហជីវិនហែល ស៊ុំផា បានរៀបមង្គលអាពាហ៍ពិពាហ៍ ជាមួយនាងគាត់ គីវគូរ ហៅ កុឡា ជាកូនអ្នកជំនួញនៅផ្សារសៀមរាប ឈ្មោះគាត់ · ប៊ុនហ៊ូវ អ្នកស្រីហ៊ុ · មុច ។

នៅថ្ងៃ ១០ កញ្ញា ១៩៤៧ បានឡើងកាន់ឋានៈជាចៅក្រមពេញទីថ្នាក់លេខ៤ ហើយផ្លាស់មកភ្នំពេញ កាន់មុខងារជាអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ (Commissaire-Adjoin du Roi) នៅក្នុងឆ្នាំដដែលនេះ ដល់ថ្ងៃ ៤ កក្កដា ១៩៥០ ក៏បានឡើងមួយថ្នាក់ គឺបានឋានន្តរសក្តិជាចៅក្រមថ្នាក់លេខ ៣ ។ កាលនោះបានទទួលគ្រឿងឥស្សរិយយសមេដាយអស្សរិទ្ធិមុនីសារាភណ៍ ។

នៅថ្ងៃ ៩ វិច្ឆិកា ១៩៥១ បានផ្លាស់ទៅធ្វើជា សុភាចារបុរសនាសាលាដំបូងខេត្តកំពង់ចាម ។

នៅថ្ងៃ ១៣ មេសា ១៩៥.៣ បានឡើងកាន់ឋានៈជាចៅក្រម

ថ្នាក់លេខ ២ ហើយបានគ្រឿងឥស្សរិយយស មេដាយប្រាក់ការងារ ។

នៅកំពង់ចាមបាន ២ ឆ្នាំ គឺមកដល់ឆ្នាំ ១៩៥៥ ក៏បានផ្លាស់មកកំពត កាន់មុខងារជាអគ្គព្រះរាជអាជ្ញារង អមសាលាឧទ្ធរណ៍វិញ ហើយនៅថ្ងៃ ១៣ មេសា ១៩៥៥ ក៏ទទួលឋានន្តរសក្តិជាចៅក្រមថ្នាក់លេខ ១ ។

ក្នុងឆ្នាំដដែលនេះ បានមកកាន់មុខដំណែងជានាយក្រមការប្រមូលឯកសារ និងការផ្សាយខាងច្បាប់យុត្តិសាស្ត្រ និងនីតិកម្ម ( Chef de service de Documentation et des Publications judiciaires, de Juris prudence et de Législation ) នៅក្នុងឆ្នាំដដែលនេះ កើតមានច្បាប់ចេញមកតម្រូវឲ្យដំឡើងមួយថ្នាក់ គឺដល់ឋានន្តរសក្តិជាចាងហ្វាងសាលាដំបូងថ្នាក់លេខ ៣ ។

នៅថ្ងៃ ២៦ កុម្ភៈ ១៩៥៨ បានកាន់មុខដំណែងជានាយខុទ្ទកាល័យក្រសួងយុត្តិធម៌ ។

នៅថ្ងៃ ១៣ មេសា ១៩៥៨ បានឡើងឋានន្តរសក្តិជាចាងហ្វាងសាលាដំបូងថ្នាក់លេខ ២ ។

ក្នុងឆ្នាំ ១៩៥៩-៦០ សម្តេចព្រះ ឧបាធ្យាយ សីហនុ ព្រះប្រមុខរដ្ឋទ្រង់សព្វព្រះរាជហឫទ័យទាញយកសហជីវិន ហែល-ស៊ុំផា ឲ្យធ្វើជាអ្នកនិពន្ធនាយករងនៃសារពត៌មាន អ្នកជាតិនិយម ដែលឲ្យនៅកាន់ឋានៈផ្លូវការជាទីប្រឹក្សាអមសាលាឧទ្ធរណ៍បំរើសាលាក្រុមតោទ ។ កាលនោះ បាន

គ្រឿងឥស្សរិយយសមេដាយអស្សរិទ្ធិ សុវត្ថា ។

នៅថ្ងៃ ១៣ មេសា ១៩៦០ បានឡើងឋានន្តរសក្តិជា ចាងហ្វាងសា-លាដំបូងថ្នាក់លេខ ១ ហើយបានគ្រឿងឥស្សរិយយស មេដាយអស្សរិទ្ធិព្រះរាជាណាចក្រកម្ពុជា (Chevalier de l'Ordre Royale du Cambodge)

នៅថ្ងៃ ១៤ មេសា ១៩៦២ សម្តេចសហជីវិនទ្រង់បានជ្រើសរើសដោយផ្ទាល់ព្រះហស្តឲ្យសហជីវិន ហែល-ស៊ុំផា ឈរឈ្មោះជាបេក្ខជនសង្គមរាស្ត្រនិយម ឲ្យរាស្ត្រះបោះឆ្នោតជ្រើសរើសតាំងជាតំណាងរាស្ត្រដោយបានផ្អែកទៅលើគុណបំណាច់ពិសេសចំពោះរាស្ត្រ មាតុភូមិ និងសង្គមរាស្ត្រនិយម ដូច្នេះចាប់តាំងពីថ្ងៃ ២០ មិថុនា ១៩៦២ គម្រប់ ២ ឆ្នាំ សហជីវិន ហែល ស៊ុំផា កាន់ឋានៈជាតំណាងរាស្ត្រ មណ្ឌលកំពង់ដីក្រហម (ស្រុកស្វាយទីគម និង ដីក្រហម) ខេត្តសៀមរាប ។

ក្នុងពេល ២ ឆ្នាំនេះ បានឡើងឋានន្តរសក្តិជា ចាងហ្វាងសាលាដំបូងផុតលេខនៅថ្ងៃ ១៣ មេសា ១៩៦៣ ហើយនិងជាទីប្រឹក្សាសាលាវិនិ-ច្ឆ័យថ្នាក់លេខ ៣ នៅថ្ងៃ ១៣ មេសា ១៩៤៥ ព្រមទាំងបានគ្រឿងឥស្សរិយយស ២ ទៀត ១- ទីសេនាសម្តេចព្រះមហាក្សត្រិយានី, ៤- ទីធិបតិន្ទព្រះរាជអាណាចក្រ មុនីសារភណ៍ (Commendeur de l'Ordre Royale de Monissaraphon)

នៅក្នុងកំឡុងពេល ៤ ឆ្នាំនេះ សហជីវិន ហ៊ែល ស៊ុំផា បានចូលរួមរួមក្នុងសមាសភាពគណៈរដ្ឋមន្ត្រីក្នុងឋានៈជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងការងារ ចំនួន ២ ខែ គឺពីថ្ងៃ ៦ សីហា ១៩៦៦ ។

សរុបសេចក្ដីទៅ សហជីវិន ហ៊ែល-ស៊ុំផា បានចូលធ្វើការរាជការក្នុងតុលាការតាំងពីឆ្នាំ ១៩៤៣ ដល់មកឆ្នាំ ១៩៦៦ នេះ បានឡើង ១១ ថ្នាក់ ដោយរំលងឋានៈជាក្រឡាបញ្ជីនិងចៅក្រមថ្នាក់លេខ ១ ហើយក្នុងមួយថ្នាក់ៗ នៅយ៉ាងយូរតែបីឆ្នាំទេ ។ ម្យ៉ាងទៀត នៅរដ្ឋសភាគេត្រូវដំឡើង ឋានន្តរសក្តិអគ្គរាជការជាតំណាងរាស្ត្រ ដែលដល់ពេលវេលាត្រូវឡើង ឲ្យត្រូវឡើងដោយស្វ័យប្រវត្តិ ។

ឯគ្រឿងឥស្សរិយយសបានទាំងអស់ ៦ គឺ ចាប់តាំងពីដំបូង :

១- អស្សប្ញទ្ធិមុនីសារាភណ៍

២- វឌ្ឍនការប្រាក់

៣- អស្សប្ញទ្ធិស៊ីវិល

៤- អស្សប្ញទ្ធិនៃព្រះរាជាណាចក្រកម្ពុជា

៥- សេនានៃសម្ដេចព្រះមហាក្សត្រិយានី

៦- ធិបតិន្ទ មុនីសារាភណ៍

អំពីស្នាដៃខាងអក្សរសាស្ត្រ សហជីវិន ហ៊ែល-ស៊ុំផា បានតែងប្រលោមលោក ៣ គឺ:

១. ទោសបិទមុខ ក្នុងឆ្នាំ ១៩៨១

២- ទោសលួចប្រាក់ ក្នុងឆ្នាំ ១៩៨២

៣- ទោសក្ដីត្បៀន ក្នុងឆ្នាំ ១៩៨៤

សៀវភៅបកប្រែឈ្មោះ :

- ប៉ូលនិងវីរហ្សីនី ឆ្នាំ ១៩៥៥

សៀវភៅច្បាប់ឈ្មោះ :

- ពន្យល់ច្បាប់ ឆ្នាំ ១៩៥៧ ពីលេខ ១ ដល់ លេខ-១០

- វចនានុក្រមច្បាប់ពិសេសចំពោះបទល្មើសអាជ្ញា ឆ្នាំ ១៩៦៦

សៀវភៅពិចារណា :

- គួរពិចារណាដើម្បីចេះខ្មែរ ឆ្នាំ ១៩៦៥ ស្នាដៃឯទៀតជាគុណបំណាច់ចំពោះជាតិមានតែ :

១ - បានចូលជាសមាជិកសង្គមរាស្ត្រនិយម

២- បានចូលជាសមាជិក សមាគមអ្នកនិពន្ធខ្មែរ កាន់ឋានៈជាអនុប្រធាន ១ ឆ្នាំ ជាប្រធាន ៨ ឆ្នាំ

៣ - បានចូលជាសមាជិក សមាគម អតីតសិស្ស វិទ្យាល័យ អនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ ។

៤ - បានចូលជាសមាជិក សមាគមយុត្តិសាស្ត្រខ្មែរ

៥ - បានចូលជាសមាជិក សមាគមកំចាត់រោគឃ្លង់

៦ – បានបង្រៀនច្បាប់នៅសាលាអប់រំមូលដ្ឋាននានាទេទូបាទី

៧ – បានបង្រៀនភាសាខាងតុសាការ និងច្បាប់នៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៨ – បានទទួលបេសកកម្មពីព្រះរាជរដ្ឋាភិបាល ទៅកាន់ប្រទេសក្រៅព្រមទាំងបានទស្សនាប្រទេស : ១ បារាំង ២- អង់គ្លេស ៣- បែលហ្ស៊ិក ៤- ហុល្លង់ ៥- ស៊ុីស ៦- សៀម ៧- យៀកណាមខាងត្បូង ៨- ក្រុងហុងកុង ៩ ប្រទេសជប៉ុន ១០- សហរដ្ឋអាមេរិក ១១- ប្រទេសអ៊ីរ៉ង់ ១២- ប្រទេសអ៊ីសរ៉ាឯល ១៣- ឥណ្ឌា ១៤- សហភាពសូវៀត ១៥- ប្រទេសអាល្លឺម៉ង់ខាងកើត ១៦- ហ្គ្រែស ១៧- អេហ្ស៊ីប ១៨ យៀកណាមខាងជើង ។

៩ – បានចូលរួមក្នុងចលនាយុវជន មានកងយុវជនឥណ្ឌូចិន កងយុវជន ចលនាយុវជនរាជសង្គមនិយមខ្មែរ ។ បានទៅរៀននៅសាលាអប់រំ យុវជននៅ ដាងទៀត និង ទេទូបាទី ។

១០– បានជួយឧបត្ថម្ភសមាគមរក្សាកេរ្តិ៍ខ្មែរ "សិល្បៈ"

១១– ក្នុងពេលដែលធ្វើតំណាងរាស្ត្រ បានណែនាំឲ្យបង្កើតសមាគមចំរើនឃុំ ១៣ កន្លែង បានណែនាំសមាគមទាំងនេះ ឲ្យធ្វើគិលានដ្ឋាន ៤ កន្លែង ធ្វើសាលារៀន ៣ កន្លែង ធ្វើអនុស្សាវរីយ៍ ១ កន្លែង ធ្វើស្ពាន ៧ កន្លែង លើកថ្នល់ ៣ កន្លែង ចាក់ថ្មថ្នល់ ខេត្ត ១ កន្លែង ស្មើ

ជំនួយសង្គហជាតិជូនអ្នកក្រីក្រនេះឆ្នុះ ១៦០ ខ្នង ១ កន្លែង ជូនគ្រួសារអ្នករងគ្រោះបាញ់ ១ កន្លែង ស្នើសុំសម្តេចឪប្រទានជួយស្រោចស្រព់អ្នកស្រុក ១.០០០ នាក់ ឲ្យបានត្រពាំង ត្រពាំងរួចនិងផ្លូវបុរាណ ដែលរាជការបាន ឲ្យជាសម្បទានទៅឯកជនម្នាក់ ១ កន្លែង ជួយដោះប្រដាពលរដ្ឋខ្លះ ឲ្យរួចពីការរំលោភបម្លាប់ ២ កន្លែង ស្នើសូមឲ្យរាជការដោះស្រាយបញ្ហាទឹក ២ កន្លែង ដែលនាំអ្នកស្រុកឲ្យធ្វើផ្កា ទិវបុណ្យកសាងឃុំ ១៥ កន្លែង បាន ចូលរួមប្រជុំជាមួយគ្រួសារខ្មែរហែកប៉ែន ចូលរួមក្តីបេងម្តង ហែផ្កាកសាង សាលារៀនកាកំបុតម្តង បានធ្វើអន្តរាគមសូមឈើសង់សាលារៀន ១ កន្លែង ។ល។

១២– ចូលជាសមាជិកគណៈកម្មការនៃការសិក្សា ផ្នែកអក្សរ "ក" ហៅថាគណៈកម្មការវប្បធម៌ជាមួយសម្តេចព្រះពោធិវង្ស ។

១៣– ចូលរួមប្រជុំក្នុងការប្រជុំអក្សរសាស្ត្រ ជាមួយសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ព្រះនាម ជួន ណាត ។

ជាដើម . . . . . . ។

បញ្ចប់ជីវប្រវត្តិនេះ តែត្រឹមនេះសិន ។

ភ្នំពេញ ថ្ងៃទី ២៩ តុលា ១៩៦៦

X

X X

# រឿងពិសពស់ និង ពិសត្រី

(សហ. លី-ធាមតេង រៀបរៀងតាមឯកសារទំនៀមទម្លាប់)

សត្វពស់ល្បីថាជាសត្វមានពិសសាហាវណាស់ ប៉ុន្តែមានពស់ខ្លះដែរដែលឥតពិសខ្លាំងពូកែ ដូចជាពស់ព្រលិត, ពស់សាំងសៀ, ពស់ទឹក ៗលៗ ចំណែកសត្វត្រីវិញ មានត្រីខ្លះមានពិសបំណាច់ណាស់ដែរ ជាពិសេសគឺត្រីមានធ្នុង ដូចយ៉ាងត្រីអណ្តែង, ត្រីឆ្លាំងជាដើម ៗ

រឿងហេតុដែលនាំឲ្យពស់ខ្លះត្រីខ្លះ មានពិស, ត្រីខ្លះពស់ខ្លះឥតពិសនោះ ចាស់ព្រឹទ្ធាចារ្យបានប្រាព្ធជារឿងព្រេងមួយ (១) មានសេចក្តីនិទាន ដូចតទៅនេះ ៖

កាលនោះ មានថ្លាន់មួយជាអ្នកមានពិសខ្លាំងក្លាពន់ពេកណាស់ សព្វសត្វធំទាំងឡាយតែងកោតក្រែងឫទ្ធិរបស់ថ្លាន់នេះគ្រប់ ៗ គ្នា ៗ ចំណែកមនុស្សវិញ ក៏ល្បីរន្ទឺក្រែងអែងសត្វនេះគ្រប់ភូមិស្ថានដែរ ៗ កុំថាឡើយទៅដល់ថ្លាន់នេះបានចឹក, បានត្រោះពិស ឬ តែផ្កាល់ខ្លួន សូម្បីតែនៅសល់ជានដើង ហើយថ្លាន់នេះ ទៅលិទ្ធជានដើងនេះ ក៏ម្ចាស់ខ្លួនដែលទុកជាននោះត្រូវស្លាប់ដែរ ៗ ហេតុនេះហើយ បានជាពេលមួយ ព្រះរាជបុត្រីស្តេច បានលាព្រះបិតា ទៅលំហែព្រះកាយនៅក្នុងសួន

---

១- តាមលំនាំឯកសារលេខ ៩៦.០៥៧ លោក ចាប-រីន រៀបរៀង និងលេខ ២៧.២០៣ លោក ភិណា.គួរ រៀបរៀង ។

ឧទ្យាន ៗ គ្រាដែលព្រះនាងវិលត្រឡប់មកកាន់ព្រះរាជដំណាក់វិញ ព្រះនាងនៅសល់ស្នាមព្រះបាទា ជាប់នៅមាត់ស្រះស្រង់ ដែលព្រះអង្គបានផ្លាស់ព្រះពស្ត្រា យាងចុះទៅស្នានព្រះវារីកំសាន្តសប្បាយជាមួយស្រីព្រះស្នំ ៗ កាលនោះពស់ថ្លាន់មានឫទ្ធិបានវារទៅកាត់លើស្នាមព្រះបាទា ហើយលិទ្ធស្នាមនោះទៀត ។ ពេលជាមួយគ្នានេះ ព្រះរាជបុត្រីដែលយាងទៅដល់ប្រាសាទហើយនោះចុកចាប់យ៉ាងខ្លាំង ទោះបីពេទ្យហ្មណាមកប្រកបឱសថថ្វាយក៏ពុំត្រូវពុំស្រាកសោះ ៗ ទីបំផុតក៏ក្ស័យព្រះជន្មទៅ ៗ ព្រះវររាជបិតា ទ្រង់វិតក្កខ្លាំងណាស់ដោយទ្រង់ស្តាយព្រះរាជបុត្រីតែមួយ ព្រះអង្គក៏ទ្រង់ត្រាស់បញ្ជា ឲ្យនាម៉ឺនសព្វមុខមន្ត្រីរៀបពិធីតម្កល់សព ហើយធ្វើពិធីបុណ្យគគ្រឹកគគ្រេង យប់ ៧ ថ្ងៃ ៗ គ្រានោះ អ្នកស្រុកផងទាំងឡាយនាំគ្នាកកកុញទៅមើលព្រះរាជពិធី ព្រមទាំងទទួលនូវព្រះរាជទានដែលព្រះមហាក្សត្រទ្រង់មានសទ្ធាផង ៗ

សត្វស្រុកខ្លះ ដែលធ្លាប់ហិចហើររកចំណីតាមភូមិស្រុកដូចជាក្អែកជាដើម សប្បាយរីករាយណាស់ ព្រោះបានចំណីអាហារបរិបូណ៌ ក្អែកនាំគ្នាហៅករញ្ញៀវកងរំពង ប្រាប់គ្នីប្រាប់គ្នាឲ្យមកអាស្រ័យអាហារ ៗ ចំណែកពីសត្វថ្លាន់នោះវិញ កាលបើឃើញមនុស្សអ៊ូអរ សត្វផងហើរប្រវាត់ខ្វៀលឆ្វាត់ដូច្នោះ ឆ្ងល់ណាស់ ក៏ស្រែកសួរទៅក្អែកដែលកំពុងទំ

ស្រែកលើមែកឈើ ថា ៖

អើបងក្អែក ! បងក្អែកឯងដឹងទេ ហេតុអ្វីក៏គេផ្អើលនោះឡើងច្រើនម្ល៉េះ ?

ក្អែកឮថ្លាន់សួរដូច្នោះ ក៏ក្លែងឆ្លើយចំអកដើម្បីបន្អាប់ថ្លាន់វិញថា ៖

– ហ៎ះ បងថ្លាន់ឯងធ្វើជាមិនដឹងខ្លួន គេសប្បាយពីរឿងបងថ្លាន់ឯងហ្នឹ៎ !

ថ្លាន់ឮហើយប្រញាប់សួរបញ្ឈក់ថា ៖

– រឿងអី ខ្ញុំមានរឿងអី ?

ក្អែកបន្ថែមថា ៖

រឿងបងថ្លាន់ឯងធ្លាប់ល្បីថាមានពិសពូកែណាស់ បើគ្រាន់តែលិទ្ធស្នាមជើងនរណា អ្នកនោះទឹងត្រូវស្លាប់ដែរ ហើយឥឡូវនេះ បងថ្លាន់ឯងលិទ្ធស្នាមជើងរាជបុត្រី តែព្រះអង្គមិនស្លាប់ទេ បែរជាមានរាងកាយរឹតតែល្អស្រស់ឡើងទៀត ៗ ហេតុនេះហើយ បានជាស្ដេចឲ្យធ្វើបុណ្យសប្បាយទឹងជោគជ័យនេះ ៗ

ថ្លាន់ឮសួរតែប៉ុណ្ណោះ ក៏ស្រងាកចិត្ត លូនចេញពីមុខក្អែកភ្លាម ៗ ថ្លាន់ឈឺចិត្តណាស់ ព្រោះតាំងពីដើមមក នរណាក៏កោតខ្លាចខ្លួនដែរ ចុះបើឥឡូវបែរជាមានគេឈ្នះឫទ្ធិខ្លួនដូច្នេះ គួរឲ្យអាម៉ាស់មុខណាស់ ៗ គិតដូច្នេះភ្លាម ថ្លាន់លូនសំដៅទៅរកបឹងមួយដែលកំពុងមានទឹកជន់ជោរ

ទៀងលិចពេញព្រៃផ្សៃ នៅជិតខាងនោះ ៗ សត្វជាតុទាំងឡាយកំពុងពួនជ្រកទឹងគុម្ពោតព្រៃខ្លាចស្លាប់ដោយសារទឹកជំនន់ ៗ ថ្លាន់ទៅដល់ទីនោះហើយ ក៏យំឈឺចិត្តក្អួបញ្ចេញពិសខ្លួនចេញចោលឲ្យអស់ ដោយយល់ថា ទុកធ្វើអ្វីបើមិនបានការដដែល ៗ

ពេលនោះ ពស់ខ្លះដែលជ្រកនៅពួនកងគុម្ពោតព្រៃជិតនោះ ដូចជាពស់វែក ពស់ក្រាយ ពស់ស្នាទខ្យោនជាដើម ម្នីម្នានាំគ្នាមកក្រងយកពិសដែលថ្លាន់ក្អួចោលនោះភ្លាម ៗ ហេតុនេះហើយ បានជាពស់ទាំងនេះ មានពិសខ្លាំងក្លាណាស់ , ចំណែកពស់ឯទៀតដែលមិនបានទៅជិតក៏ប្រឹងត្រដរមកដណ្ដើមពិសទឹងគេដែរនោះ ខ្លះក៏បានបន្តិចបន្តួច ខ្លះក៏ទទេស្មោះ ក៏មាន ៗ

រីឯត្រីដែលរស់នៅក្បែរខាងនោះវិញ ប្រឹងនាំគ្នាត្របាក់ដណ្ដើមយកពិសពីថ្លាន់ដែរ ត្រីដែលយកបានពិសខ្លះនោះ មានត្រីអណ្ដែង ត្រីឆ្លាំង បានមុនគេ ឯត្រីឯទៀតៗ ក៏វំរូតរះមកយកពិសទឹងគេដែរ ម្ល៉ោះហើយបានជាប្រជ្រៀតគ្នាតាន់តាប់ ។ ត្រីណាដែលត្រូវគេត្បៀតខ្លាំង ក៏សំប៉ែតខ្លួនទាល់តែសព្វថ្ងៃ ដូចយ៉ាងត្រីកេស ត្រីក្រពាត់ ត្រីស្លាត ។ល។ គឺជាត្រីស្លាតនេះឯង ដែលត្រូវគេប្រជ្រៀតផ្ទប់ទៅទឹងថ្មទាល់តែសំប៉ែត

ស្អើងខ្លួនអស់ដល់សព្វថ្ងៃ ។ ឯត្រីក្រមមចំប្រជៀតទៅត្របាក់យកបាន ពិសមកហើយ ប៉ុន្តែហាក់ចេញមកវិញ ដោយមានគេឯងដណ្ដើមច្រើនពេក ក៏ជ្រុះបាត់ទៅវិញទៅ ។ ត្រីក្រមមយំស្ដាយពិសនោះខ្លាំងណាស់ ទាល់តែហើមមុខដល់សព្វថ្ងៃ បានជាមានពាក្យថា "មុខហើមមើលតែត្រីក្រមម" ។ កាលនោះ ត្រីសណ្ដាយហែលមកឃើញត្រីអស់នេះ មានរូបភាពប្លែក ខ្លះសំប៉ែត ខ្លះហើមមុខដូច្នេះ ក៏សើចចំអកឲ្យ សើចមិនតិចមិនតួច សើចដល់ទៅរយះមាត់ប្រេះដល់គុម្ពត្រចៀករហូតដល់សព្វថ្ងៃ ។

នេះហើយ ជារឿងពិសពស់ និង ពិសត្រី ។

X

X X

> អក្សរសាស្ត្រខ្មែរយើង ផ្នែកសាសនា, ទស្សនវិជ្ជា, វិទ្យាសាស្ត្រ, និរុត្តិសាស្ត្រ ជាបាលី និង សំស្ក្រឹត, មានតម្លៃ មានឋានៈដ៏ខ្ពស់ឧត្ដុង្គឧត្ដមណាស់ នៅលើផ្ទៃពិភពអន្តរជាតិ និង គង់ចំណោមនៃអត្ថបទនានាដ៏មានតម្លៃនៃវប្បធម៌សកលលោក ។
>
> សម្ដេចព្រះ នរោត្ដម សីហនុ
>
> ថ្លែងក្នុងពេលថ្វាយសញ្ញាបត្របណ្ឌិត
>
> ចំពោះសម្ដេចព្រះសង្ឃរាជ
>
> (ថ្ងៃ ២៨ ៥-៦៣)

# ពិធីបុណ្យឆ្លងព្រះវិហារ-បញ្ចុះខណ្ឌសីមា

នៃវត្តនិរោធរង្សី សង្កាត់ច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ នៃសម្ដេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

វត្តនិរោធរង្សីជាវត្តចាស់បុរាណមួយ រាប់ជាងមួយសតវត្សហើយ ដែលសង់នៅលើមាត់ច្រាំងទន្លេ ប៉ុន្តែត្រូវច្រាំងបាក់ដេញអស់ពីរដងហើយ ។ ឥឡូវនេះ ពុទ្ធបរិស័ទជើងវត្តមានព្រះមុនីកោសល សោម ឈឿង ជាចៅអធិការ បានរុះរើចេញអំពីច្រាំងបាក់មកសង់ខាងត្បូងជាប់ថ្នល់ជាតិ ជាខាងកើតផ្សារច្បារអំពៅចំនួន ១.៣០០ម ។ វិហារវត្តនិរោធរង្សីដែលព្រះមុនីកោសល សោម ឈឿង និងពុទ្ធបរិស័ទជើងវត្ត បានចាប់ស្ថាបនាតាំងពីឆ្នាំឆ្លូវឯកស័ក ១៩៤៩ លុះដល់ឆ្នាំ ១៩៥៩ ព្រះមុនីកោសលក៏ទទួលអនិច្ចធម្មទៅ ។ សំណង់វិហារក៏នៅសល់ពុំទាន់ហើយ គឺនៅត្រឹមជំបូល, កំពូលនិងក្បាច់ក្បូរថ្មក់លើទាំងអស់ ។

លុះដល់ឆ្នាំ ១៩៦១ ព្រះមុនីកោសល សូរ ហាយ បានទទួលនាទីជាចៅអធិការ បានកសាងវិហារនោះបន្តមកទៀត រហូតដល់ឆ្នាំ ១៩៦៨ ទើបហើយស្រេច ។ លុះសំណង់វិហារនោះសម្រេចហើយ បានប្រជុំពុទ្ធបរិស័ទ តាំងគណៈកម្មការមួយ ដំនុំអំពីពិធីបុណ្យឆ្លងវិហារ បញ្ចុះខណ្ឌសីមា ។ គណៈកម្មការក៏បានយល់ស្របគ្នាជាឯកច្ឆន្ទ ។

កម្មវិធីបុណ្យឆ្លងវិហារ-បញ្ចុះខណ្ឌសីមាវត្តនិពេធវង្សនេះ មានបីយប់បួនថ្ងៃ គឺ :

ថ្ងៃទី ១ គឺថ្ងៃអាទិត្យ ៤ រោចខែផល្គុន (១៧ មីនា ឆ្នាំ១៩៦៨) ពេលល្ងាចម៉ោង ១៦ ប្រជុំគ្នាបើកសម័យចូលបុណ្យ ដង្ហែដុំថ្មនិមិត្តសីមាប្រទក្សិណវិហារ រួចយកនិមិត្តសីមា ទៅតម្កល់ក្នុងវិហារថ្នាក់លើ, ម៉ោង ១៩ អុជកាំជ្រួច, ម៉ោង ២០ នមស្ការព្រះរតនត្រ័យ ព្រះសង្ឃចំរើនព្រះបរិត្ត, សូត្រដុំថ្មនិមិត្តសីមា, សូត្រឧបោសថាគារ គឺព្រះវិហារ, ម៉ោង ២១ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ទ្រង់ប្រទានធម្មទេសនា ព្រះធម្មគារវៈ, ម៉ោង ២៣ បញ្ចាំងភាពយន្តតទៅ ។

ថ្ងៃទី ២ គឺថ្ងៃ ៥ រោចខែផល្គុន (១៨ មីនា) ពេលព្រឹក និងពេលថ្ងៃត្រង់ អង្គាសយាគូ វេរសង្ឃភត្តចំពោះសង្ឃ ១៨០ អង្គ, ពេលល្ងាចម៉ោង ១៥ និមន្តលោកគ្រូអាចារ្យ ព្រះនាម ពណ៌ ចៅអធិការវត្តពោធិព្រឹក្ស ទេសនា ទសជាតក៍, ពេលព្រលប់ម៉ោង ១៨ អង្គាសគេសជ្ជៈ ម៉ោង ១៩ អុជកាំជ្រួច, ម៉ោង ២០ នមស្ការចម្រើនព្រះបរិត្ត រួចសូត្រធ្វើកិច្ចពុទ្ធាភិសេក, ម៉ោង ២២ សម្តេចព្រះពោធិវង្ស ប្រទានធម្មទេសនាបឋមត្រាស់, ម៉ោង ២៣ បញ្ចាំងភាពយន្តតទៅ ។

ថ្ងៃទី ៣ គឺថ្ងៃ ៦ រោចខែផល្គុន (១៩ មីនា) ពេលព្រឹកមានកម្ម-

វិធីដូចថ្ងៃទី ៦ ដែរ ។ ពេលរសៀលម៉ោង ១៦ និមន្តព្រះអរិយមគ្គញាណ អៀម ហេង វត្តសាកាវ៉ន ទេសនាអំពីផលានិសង្ឃបុណ្យ, ម៉ោង ១៧ អង្គាសភេសជ្ជៈ, ម៉ោង ១៨ និមន្តព្រះសង្ឃ ១៥០ អង្គធ្វើសង្ឃកម្មសូត្រសីមា, ម៉ោង ២១ អុជកាំជ្រួច រួចមានសិល្បៈយីកេតទៅ ។

ថ្ងៃទី ៤ គឺថ្ងៃ ៣ រោចខែផល្គុន (២០ មីនា) ពេលព្រឹកម៉ោង ៦ អង្គាសយាគូ និងភត្តចំពោះសង្ឃ ១៨០ អង្គ, ម៉ោង ៨ រង់ចាំធ្វើបដិសណ្ឋារកិច្ចចំពោះសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១, សម្ដេចព្រះសង្ឃនាយកគណៈធម្មយុត្ត និង សម្ដេចព្រះពោធិវង្ស, ម៉ោង ៩ រង់ចាំធ្វើបដិសណ្ឋារកិច្ចចំពោះសម្ដេចព្រះប្រមុខរដ្ឋ, ម៉ោង ១០ ព្រះមុនីកោសល ថ្វាយសុន្ទរកថា, ម៉ោង ១០,២០ នាទី សម្ដេចព្រះប្រមុខរដ្ឋថ្លែងសន្ថរកថាដ៏សង្ខេប, ម៉ោង ១០,៤០ នាទី កាត់ឫសសីមា, ម៉ោង ១១ វេរសង្ឃភត្ត ពេលរសៀលម៉ោង ១៤ និមន្តព្រះធម្មកថិក ៣ អង្គ សុទ្ធតែជាព្រះមេគណ គឺ : លោកគ្រូមេគណខេត្តកណ្ដាល, មេគណក្រុងភ្នំពេញ និង មេគណខេត្តស្វាយរៀង ទេសនា សង្គាយនាចូលបុណ្យតាមប្រពៃណីនិយម ។

ក្នុងឱកាសបុណ្យឆ្លងព្រះវិហារ-បញ្ចុះខណ្ឌសីមាវត្តនិរោធរង្សី មានគណៈកម្មការ ១២ ក្រុម ជាអ្នកចាត់ចែងរៀបចំបុណ្យ ។ វត្តនិរោធរង្សី បានទទួលនូវភាពថ្កុំថ្កើងរុងរឿងជាមហាស្ថានដ៏ក្រៃលែង អស់រពង

៤ យប់ ៥ថ្ងៃ ដោយរៀបចំនាដាក់ភ្លើងអគ្គិសនីភ្លឺចិញ្ចែងចិញ្ចាចគ្រប់ដើមឈើមែកឈើទាំងអស់ព្រមទាំងភ្លើងបញ្ចាំងពន្លឺចំពោះព្រះវិហារ ទាំងចម្រុះដោយទង់ជាតិ និង ទង់សាសនា ជាច្រើនក្រោងក្រាក ព្រមទាំងពេងតាំង ១១ សុទ្ធតែមានលំអក្រៃលែងផ្សេងៗគ្នា គួរជាទីជ្រះថ្លារីករាយនៃមហាជនពន់ពេកណាស់ ។ នៅឱកាសពិធីបុណ្យនេះ ក៏មានភ្ញៀវអញ្ជើញមកច្រើនកុះករមីរដេរដាសនៅលើថ្នល់ជាតិ តាំងពីផ្សារចង្អៀតពេញថ្នល់ពេញវត្ត ហើយច្រើនលាន់មាត់សរសើរថា បុណ្យនេះចំជាថ្កើងរុងរឿងអស្ចារ្យពិតប្រាកដមែន ។

## គណៈកម្មការបុណ្យ ១២ ក្រុម

១- គណៈកម្មការទូទៅមានលោក តាន់ ឈាងលឹម តំណាងរាស្ត្រ ជាប្រធាន

២- គណៈកម្មការមជ្ឈមណ្ឌលមានលោក សាន ឌុក ជាប្រធាន

៣- គណៈកម្មការ ចំណាយខាងហិរញ្ញវត្ថុមាន ឧបាសក ស៊ុក មៀច ជាប្រធាន

៤- គណៈកម្មការ ខាងភោជនាហារមានឧបាសក អែម សម ជាប្រធាន

៥- គណៈកម្មការ ខាងភេសជ្ជៈមានឧបាសក ប៊ុល ឈោម ជាប្រធាន

BIBLIOTHEQUE P.P. D'EXTREME ORIENT

៦- គណៈកម្មការ ខាងហេរញ្ញិក មានអាចារ្យ

ស្រី ឈឹន, គួច គីឡេង ជាប្រធាន

៧ - គណៈកម្មការ ខាងផ្គត់ផ្គង់ភ្លើង មានឧបាសក

អ៊ុក-មៀច, ចៅ ពេញ ជាប្រធាន

៨ - គណៈកម្មការ ខាងរកប្រើប្រាស់ មានឧបាសក

សោ-ហ៊ិន ជាប្រធាន

៩ - គណៈកក្មការ ខាងបដិសណ្ឋារៈ ចំពោះសង្ឃនិងគ្រហស្ថ មានព្រះមុនីកោសល, ព្រះឥន្ទមុនី ឆាយ-ផន ជាប្រធាន និងព្រះសិរីវិសុទ្ធ ធន់ ពន់ ជាអនុប្រធាន ៍ ខាងគ្រហស្ថមានឧបាសក ឯវ-អ៊ុំ ជាប្រធាន

និងលោក ម៉ែន-ពុំ ជាអនុប្រធាន

១០ - គណៈកម្មការ ខាងត្រួតត្រាមើលពេងកាន់ទិស

មានឧបាសក ឯម-សម ជាប្រធាន

១១ - គណៈកម្មការ ខាងរបៀបរៀបចំទូទៅ មានសន្តិសុខនិង សុខាភិបាលជាដើម មានលោក ម៉ៅ-អ៊ុត ហៅ ម៉ុល ជាប្រធាន

១២ - គណៈកម្មការ ខាងផ្គត់ផ្គង់កាំជ្រួច, អុជកាំជ្រួចរៀងរាល់ យប់ ដោយមានលោក ឡាំ-សន ជាប្រធានគហបតី ល៉ី-គ្រាន់ ជាអនុ-ប្រធាន ។

គណៈកម្មការពិធីបុណ្យនេះ មានសមាជិក-សមាជិកា ចំនួន ១៨០

នាក់ មានព្រះមុនីកោសលជាចៅអធិការជាប្រធានទូទៅលើគណៈកម្មការឯទៀត ៗ ដើម្បីអនុវត្តឲ្យត្រឹមត្រូវតាមគម្ពវិធី និងបទបញ្ជារបស់គណៈកម្មការទាំងអស់ ជាពិសេសអស់លោកអ្នកដែលពុំមែនជាសមាជិកនៃគណៈកម្មការបុណ្យនេះទេ ប៉ុន្តែលោកបានអញ្ជើញមកជួយបម្រើបុណ្យដោយពេញកម្លាំង បែកញើសហូរស្រោកស្រៀនពល់យប់ពល់ថ្ងៃ ឥតខ្លាចនឿយហត់ឡើយ ដូចយ៉ាងលោក វរសេនីយឯក ប៉ុក-សំអាន, លោកវរសេនីយឯក ថេបនា-ធិន និងលោក យង់-សេង ចៅតំបន់រដ្ឋបាលច្បារអំពៅ ដែលខំខ្វល់ខ្វាយបម្រើបុណ្យផ្ទាល់ ១ ខ្លួន ទាំងយប់ទាំងថ្ងៃ ។

មួយទៀតការជួយឧបត្ថម្ភបុណ្យនេះ មានឯកឧត្តមចៅ សែនកុសល ឈុំ ប្រធានរដ្ឋសភា, ឧត្តមសេនីយឯក លន់ ណុល និងលោកជំទាវ, អ្នកស្រីឧបាសិកា គាន់ ស៊ុបី ប្រធានគណៈកម្មការ វត្តឧណ្ណាលោម, លោកអភិបាលខេត្តកណ្តាល និងលោកអភិបាលស្រុក កៀនស្វាយ ជាដើម ។

ចំណាយថវិកាកំណត់ទុកសំរាប់បុណ្យ របស់គណៈកម្មការបានជួរស្រាលជាច្រើនណាស់ ដូចយ៉ាងប្រាក់កាសដែលត្រូវចាយ សម្រាប់ភោជននិងគេសជ្ជៈជាដើមចំនួន៤ថ្ងៃ ប៉ុន្តែត្រូវចាយចំពោះតែ២ថ្ងៃទៅវិញគឺ

១ លោកជំទាវឧត្តមសេនីយឯក លន់ - ណុល ទទួលក៏ប៉ាងធ្វើចង្ហាន់ប្រគេនព្រះសង្ឃចំនួន ២០០ អង្គអស់មួយថ្ងៃ ។

២- អ្នកស្រីឧបាសិកា តាំង - ស៊ីប ទទួលកាប់រងធ្វើចង្ហាន់ប្រគេនព្រះសង្ឃចំនួន ២០០ អង្គអស់មួយថ្ងៃ ។

៣ ឯកឧត្តម ប៉ៅ-សែនកុសល ឈុំ ទទួលភាប់រងវេទិកាពិសេសសម្រាប់សម្តេចព្រះប្រមុខរដ្ឋ ព្រមទាំងរថយន្តដឹកទឹក ។

៤ លោកវររសេនីយឯក ប៊ុនណា - ងិន ទទួលភាប់រងខាងម៉ាស៊ីនភ្លើង អគ្គិសនីព្រមទាំងការរចនាភាក់តែងភ្លើង ។

៥- លោកវររសេនីយឯក ប៉ុក-សំអាត ទទួលភាប់រងខាងក្ដារបែនសម្រាប់តម្កល់គ្រប់បាតព្រមទាំងកៅអី និងរថយន្តដឹកទឹក ។

៦ - គហបតី យ៉ាង ទេង ភាប់រងខាងកាំជ្រួចសម្រាប់អុជរៀងរាល់យប់ អស់ចំនួន ២០.០០០ រៀល ។

៧- លោកអ្នកឧកញ៉ា ងិន-ង៉ិប ភាប់រងខាងភេសជ្ជៈចំពោះសង្ឃអស់មួយពេល ។

៨- គហបតី លី-គ្រាន់ ទទួលភាប់រងចេញប្រាក់បោះពុម្ពសៀវ-ភៅ សម្រាប់ប្រគេនចែកជាធម្មទានអស់ ១០.០០០ រៀល ព្រមទាំងស្បង់ចំនួន ១០០ ។

៩- ក្រុមពុទ្ធបរិស័ទ សាលាសន្សំសុខ ក្រុងភ្នំពេញ ធ្វើចីវរចំនួន ២០ លៀង ព្រមទាំងធ្វើភេសជ្ជៈប្រគេនព្រះសង្ឃអស់មួយពេល ។

១០- ក្រុមពុទ្ធបរិស័ទ ផ្សារ បែកចាន ធ្វើចីវរចំនួន ១០ សៀង

១១- ក្រុមពុទ្ធបរិស័ទ ភូមិសល់ដី ព្រៃពួច អង្គស្នួល ធ្វើចីវរ ចំនួន ៥ សៀង ។

១២- ក្រុមបរិស័ទ សេង.បៃ ជំនួញភេសជ្ជៈ ប៉ុបស៊ី-កូឡា ក៏បានប្រគេនភេសជ្ជៈចំពោះសង្ឃអស់មួយពេល ។

នៅទំព័របន្ទាប់ទៅទៀតនេះ យើងសូមចុះជូនតាំងស្រុងនូវអត្ថបទសុន្ទរកថារបស់ ព្រះម្ចាស់ពោសល ស្លូរ.ហាយ ដែលបានថ្លែងជាឧទ្ទេសកក្នុងឱកាសបុណ្យនេះ ។

ចំណែកព្រះរាជសន្ទេសជាដ៏ពីរោះក្បោះក្បាយ របស់សម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ជាទីគោរព ស្នេហា ស្មើជីវិតនៃយើងនោះ អស់លោកអ្នកអាន បានស្តាប់ជាច្រើនលើកតាមសម្លេងវិទ្យុជាតិរួចមកហើយកាលពីថ្ងៃទី ២០ និង ២១ មីនា គ.ស.១៩៦៨ ។

# សុន្ទរកថា នៃព្រះមុនីកោសល សួរ ហាយ

ថ្លែងក្នុងឱកាស ពិធីឆ្លងព្រះវិហារ បញ្ចុះខណ្ឌសីមា វត្តនិរោធរង្សី សង្កាត់ច្បារអំពៅ ស្រុកកៀនស្វាយ ខេត្រកណ្ដាល នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៦៨ ក្រោមព្រះរាជាធិបតីភាពនៃ

សម្តេចព្រះប្រមុខរដ្ឋ

## សូមថ្វាយព្រះពរ

## ចំពោះសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

*ក្នុងនាមនៃពុទ្ធបរិស័ទដើនវត្ត, ក្នុងនាមនៃគណៈកម្មការចាត់ចែងពិធីបុណ្យ និងក្នុងនាមផ្ទាល់នៃអាត្មាភាព ដោយពេលឱកាសដ៏មហោឡារិកនេះ នាំឲ្យអាត្មាភាពមានសោមនស្សរីករាយរំភើបចិត្ត ប្រកបដោយបីតិប្រាមោទ្យអរសប្បាយជាទីបំផុត ចំពោះសម្តេចជាម្ចាស់ ដែលទ្រង់ព្រះមេត្តាស្ដេចយាងមកជាព្រះរាជាធបតី និង ជាព្រះរាជាកិត្តិយសដ៏ខ្ពង់ខ្ពស់នៃពិធីបុណ្យឆ្លងព្រះវិហារថ្មី និង បុណ្យបញ្ចុះខណ្ឌសីមាវត្តនិរោធរង្សី ឆ្លងសាលាបឋមសិក្សាមួយខ្នង, បណ្ណាល័យមួយខ្នង, ស្ពានបេតុងអារម៉េ១ ព្រមទាំងថ្នល់មួយផង ។*

សូមក្រាបបង្គំទូលថ្វាយសម្តេចព្រះសង្ឃរាជថ្នាក់ទី១,

សម្តេចព្រះសង្ឃនាយក,

សម្តេចព្រះពោធិវង្ស,

ព្រះមហាថេរានុត្ថេរៈទាំងឡាយ,

ទ្រង់, ឯកឧត្តម និងអស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ ដែលបាន យាង និមន្ត-អញ្ជើញ មកជាព្រះរាជកិត្តិយស និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធវិហារថ្មី, បញ្ចុះខណ្ឌសីមានេះ ។

នៅពេលនេះ អាត្មាភាព សូមព្រះរាជទានព្រះរាជវរោកាសថ្វាយ ដោយសង្ខេប អំពីសំណង់វិហារ, សាលាបឋមសិក្សា, បណ្ណាល័យ, ស្ពាន និង ថ្នល់ ដើម្បីសម្តេចជាអម្ចាស់ទ្រង់ជ្រាប ដូចសេចក្តីរៀបរាប់វែកញែកតទៅនេះ ៖

## អំពីសំណង់វិហារ

ព្រះវិហារនេះចាប់ផ្តើមបញ្ចុះបឋមសិលាពីឆ្នាំ ១៩៦៧ កាលណោះ ឯកឧត្តម ទៅសែន កុសល ហៅ ឈុំ អភិបាលខេត្តកណ្តាល បានអញ្ជើញ មកជាអធិបតីក្នុងពិធីបញ្ចុះសិលា លុះមកដល់ឆ្នាំថ្មីឯកស័កឆ្នាំ ១៩៤៩ ក៏ ចាប់ផ្តើមសង់វិហារបណ្តើរ លើកដីបណ្តើរដរាបមក ។ វត្តនិពន្ធវង្សនេះជា វត្តបុរាណចាស់ទុំយូរណាស់ហើយ មានកំណើត ៣ កន្លែង និងកន្លែងនេះ ហើយ ដោយហេតុប្រាំងទន្លេចេះតែបាក់ ស្រុតដេញវត្តចេញអំពីមាត់ទន្លេ

ម្ល៉ោះហើយ គឺចេះតែត្រូវរុះរើចេញអំពីទីប្រាំងបាក់យកមកសង់ត្រង់កន្លែងនេះ ។ វត្តនេះទើបនឹងរុះរើចេញអំពីទីមាត់ទន្លេប្រាំងបាក់ ពីឆ្នាំមមែត្រីស័ក ខែពិសាខ ថ្ងៃសុក្រ ព.ស. ២៤៧៥ គ.ស. ១៩៣១ ។ រយៈចម្ងាយពីវត្តវិភោធរង្សីថ្មីនេះ ទៅមាត់ទន្លេប្រាំងបាក់ខាងជើង ចំនួន ២ គីឡូម៉ែត្រ ។

សំណង់វិហារនេះ ដោយពុទ្ធបរិស័ទ មានព្រះមុនីកោសល សោម-ឈុន ជាដើម ជាអតីតចៅអធិការវត្តនេះ ព្រមទាំងពុទ្ធបរិស័ទជើងវត្ត និងអស់លោក អ្នកក្រុងភ្នំពេញ ជួយឧបត្ថម្ភជាច្រើននាក់ ដូចកត់នាមខាងក្រោមនេះ ៖

១- ឯកឧត្តម ចៅ សែនកុសល ឈុំ ប្រធានរដ្ឋសភាបច្ចុប្បន្ននេះ

២. ឧត្តមសេនីយឯក លន់ ណុល និង លោកជំទាវនៃឧត្តមសេនីយឯក បានជួយឧបត្ថម្ភផ្តល់បច្ច័យក្នុងសំណង់វិហារនេះទាល់តែហើយស្រេច អស់បច្ច័យចំនួន ២៩០.០០០៛

៣- លោកវរសេនីយឯក បបនា ង៉ិន និង លោក ង៉ិន ទិព្វា ជាបងប្អូននិងគ្នា

៤- លោកវរសេនីយឯក ប៉ុក សំអាន ។

ក្នុងការឧបត្ថម្ភសំណង់វិហារនេះ សូមអភ័យទោសពុំបានកត់ឈ្មោះឲ្យអស់ឡើយ ។ សំណង់វិហារនេះ តែងធ្លាក់សង្កត់ធ្ងន់ទៅលើពុទ្ធបរិស័ទជើងវត្ត បើពុំតែបានអស់លោកដូចកត់នាមខាងលើនេះ និងលោកជំទាវ

ឧត្តមសេនីយឯក និងឧបាសិកា តាន់ ស៊ុបី ជាដើមជួយដោះស្រាយ ប្រ-
ហែលជាសំណង់វិហារនេះពុំទាន់ហើយស្រេចទេ ។

## អំពីតម្លៃសំណង់វិហារ

ការប្រមូលតម្លៃសំណង់វិហារនេះ តាំងពីឆ្នាំថ្ងៃឯកស័ក ១៩៤៩ រហូត
ដល់មកឆ្នាំ ១៩៦៨ ត្រូវជា ១៩ ឆ្នាំ ហើយអស់តម្លៃដោយសារុបចំនួន
បីលានប្រាំបួនម៉ឺនប្រាំពាន់រៀល (៣.០៩៥.០០០៛) ។

## អំពីកំពស់ និង ទំហំនៃវិហារ

វិហារនេះមានពីរជាន់ កំពស់ដោយកប់តាំងពីថ្ពក់បធម្មតាដល់ចុង
កំពូលធត្រត្រ ៣២ម. មានទទឹង ១៤ម. បណ្តោយ ២៩ម ។

## អំពីសាលាបឋមសិក្សា

សាលាបឋមសិក្សាមួយខ្នងមាន ៤ បន្ទប់ ដែលយាយឧបាសិកា នូ-
ពិន និង គហបតី ជូ គិបស្រេង ជួយឧបត្ថម្ភផង ។ សាលានេះបិតនៅ
ខាងកើតវត្តចំនួនជាងមួយរយម៉ែត្រ ចាប់កសាងពីឆ្នាំ ១៩៥៦ ។ ដើម
ឡើយសាលានេះយាយឧបាសិកា នូ ពិន សង់បានតែ ៣ បន្ទប់ទេ ព្រម
ទាំងខ្លោងទ្វារខាងជើងសាលា និង ការលើកចាក់ដីបំពេញទីក្រហេងក្រ
ហូង អស់តម្លៃដោយរួបរួមចំនួន ២២៤.៩០៧៛ ។ លុះដល់មកឆ្នាំ

១៩៦៦ ក្នុងខែឧសភាក៏អាត្មាភាពដឹកនាំគហបតី លី ប៊ិន ក្រុងភ្នំពេញ ឲ្យកសាងបន្តភ្ជាប់គ្នាបានមួយបន្ទប់ទៀត អស់តម្លៃចំនួន ១៤១.០០០រ ។ បូករួមទាំងតម្លៃពីបន្ទប់ដែលយាយ ឧបាសិកា ទូ ពិន បានកសាងនោះត្រូវអស់តម្លៃ ៣៦៤.៥០៣រ ។

ក្នុងឆ្នាំជាមួយគ្នានោះ គហបតី លី ប៊ិន ដែលជាមិត្តភក្តិនឹងអាត្មាភាពបានសង់បណ្ណាល័យមួយខ្នងទៀតដោយគ្រឿងបេតុងអារ៉ម៉េ មានពីរជាន់ឋិតនៅខាងក្រោយនេះ ប៉ុន្តែក្រាលក្តារឈើទាល អស់តម្លៃចំនួន ១៩៥.០០០រ ។

## អំពីស្ពានបេតុងអារម៉េនិងបិល់

សំណង់ស្ពានបេតុងអារម៉េ ដែលសង់ឡើងដោយពុទ្ធបរិស័ទជើងវត្ត មានអាត្មាភាពជាប្រធានគណៈកម្មការសង់ ។ ស្ពាននេះចាប់សង់ឡើងពីឆ្នាំ ១៩៦៦ កាលណោះលោក ទេព សុន្ទី អភិបាលខេត្តកណ្តាលជួយជាវិភាគទានស៊ីម៉ងត៍ ១០០ បាវ ដែកចំនួន ៥០០ គីឡូ, ខាងសង្គមកិច្ចក៏បានជួយស៊ីម៉ងត៍ ៥០ បាវដែរ រួចពីនេះបះតែនាំគ្នាធ្វើ ពុំបានជួលជាងដោយមេការ ឬ ឈ្នួលថ្លៃនោះឡើយ គឺថាស្ពាននេះពុំមានជាប់បង់ថ្លៃឈ្នួលជាងទេ ។ ជាងអ្នកសង់ស្ពាននេះ មានឈ្មោះឧបាសក មៅ អ៊ុត ហៅ ម៉ុល, ជាង កេត, ជាង សម, ជាង យុត ជាដើម សង់ឡើង

ដោយចិត្តជ្រះថ្លាចំពោះខ្លួន ។ ស្ពាននេះទទឹង ៥ ម៉ែត្រ, បណ្តោយ ២៦ ម៉ែត្រ សង់ត្រង់ព្រែកធ្លា មានចម្ងាយពីវត្តទិពេជរង្សីនេះទៅខាងជើងចំនួន ១ គីឡូម៉ែត្រ ។ តម្លៃសំណង់ស្ពាននេះ អស់ចំនួន ១២០.០០០៛ ។

កម្លាំងរបស់ស្ពាននេះ ដែលលោកអ្នកបច្ចេកទេសបានពិនិត្យមើលឃើញថាមាំមួនរឹងប៉ឹង អាចទទួលទម្ងន់បានរហូត ៦ តោន ។

## អំពីផ្លូវថ្នល់

ផ្លូវថ្នល់កសាងឡើងដោយពុទ្ធបរិស័ទជើងវត្តនេះតែបបួលគ្នា នាំគ្នាលើកដោយខ្លួនឯងខ្លះ ជួលគេខ្លះ តាំងពីឆ្នាំ ១៩៥៩ ។ ផ្លូវថ្នល់នេះជាប់អំពីថ្នល់ជាតិខ្ពោះត្រង់ទៅមាត់ទន្លេទិសខាងជើង មានរយៈចម្ងាយចំនួន ២ គីឡូម៉ែត្រ ប៉ុន្តែលើកឲ្យមានកំពស់ហើយ ទើបនឹងបានចម្ងាយ ១.៥០០ ម៉ែត្រ នៅសល់ពុំទាន់បានលើក ៥០០ ម៉ែត្រទៀត តែជាអ្នកភូមិទាំងនោះ សន្យាថានឹងបេះតែនាំគ្នាលើកតទៅទៀត ទាល់តែចប់ស្រេចពុំខាន ថ្នល់នេះមានកំពស់កន្លែងខ្លះរហូត ៣ ម៉ែត្រ, កន្លែងខ្លះរហូត ២ ម៉ែត្រ ឬ ១ ម៉ែត្រកន្លះ, ទទឹង ៤ ម៉ែត្រ បើទឹកឡើងតូចដូចឆ្នាំនេះ មិនលិចថ្នល់នោះទេ បើទឹកឡើងធំដូចកាលពីឆ្នាំមុនទើបលិច ជម្រៅរហូត ៥០ សង្ទីម៉ែត្រ ឬ ៧០ សង្ទីម៉ែត្រ ដោយកន្លែងខ្លះ ។

## សូមថ្វាយព្រះពរ

ផ្លូវថ្នល់ដែលប្រជាពលរដ្ឋ ក្នុងភូមិជើងវត្តសង់ឡើងនេះ ពុំមានកំណត់តម្លៃថា អស់ប៉ុណ្ណេះប៉ុណ្ណោះកើតទេ ពីព្រោះច្រើនតែលើកដោយការហត្ថកម្មស្ម័គ្រចិត្តពល់ ៗ ខ្លួន ពុំសូវមានជាប់បង់ថ្លៃឈ្នួលឡើយ ។

សាលាបឋមសិក្សា, បណ្ណាល័យ, ស្ពានបេតុងអារម៉េ និងថ្នល់បានថតយករូបភាពមកជាភស្តុតាង ថ្វាយសម្តេចជាអម្ចាស់ទ្រង់ទត ដើម្បីសម្ពោធក្នុងពេលនេះដែរ ។ សាលាបឋមសិក្សា, ស្ពាន, បណ្ណាល័យ និងថ្នល់ទុកជាសមិទ្ធិមួយសម្រាប់បម្រើជាតិ សាសនា និងព្រះរាជបល្ល័ង្ក កើតឡើងក្នុងសម័យមហាចលនាសង្គមរាស្ត្រនិយម ដែលមានអង្គសម្តេចជាប្រធាន ។

## សូមថ្វាយព្រះពរ

ការស្ថាបនានូវសមិទ្ធិផ្សេង ៗ មានសាលារៀនជាដើមជាទីចាប់អារម្មណ៍នៃអាត្មាភាពដ៏ក្រៃលែងជាអតិបរមា ។ ព្រោះថាសមិទ្ធិគឺសេនា-សនកណ្ឌនេះ ជាសម្ភារៈសម្រាប់បម្រើខាងផ្លូវលោកនិងផ្លូវសាសនា រាប់ជាជាមូលដ្ឋានមួយដែលអាចសំគាល់បានថាជា ថាមពល មានមុខឈមទៅរកសេចក្តីចម្រើន លូតលាស់ ប្រគល់កិត្តិយសកេរ្តិ៍ឈ្មោះដល់ជាតិសាសនារបស់យើងដោយពិតប្រាកដ ។ ការកសាងសមិទ្ធិនេះ ទុកជា

ឧត្តមគតិមួយដ៏ប្រសើរបំផុត អាចជួយលើកស្ទួយប្រទេសជាតិរបស់យើង បានច្រើនណាស់ដូចឧទាហរណ៍: សមិទ្ធិបូរាណ នគរវត្ត របស់យើង បង្ហាញដ៏ត្រកាលអស្ចារ្យដល់បរទេស អាចទាក់ទាញពួកទេសចរបរទេស ឲ្យមកក្នុងឆ្នាំនីមួយៗ ច្រើនពាន់នាក់ ឃើញថាសមិទ្ធិជាមូលហេតុនាំឲ្យ ប្រទេសបមុងចម្រើន ទាំងទ្រព្យសម្បត្តិទាំងកេរ្តិ៍ឈ្មោះជាប្រាកដ ។ ករណីនេះសឲ្យឃើញថា មហាក្សត្ររបស់យើងសម័យបូរាណ ដែលកសាងប្រាសាទអង្គរធំអង្គរវត្ត ឈ្មោះថាមហាក្សត្រជាន់នោះ មានមធ្យោ-បាយល្អប្រកបដោយឧត្តមគតិ ដ៏ខ្ពង់ខ្ពស់បំផុត ។

ក្នុងសម័យ មហាចលនាសង្គមរាស្ត្រនិយម ដែលអង្គសម្តេចដឹកនាំនេះ ប្រាកដជាមាននិន្នាការបែរឈមទៅរកសន្តិសុខចម្រើនរុងរឿង លូតលាស់ជឿនលឿន ដែលយើងឃើញជាសក្ខីភាពច្បាស់ហើយ ។ ព្រះមហាក្សត្រ គឺសម្តេចព្រះប្រមុខរដ្ឋ ដែលតាំងពីសម្តេចទ្រង់បំពេញបេសក-កម្មដឹកនាំប្រទេសជាតិកម្ពុជាយើងនេះមកឃើញថា សមិទ្ធិធំតូចព្រោងព្រាត ហាក់ដូចជាផុសឡើងឯគ្រប់ស្រុកគ្រប់ខេត្ត ក្រោមព្រះកិច្ចដឹកនាំនៃសម្តេច ដោយព្រះមធ្យោបាយនៃសម្តេចជាអម្ចាស់ ។ ការណ៍នេះឈ្មោះថា សម្តេចទ្រង់អនុវត្តត្រូវតាមឧត្តមគតិព្រះមហាក្សត្រសម័យអង្គរ ដោយពិតប្រាកដ ។ ព្រះមធ្យោបាយគ្រប់យ៉ាងនៃសម្តេច ពេញជាល្អខ្ពង់ខ្ពស់ត្រឹមត្រូវគ្រប់ ១០០ ភាគរយ ឥតខ្វះឡើយ ។

ខ្ញុំអាត្មាភាពបានប្តេជ្ញាចិត្តថា សូមបំពេញបេសកកម្ម តាមឋានៈជាបព្វជិតដែលអាចបំពេញបាន ហើយត្រូវតែទំប្រឹងរត់ហែតាមព្រះមធ្យោ-បាយសម្តេចជាអម្ចាស់ ដរាបដល់អវសាននៃជីវិតពុំខាន ។ កម្មវិធីក្នុងចិត្តអាត្មាភាពចំពោះកិច្ចហ្មបទានូវសមិទ្ធិ ព្រោះតែមានទៅជានិច្ច ទាស់តែខ្វះបច្ច័យជាហេតុនាំឲ្យចាត់ការទាំងនេះ មិនបានគ្រប់គ្រាន់តាមកម្មវិធីទៅឡើយ ។ ដូចឧបដ្ឋានសាលាសម្រាប់បម្រើព្រះពុទ្ធសាសនាក្នុងវត្តនេះក៏សង់ឡើងបានមួយជាន់ខាងក្រោមហើយ នៅមួយជាន់ខាងលើទៀតតាមគោលបំណងថា នឹងទុកដាក់ជាសាលាពុទ្ធិកបឋមសិក្សាថ្នាក់ទី ១ ព្រោះថ្នាក់ទី ២ មានសាលាដោយឡែកហើយ ។

ក្នុងពាក់កណ្តាលឆ្នាំ ១៩៦៨ នេះ នឹងសង់អនុវិទ្យាល័យមួយគ្រឿងនៅលើដីវត្ត នាទិសខាងកើតជាប់នឹងដីវត្តនិរោធរង្សី សម្រាប់សង្កាត់ច្បារអំពៅ ដោយហេតុសង្កាត់នេះមានមនុស្សកុះករ, មានសាលាបឋមសិក្សាជាច្រើន, មានសល់ក្មេងថ្នាក់ឧត្តមដ្ឋានជាច្រើននាក់ណាស់ ពីព្រោះអនុ-វិទ្យាល័យស្មើសម្តេចឪនៅព្រែកឯងនោះពុំទាន់ជួនល្មមនៅឡើយ ។ ការប្រុងប្រៀបស្ថាបនាអនុវិទ្យាល័យលើដីវត្តនៅទិសខាងកើតវត្តនេះ បានតាំងគណៈកម្មការបណ្តោះអាសន្នរួចហើយ បានទាំងសូមតាមផ្លូវការនូវការស្ថាបនាអនុវិទ្យាល័យទៅក្រសួងអប់រំជាតិរួចស្រេចហើយ ផ្នែកខាងក្រសួងអប់រំជាតិក៏បានអនុញ្ញាតយល់ព្រមហើយ ។ គណៈកម្មការបណ្តោះអាសន្ន

មានអាត្មាភាពជាប្រធាន ដោយអស់លោកអ្នកកងសង្កាត់ប្បាអំពៅ មាន លោកតំណាងកស្រ្ត គាន់-ឈាងលីម, លោក ជិម-ម៉ាលិស, លោក ឡុង-ប៊ួរ៉េត ជាដើម បេះតែព្រួតគ្នាធ្វើយជាក់អាត្មាភាពប្រកែកមិនរួចសោះ ។

កងករណីដូចរៀបរាប់ថ្វាយសម្តេចជាអម្ចាស់នេះ លោកអ្នកបច្ចេកទេសក្រុមផែនទីសុយោធាដ៏កំបានគូរប្លង់ដីសម្រាប់សង់រួចស្រេចហើយ សឹងមានរូបភាពប្លង់ដីព្រាងនេះជាក់ស្តែង ដើម្បីថ្វាយសម្តេចជាអម្ចាស់ទ្រង់ទតទីងបានទ្រង់ជ្រាបទុកជាមុន ។

មួយទៀតការរៀបចំដើម្បីធ្វើបុណ្យសម្ពោធវិហារ និង បុណ្យបញ្ចុះខណ្ឌសីមានេះ មានលោកអ្នកពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លាពីមុនថ្ងៃចូលបុណ្យដូចមាននាមខាងក្រោមនេះ ៖

១- លោក ង៉ោ-ហុង បានថែព្រះពុទ្ធរូបថ្មកែវមួយព្រះអង្គជាព្រះពុទ្ធរូបរបស់ឧត្តមសេនីយ ង៉ោ-ហ៊ូ មកតម្កល់កងព្រះវិហារថ្នាក់លើព្រមទាំងយកកន្ទេលល្អ ៦ ខ្សែ ក្រាលវិហារ ។

២- គហបតី លី-គ្រាន់ ភ្នំពេញ យីហោ គង់ហេង ផ្សារថ្មីចូលបោះពុម្ពសៀវភៅ ១០.០០៛ ព្រមទាំងស្បង់ ១០០ សម្រាប់ប្រគេនព្រះសង្ឃធ្វើសង្ឃកម្មសីមា ។

៣ - គហបតី យាន ខេង ភ្នំពេញ យីហោ ខេង-ហេង ផ្សារថ្មី ទទួលរ៉ាប់រងខាងទិញកាំជ្រួចចំនួន ១៥.០០០៛

៤- លោកជំទាវឧត្តមសេនីឯក លន់-ណុល ចូលបច្ច័យ ១០.០០០៛ ព្រមទាំងយាយ មឿនទិនឧបាសិកាម្នាក់ទៀត ៤០០៛ សម្រាប់ចាត់ការបុណ្យ

៥- លោកអ្នកឧកញ៉ាឧត្តមគោគី លឹម-ហួត ក៏ពេញចូល ២.០០០៛ មុនដំបូងបង្អស់ សម្រាប់ទិញឈើឬស្សីស្បូវ សម្រាប់ធ្វើកេន៍បុណ្យបញ្ចុះខណ្ឌសីមានេះ

៦- ឧបាសិកា គឹម ហ៊ុំ ផ្សារគគីរ ចូល ៥០០៛ ធ្វើកេន៍បុណ្យ

៧- គហបតី តាន់ប៊ុនឈាង ក៏ពេញចូល ២.០០០៛ សម្រាប់ចាយវាយធ្វើកេន៍បុណ្យដែរ

៨- ឧបាសក អេង-ង៉ួន ក៏ពេញ ចូល ៥០០៛ សម្រាប់ធ្វើកេន៍បុណ្យ

៩- លោក តាន់ ឈាងលឹម តំណាងក្រុមចូល ១.០០០៛ ក្នុងការបោះពុម្ពសៀវភៅធម៌ជាធម្មទាន

១០- ឧបាសក គង់-ឡេង ឧបាសិកា ចាន់-ហ៊ុច ភូមិនិគេធចូល ៥០០៛ សម្រាប់បោះពុម្ពសៀវភៅធម៌

១១- ឧបាសក ឌុយ ឧបាសិកា ពុយ កសាងជងទង់ដែកមួយគូ ដាក់ខាងមុខវិហារបូជាព្រះរតនត្រ័យគេទៅ តម្លៃ ១០.០០០៛

១២ - ឧបាសក ដីវ ផ្សារថ្នាវអំពៅ ចូលបច្ច័យ ២០០៛ សម្រាប់

បោះពុម្ពសៀវភៅធម៌ ៗ សូមអភ័យទោសចំពោះអស់លោកខ្លះ ដែលពុំបានចេញនាមក្នុងសុន្ទរកថានេះ ៗ

## សូមថ្វាយព្រះពរ

នៅទីអវសាននេះ អាត្មាភាពសូមរំលឹកចំពោះគុណព្រះរតនត្រ័យ សូមសំបូងសង្រួងអស់ពួកទេវតាក្នុងលោកទាំងអស់ ដែលមានចិត្តល្អជាសម្មាទិដ្ឋិ សូមអភិបាលគ្រប់គ្រងសម្តេចព្រះមហាក្សត្រិយានីនិងសម្តេចព្រះប្រមុខរដ្ឋ អគ្គពុទ្ធសាសនូបត្ថម្ភក៍ សូមព្រះអង្គបានប្រកបដោយព្រះសុខភាពបរិបូណ៌ សូមព្រះអង្គប្រកបដោយព្រះសុភមង្គលវិបុលសុខសួស្តី មានព្រះជ័យជំនះឈ្នះអស់ពួកមារសត្រូវគ្រប់ទិសទាំង ១០ អស់កាលជានិច្ចនិរន្តរ៍គ្រប់ទិវារាត្រី ។

សូមថ្វាយ-ប្រគេន-ជូន ចំពោះសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស ព្រះរាជវង្សានុវង្ស, ឯកឧត្តម និងអស់លោកអ្នកទាំងឡាយគ្រប់ឋាន: នូវពរទាំង ៤ ប្រការ គឺ អាយុ វណ្ណ: សុខ: ពល: និងបដិភាណ: តវែងឆ្ងាយទៅកុំបីឃ្លៀងឃ្លាតឡើយ ។

# ឯកសារ

ដើម្បីជូនអស់លោកអ្នកអានបានជ្រាបខ្លះ អំពីអង្គការ និង ការបង្កើត ព្រមទាំងរបៀបចាត់ការរបស់វិទ្យាស្ថាន ដែលហៅថា « ពុទ្ធសាសនបណ្ឌិត្យ » ដ៏ជាទីផ្សាយទស្សនាវដ្ដីនេះ យើងខ្ញុំសូមចុះផ្សាយនូវព្រះរាជក្រម និង អត្ថបទច្បាប់នានា ដែលទាក់ទងនឹងវិទ្យាស្ថាននេះ ចាប់ពីលេខនេះទៅ ។

ព្រះរាជាណាចក្រកម្ពុជា

*លេខ ២១៦ ន.ស.*

## ព្រះរាជក្រម

*ព្រះបាទសម្ដេចព្រះ នរោត្ដម សុរាម្រិត*

*វិសុទ្ធមហាខត្តិយវង្ស វិសិដ្ឋហរិពង្ស គុណាតិរេក ធម្មបរិយោត្ដម បរមបពិត្រ ព្រះចៅព្រះរាជអាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង*

*បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រ*

*បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ១២៨-នស ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៩៥២ ស្ដីអំពីការរៀបចំក្រសួងធម្មការ និង សាសនសិក្សាធិការ*

*បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ៣៣៨-នស ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៥៦ ស្ដីអំពីការតែងតាំងគណៈរដ្ឋមន្ត្រី*

*បានទ្រង់យល់យោបល់នៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ*

*គណៈរដ្ឋមន្ត្រីបានយល់ព្រមផង*

ទ្រង់មានព្រះបរមរាជឱង្ការប្រកាសឱ្យប្រើ

ច្បាប់ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ១៩៥៧ មានសេចក្ដីដូចតទៅនេះ ៖

មាត្រា ១ - ពុទ្ធសាសនបណ្ឌិត្យ ត្រូវចាត់ការ និងសម្របសម្រួលនូវការសិក្សានៃព្រះពុទ្ធសាសនាខាងហីនយាន ក្នុងចំណោមប្រជាជននៃប្រទេសកម្ពុជា និងក្រុមជនជាតិខ្មែរនៅក្រៅប្រទេស ។

មាត្រា ២- ពុទ្ធសាសនបណ្ឌិត្យ ដែលស្ថិតនៅក្រោមព្រះរាជូបត្ថម្ភ ត្រូវមាននីតិបុគ្គលិកលក្ខណភាព ក្រុមនេះត្រូវឡើងរដ្ឋមន្ត្រីក្រសួងធម្មការ ដែលជាប្រធានក្រុមប្រឹក្សាភិបាលនៃវិជ្ជាឋាននេះ ។

ពុទ្ធសាសនបណ្ឌិត្យ តាំងនៅក្រោមការដឹកនាំរបស់ជនមួយរូប ដែលតែងតាំងឡើងដោយព្រះរាជក្រឹត្យ តាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងធម្មការ ។ នាយកនេះ មានអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយរូប ជួយធ្វើការផង ។

មាត្រា ៣ - លក្ខខណ្ឌនៃការរៀបចំនិងការប្រព្រឹត្តទៅនៃពុទ្ធសាសនបណ្ឌិត្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ដែលធ្វើឡើងតាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងធម្មការ ។

មាត្រា ៤ - ថវិកាជាតិ ត្រូវទទួលភារៈខាងមុខចំណាយ សម្រាប់ការ

ប្រព្រឹត្តទៅនៃពុទ្ធសាសនបណ្ឌិត្យ ហើយនិងត្រូវទទួលប្រាក់ចំណូលពីក្រុមនេះ ។

មាត្រា ៥- បទបញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះ ទុកជាមោឃៈ ។

ធ្វើក្នុងព្រះបរមរាជវាំង ក្រុងភ្នំពេញ នៅថ្ងៃទី ២ ។ ៨ ១០ ឆ្នាំរកា នព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ២ ខែកញ្ញា គ.ស. ១៩៥៧ ។

ព្រះករុណាទ្រង់ឡាយព្រះហស្តលេខា : ន. សុរាម្រឹត

បានក្រាបបង្គំទូលថ្វាយ ទទួលព្រះបរមរាជឱង្ការដ៏កល់លើត្បូង

សូមឡាយព្រះហស្តលេខា

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

នាយករដ្ឋមន្ត្រី

ហត្ថលេខា : ស៊ឹម វ៉ា

រដ្ឋមន្ត្រីក្រសួងធម្មការ

ហត្ថលេខា : ប៉ាល់ ឌួន

អ្នកទទួល :

- អ-ល-គ ៖
- រាជកិច្ច
- ក្រសួងហិរញ្ញវត្ថុ
- គ្រប់ទីស្តីការរដ្ឋមន្ត្រី និងទីស្តីការអនុរដ្ឋលេខាធិការ
- ពុទ្ធសាសនបណ្ឌិត្យ

លេខ ៤១

បានឃើញ ហើយភ្ជាប់យោបល់

ភ្នំពេញ ថ្ងៃទី ១៤ សីហា ឆ្នាំ ១៩៥៧

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

ហត្ថលេខា : ទៀង កាង

សូមលោកអ្នកអាន មេត្តាកែតម្រូវពាក្យខ្លះ ដែលបោះពុម្ពខុសនៅ

ក្នុងអត្ថបទ "សទ្ទវិចារណ៍អំពីពាក្យខាល" ដូចតទៅៈ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ចូលវិចារណ៍ | មូលវិចារណ៍ | ៤៩៧ | ១០ |
| ហើយច្រើននិយាយ | ហើយប្រើនិយាយ | ៤៩៨ | ១៣ |
| ការនេះជាច្រើនហើយ ៗ | ការបេះដឹងច្រើនហើយៗ | ៤៩៩ | ១៧ |
| តែចំនួនគាថានេះថា | តែចំនួន ២ គាថានេះថា | ៥០០ | ៤ |
| ក៏អានយល់ | ក៏អាចយល់ | " | ១៤ |
| កុំនាំគ្នាទំនេរពេល | កុំនាំគ្នាទំនេរពេក | ៥០៣ | ៤ |
| គ្រប់គ្រងឲ្យជិត | គ្របប្រក់ឲ្យជិត | ៥០៣ | ១៧ |
| ចុះប្រើប្រាប់ថា | ចុះបើប្រាប់ថា | ៥០៤ | ៥ |
| កូមិខ្វេ១ កូមិយូ ១ | កូមិដើងខ្វេ១ កូមិដើងយូ១ | " | ១៧ |
| គាមធ្វើជញ្ជាំង | គាបធ្វើជញ្ជាំង | ៥០៥ | ៤ |
| នៅប្រគាត់ប្រគង | នៅប្រគាក់ប្រគង | ៥០៦ | ១៥ |
| ឥតឃើញមេខ្លា | ឥតឃើញខ្លា | ៥០៧ | ១០ |
| គេហៅថា "ខាល" | គេហៅថា "ខាល់" | ៥០៨ | ១៤ |
| ថា "ផ្តិលខាត់" | ថា "ផ្តិលខាល" | ៥០៩ | ៣ |